**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងការនាំចេញកញ្ចប់បញ្ញើ តាមប្រៃសណីយ៍កម្ពុជា

កម្មសិក្សាពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន៖ **ក្រុមហ៊ុន ប្រៃសណីយ៍កម្ពុជា**

តាក់តែងឡើងដោយ
និស្សិតឈ្មោះ៖ **គី វ៉ាន់ឆៃ**
**ថាច់ រ័ត្ន**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ឈុន ពហុ**

ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច
ជំនាញ គ្រប់គ្រងធុរកិច្ច ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេររបាយការណ៍ ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **គី វ៉ាន់ឆៃ** និង **ថាច់ រ័ត្ន** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី៤ ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងសហគ្រាស ជំនាន់ទី ១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០១៣-២០១៧ សូមថ្លែងនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

**មាតាបិតា** របស់យើងខ្ញុំទាំងពីរ ដែលមានអនេកប្បការគុណដ៏វិសេសវិសាលបំផុត ក្នុងការប្រសូត និងចិញ្ចឹមបីបាច់ថែរក្សារូបយើងខ្ញុំ តាំងពីមិនទាន់ដឹងក្តី រហូតធំពេញវ័យពេញរូបពេញរាង ព្រមទាំងផ្តល់ជាព្រហ្មវិហារធម៌ ការអប់រំ និងជំបូន្មានសព្វបែបយ៉ាង ដើម្បីឲ្យបុត្រា បុត្រីទទួលបាននូវចំណេះដឹង ជំនាញ និងអាកប្បកិរិយាថ្លៃថ្នូរនៅក្នុងសង្គម ។ បើគ្មានលោកអ្នកមានគុណទាំងពីរនោះទេ យើងខ្ញុំទាំងពីររូបក៏មិនអាចមានថ្ងៃនេះដែរ ។ លោកអ្នកមានគុណទាំងពីរ បានលះបង់កម្លាំងកាយ ចិត្តមិនខ្លាចនឿយហត់ និងតែងតែលើកទឹកចិត្តកូនគ្រប់ពេល ។

**ឯកឧត្តមសាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង** ព្រមទាំងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យគ្រប់ជាន់ថ្នាក់ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច ដែលបានលះបង់នូវពេលវេលាដ៏មានតម្លៃ ព្រមទាំងកម្លាំងកាយកម្លាំងចិត្ត យកចិត្តទុកដាក់ អប់រំ ណែនាំ និងបង្ហាត់បង្រៀនពួកយើងខ្ញុំដោយមិនខ្លាចនឿយហត់ ក៏ដូចជាចែករំលែកនូវបទពិសោធន៍ល្អៗក្នុងជីវិតរបស់លោក ព្រមទាំងចាត់ទុកយើងខ្ញុំប្រៀបបាននឹងបុត្របង្កើត ។

**លោកសាស្ត្រាចារ្យ ឈុន ពហុ** ដែលបានជួយណែនាំ ផ្តល់ចំណេះដឹងជាមូលដ្ឋានគ្រឹះ និងជំនាញ ជាពិសេសបំផុតនោះលោកជាបុគ្គលមួយរូបដ៏សំខាន់ ក្នុងការលើកទឹកចិត្ត និងផ្តល់ការយកចិត្តទុកដាក់ក្នុងការត្រួសត្រាយផ្លូវដល់យើងខ្ញុំ ក្នុងការសរសេរសារណាមួយនេះតាំងពីចាប់ផ្តើមរហូតសម្រេចបានជាផ្លែផ្កា ។

**កញ្ញា ផាវ ចាន់អេង** ប្រធានការិយាល័យបញ្ជូនបញ្ញើឆាប់រហ័សនៃសហគ្រាសប្រៃសណីយ៍កម្ពុជា ដែលបានអនុញ្ញាតឲ្យយើងខ្ញុំបានសាកសួរ សំណេះសំណាល ដក់ស្រង់នូវទិន្នន័យ និងព័ត៌មានសំខាន់ៗជាមូលដ្ឋានក្នុងការសរសេរបញ្ចប់សារណាដ៏មានសារៈសំខាន់មួយនេះ ។

**បុគ្គលិករបស់ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជាទាំងអស់** ដែលជាបុគ្គលប្រតិបត្តិការងារជាក់ស្តែងបានចូលរួមសហការ ផ្តល់ពេលវេលាដ៏មានតម្លៃក្នុងការសម្ភាសន៍ និងបំពេញនូវរាល់កម្រងសំណួរដែលបានចងក្រងឡើងដោយរូបយើងខ្ញុំទាំងពីរ ដែលនេះជាធាតុផ្សំមួយដ៏សំខាន់ ក្នុងការសរសេរសារណានេះបានសម្រេចជោគជ័យ ។

ជាទីបញ្ចប់យើងខ្ញុំសូមបួងសួងដល់គ្រប់វត្ថុសក្តិសិទ្ធិលើលោក សូមតាមជួយថែរក្សាមាតាបិតារបស់យើងខ្ញុំទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង លោកសាស្ត្រាចារ្យ ឈុន ពហុ ព្រមទាំងសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេសគឺកញ្ញា ផាវ ចាន់អេង និងបុគ្គលិកនៃសហគ្រាសប្រេសណីយ៍កម្ពុជាទាំងអស់ឲ្យជួបប្រទះនូវសេចក្តីសុខ និងពុទ្ធពរជ័យបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

## អារម្ភកថា

បើយើងក្រឡេកមកមើលប្រវត្តិសាស្ត្រប្រទេសកម្ពុជា នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជានៅពេលនោះបានរងនូវការខ្ទេចខ្ទាំស្ទើរតែទាំងអស់ ។ ស្ថាប័នរដ្ឋ ស្ថាប័នឯកជន រោងចក្រ សហគ្រាសគ្រប់ទីកន្លែងទូទាំងប្រទេសត្រូវបានបិទទ្វារ និងបំផ្លេចបំផ្លាញ ជាពិសេសគ្មានការចរាចរណ៍ទំនិញនាំចេញនាំចូល គ្មានវិស័យដឹកជញ្ជូន និងទូរគមនាគមន៍ ដែលធ្វើឲ្យសេដ្ឋកិច្ចប្រទេសកម្ពុជានៅពេលនោះធ្លាក់ដុនដាបដល់ចំណុចសូន្យ ។ បច្ចុប្បន្នក្រោយពីប្រទេសទទួលបានសន្តិភាព ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ យើងសង្កេតឃើញថាការដឹកជញ្ជូនទំនិញ ការនាំចេញ ការនាំចូល និងវិស័យទូរគមនាគមន៍នៅកម្ពុជាកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសដ៏កំសត់មួយនេះ ឲ្យមានការរីកចម្រើនទៅមុខ ។ ជាក់ស្តែងប្រៃសណីយ៍កម្ពុជា ជាសហគ្រាសស្វយ័តមួយ ដែលបានវិវត្តន៍ខ្លួនទៅមុខយ៉ាងរហ័សដើម្បីផ្តល់សេវាកម្មបញ្ញើ ដឹកជញ្ជូនទំនិញ និងសេវាកម្មផ្សេងៗទៀត សម្រាប់បំពេញនូវតម្រូវការអតិថិជនទាំងក្នុងស្រុក និងក្រៅស្រុក ។

ដោយសារមើលឃើញពីសារៈប្រយោជន៍នៃវិស័យប្រៃសណីយ៍និងទូរគមនាគមន៍នៅកម្ពុជា ដូច្នេះហើយ ទើបយើងខ្ញុំទាំងពីរសម្រេចចិត្តជ្រើសរើសយកសរសេរសារណាមួយដែលទាក់ទងនឹង **"ការគ្រប់គ្រងការនាំចេញកញ្ចប់បញ្ញើតាមប្រៃសណីយ៍កម្ពុជា"** ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងប្រៀបធៀបពីទ្រឹស្តីមេរៀនជាមួយនឹងសកម្មភាពជាក់ស្តែង ថាតើមានភាពខុសគ្នាបែបណា? ម្យ៉ាងទៀតសារណានេះអាចកើតចេញជារូបរាងបាន ដោយសារការពិភាក្សា និងការណែនាំ ឲ្យដំបូន្មានរបស់លោកសាស្ត្រាចារ្យ ឈុន ពហុ និងការចុះជួបផ្ទាល់ ក៏ដូចជាផ្តល់នូវឯកសារនានា ពីកញ្ញា ផាវ ចាន់អេង ប្រធានការិយាល័យបញ្ជូនបញ្ញើឆាប់រហ័ស នៃប្រៃសណីយ៍កម្ពុជា និងបុគ្គលិកក្រុមហ៊ុនប្រៃសណីយ៍កម្ពុជាទាំងអស់ ។

ទោះបីជាមានការយកចិត្តទុកដាក់ សម្រិតសម្រាំងខ្លាំងយ៉ាងណាក៏ដោយ យើងខ្ញុំជឿជាក់ថា សារណាមួយនេះប្រាកដជា មិនអាចជៀសផុតពីកំហុសខុសឆ្គងដោយប្រការណាមួយ ទាំងអត្ថន័យ និងអក្ខរាវិរុទ្ធជាក់ជាមិនខាន ។ អាស្រ័យហេតុនេះ យើងខ្ញុំរង់ចាំជានិច្ច ទទួលយកនូវការរិះគន់ក្នុងការស្ថាបនានានា ពីសំណាក់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីធ្វើយ៉ាងណាបំពេញនូវចំណុចខ្វះខាត និងកែលម្អរឡើងវិញសម្រាប់ជាបទពិសោធន៍ទៅថ្ងៃអនាគត ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់សង្ឃឹមយ៉ាងមុតមាំថា ឯកសារនេះនឹងក្លាយទៅជារបាយការណ៍ស្រាវជ្រាវមួយ ដែលអាចជាប្រយោជន៍ដល់សង្គម និងជាទុនសម្រាប់ចែករំលែកដល់ប្អូនៗជំនាន់ក្រោយៗទៀត យកមកប្រើប្រាស់ជាឯកសារជំនួយក្នុងការសិក្សា ។

# មាតិកា

បញ្ជីអក្សរកាត់ ..................................................................................................................vii
បញ្ជីរូបភាព .......................................................................................................................viii
បញ្ជីឧបសម្ព័ន្ធ ......................................................................................................................xi

## សេចក្តីផ្តើម

១.លំនាំបញ្ហានៃការស្រាវជ្រាវ ..................................................................................................១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..........................................................................................១
៣. គោលបំណងនៃការស្រាវជ្រាវ ..............................................................................................២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ..................................................................................២
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ...................................................................................................៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ .............................................................................................៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ...............................................................................................៤

## ជំពូកទី ១
## ការសិក្សាលើផ្នែកទ្រឹស្តី

១.១ និយមន័យ ........................................................................................................................៦
១.១.១ ការគ្រប់គ្រង ................................................................................................................៦
១.១.២ សហភាពប្រៃសណីយ៍សកល ..............................................................................................៩
១.១.៣ បញ្ញើប្រៃសណីយ៍នាំចេញ ................................................................................................ ១០
១.១.៤ ពាក្យគន្លឹះក្នុងវិស័យប្រៃសណីយ៍ ...................................................................................... ១១
១.២ សញ្ញាណសំខាន់ៗ ............................................................................................................. ២០
១.២.១ អាជីវកម្មជាលក្ខណៈអន្តរជាតិ .......................................................................................... ២០
១.២.២ ទីផ្សារ និងការប្រកួតប្រជែង ........................................................................................... ២១
១.២.៣ សេវាកម្មដឹកជញ្ជូនបញ្ញើ .............................................................................................. ២៣
១.៣ ផលិតផល និងសេវាកម្ម ..................................................................................................... ២៤
១.៣.១ សេវាបញ្ញើប្រៃសណីយ៍ធម្មតា ......................................................................................... ២៤
១.៣.១.១ ប្រៃសណីយ៍ប័ត្រ ....................................................................................................... ២៤

១.៣.១.២ លិខិតអាកាសយាន ........ ២៤
១.៣.១.៣ សំបុត្រ ........ ២៤
១.៣.១.៤ កលិកប័ត្រ ........ ២៤
១.៣.១.៥ កញ្ចប់តូច ........ ២៤
១.៣.១.៦ សំភារៈសិក្សាសម្រាប់មនុស្សខ្វាក់ ........ ២៥
១.៣.១.៧ បញ្ញើផ្ញើរាបតាមអាកាសយាន ........ ២៥
១.៣.២ តែមប្រៃសណីយ៍ ........ ២៥
១.៣.៣ ប្រអប់សំបុត្រ ........ ២៧
១.៣.៤ សេវាបញ្ញើប្រៃសណីយ៍ភ័ណ្ឌ ........ ២៩
១.៣.៥ សេវាបញ្ញើឆាប់រហ័ស (EMS) ........ ២៩
១.៣.៦ សេវាពិសេស ........ ៣០
១.៣.៧ សេវាលើការងារដឹកជញ្ជូនបញ្ញើ និងដឹកអ្នកដំណើរក្នុងស្រុក ........ ៣០
១.៣.៨ តារាងតម្លៃសេវាប្រៃសណីយ៍ ........ ៣៤
១.៤ ឯកសារពាក់ព័ន្ធ និងការធ្វើពាណិជ្ជកម្ម ........ ៣៤
១.៤.១ អនុសារណានៃការយោគយល់គ្នារវាង UPU និង WOC ........ ៣៤
១.៤.២ អនុក្រិត លិខិតអនុញ្ញាត សារចរណែនាំ និងសេចក្តីជូនដំណឹង ........ ៣៦
១.៤.៣ សញ្ញាណខ្លះនៃ B/L , Air waybill , និង Manifest ........ ៣៦
១.៤.៤ ដីការអម (ដីការបញ្ជូន) ........ ៣៧
១.៤.៥ ពន្ធគយ និងពន្ធដទៃទៀត ........ ៣៧
១.៤.៦ ការរួចអាករប្រៃសណីយ៍ ........ ៣៧
១.៥ ច្បាប់ស្តីពីវិស័យប្រៃសណីយ៍ ........ ៣៨
១.៦ ការគ្រប់គ្រងបញ្ញើប្រៃសណីយ៍ ........ ៣៨
១.៦.១ ប្រព័ន្ធនៃការតាមដានបញ្ញើ ........ ៣៨
១.៦.២ ការប្រើប្រាស់នូវម៉ាស៊ីនស្កេន ........ ៤០
១.៦.៣ ការប្រើប្រាស់នូវវេបសាយផ្លូវការរបស់ប្រៃសណីយ៍កម្ពុជា ........ ៤០
១.៦.៤ ប្រព័ន្ធគ្រប់គ្រងគុណភាពសេវាកម្ម ........ ៤១
១.៦.៥ ការរក្សាការសម្ងាត់ ........ ៤២

## ជំពូកទី ២

## ការអនុវត្តន៍លើកញ្ចប់បញ្ញើនាំចេញនៃវិស័យប្រៃសណីយ៍កម្ពុជា


២.១ ស្ថានភាពទូទៅ ........ ៤៣
២.១.១ប្រវត្តិ ........ ៤៣
២.១.២ ទីតាំងរបស់ក្រុមហ៊ុន ........ ៤៤
២.១.៣ ទស្សនៈវិស័យ ........ ៤៤
២.១.៤ ស្លាកសញ្ញា និងពាក្យស្លោក ........ ៤៥
២.១.៥ សក្តានុពលសេដ្ឋកិច្ច ........ ៤៦
២.២ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជា ........ ៤៧
២.២.១ តួនាទី និងភារកិច្ច ........ ៤៧
២.២.២ មុខចំណូលអាជីវកម្មប្រៃសណីយ៍កម្ពុជា ........ ៥៣
២.២.៣ ក្របខ័ណ្ឌប្រាក់បៀវត្សរ៍ ........ ៥៤
២.៣ ដំណើរការលើការនាំចេញទំនិញ ........ ៥៦
២.៣.១ ការទទួលបញ្ញើ ........ ៥៦
២.៣.១.១ ការទទួលបញ្ញើធម្មតា ........ ៥៧
២.៣.១.២ ការទទួលបញ្ញើប្រៃសណីយ៍ភ័ណ្ឌ ........ ៥៨
២.៣.១.៣ ការទទួលបញ្ញើឆាប់រហ័ស ........ ៥៨
២.៣.២ ការត្រួតពិនិត្យបញ្ញើជារូបវន្ត ........ ៥៩
២.៣.៣ ការវេចខ្ចប់បញ្ញើ ........ ៦១
២.៣. ៤ ការដាក់ឲ្យឆ្លងកាត់ម៉ាស៊ីនស្កេន ........ ៦៣
២.៣.៥ ការដឹកជញ្ជូនបញ្ញើ ........ ៦៣
២.៣.៦ ការធានា និងការទទួលខុសត្រូវលើបញ្ញើ ........ ៦៥
២.៣.៧ សារៈសំខាន់នៃវិស័យប្រៃសណីយ៍ ........ ៦៦


## ជំពូកទី ៣

## ការសិក្សាលើលទ្ធផល


៣.១ សមិទ្ធផលដែលសហគ្រាសប្រៃសណីយ៍កម្ពុជាសម្រេចបាន ........ ៦៨
៣.១.១ កំនើននៃបរិមាណបញ្ញើនាំចេញ ........ ៦៨

៣.១.២ ប្រសិទ្ធិភាពនៃការត្រួតពិនិត្យ ........ ៦៨
៣.១.៣ ការវេចខ្ចប់ប្រកបដោយស្តង់ដារ ........ ៧០
៣.១.៤ ការរុករកឃើញ និងទប់ស្កាត់វត្ថុហាមឃាត់ ........ ៧១
៣.១.៥ ការបញ្ជូនបញ្ញើមានភាពឆាប់រហ័ស ........ ៧១
៣.១.៦ ទំនុកចិត្ត និងភាពពេញចិត្តរបស់អតិថិជន ........ ៧២
៣.២ បញ្ហាប្រឈម ........ ៧៣
៣.២.១ បញ្ហាពេលទទួលបញ្ញើពីអតិថិជន ........ ៧៣
៣.២.២ បញ្ហាចន្លោះប្រហោងនៃការត្រួតពិនិត្យនៅតាមមន្ទីរប្រៃសណីយ៍ខេត្ត ........ ៧៤
៣.២.៣ ធនធានមនុស្សនៅមានកម្រិត ........ ៧៤
៣.២.៤ ការផ្ញើទំនិញដែលហាមឃាត់ និងទំនិញមានវេទយិតភាព ........ ៧៤
៣.២.៥ បញ្ហាពាក់ព័ន្ធនឹងការដឹកជញ្ជូនបញ្ញើ ........ ៧៥
ក. ប្រព័ន្ធIPS មិនដំណើរការ ........ ៧៥
ខ. អាកាសធាតុ ........ ៧៦
គ. បញ្ហាចរាចរណ៍ ........ ៧៦
ឃ. បញ្ញើសំណល់ ........ ៧៦
៣.៣ ដំណោះស្រាយ ........ ៧៦
៣.៣.១ ការបញ្ជូនបន្ត បញ្ជូនត្រឡប់ និងពាក្យសុំកែប្រែអាស័យដ្ឋាន ........ ៧៦
៣.៣.១.១ ការបញ្ជូនបន្ត ........ ៧៦
៣.៣.១.២ការបញ្ជូនត្រឡប់ ........ ៧៧
៣.៣.១.៣ ពាក្យសុំកែប្រែអាស័យដ្ឋាន ........ ៧៨
៣.៣.១.៤ បណ្តឹងតវ៉ា ........ ៧៨
៣.៣.២ ការត្រួតពិនិត្យលម្អិតនៅភ្នំពេញ ........ ៧៨
៣.៣.៣ ការរៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស ........ ៧៩
៣.៣.៤ ការសហការជាមួយស្ថាប័នមានសមត្ថកិច្ច ........ ៨០
៣.៣.៥ ការបំពេញឯកសារដឹកជញ្ជូនដោយដៃ ........ ៨០
៣.៣.៦ បែបបទអនុវត្តក្នុងករណីបញ្ញើពុំអាចចែកបាន ........ ៨១

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន .......... ៨២
២.ការផ្តល់អនុសាសន៍ .......... ៨៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| LC | = | Letters et Cartes ( Letters and Cards ) |
| AO | = | Autre Objects ( Other Articles ) |
| CP | = | Colis Postaux ( Parcel Post ) |
| EMS | = | Express Mail and Service |
| CIF | = | Cost Insurance & Freight |
| FOB | = | Free On Board |
| UPU | = | Universal Postal Union |
| IPS | = | International Postal System |
| S.A.L | = | Surface Air Leaf |
| P.O. Box | = | Post Office Box |
| GDCE | = | General Department of Customs and Excise |
| BL | = | Bill of Lading |
| CO | = | Country of Origin |
| MTO | = | Multimodal Transport Operation |
| AR | = | Advise of Receipt |
| VAT | = | Value Added Tax |
| CN | = | Customs Declaration ( CN 22/CN 23 ) |
| MOU | = | Memorandum Of Understanding |
| WCO | = | World Customs Organization |
| IBRS | = | International Business Reply Service |
| OE | = | Office of Exchange |
| AHTN | = | Asean Harmonised Tariff Nomenclature |
| EMO | = | Electronic Money Order |
| PL | = | Packing List |
| ASYCUDA | = | Automated System for Customs Data |
| CPB | = | Cambodia Post Bank PLC |

## បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១: គំរូសលាកបត្របញ្ជី

ឧបសម្ព័ន្ធទី២: តារាងប្រទេសដែលអាចផ្ញើសេវាបញ្ញើឆាប់រហ័ស

ឧបសម្ព័ន្ធទី៣: តារាងប្រទេសសម្រាប់បញ្ញើប្រៃសណីយ៍ភ័ណ្ឌតាមយន្តហោះ

ឧបសម្ព័ន្ធទី៤: តារាងប្រទេសសម្រាប់បញ្ញើប្រៃសណីយ៍ភ័ណ្ឌតាមផ្ទៃរាប

ឧបសម្ព័ន្ធទី៥: ទម្រង់ឯកសារសម្រាប់ធ្វើបណ្តឹងតវ៉ាលើបញ្ញើប្រៃសណីយ៍

ឧបសម្ព័ន្ធទី៦: គំរូពាក្យសុំកែប្រែអាស័យដ្ឋាន

ឧបសម្ព័ន្ធទី៧: អនុស្សារណៈនៃការយោគយល់គ្នារវាងអង្គការគយពិភពលោក និងសហភាពប្រៃសណីយ៍សកល

ឧបសម្ព័ន្ធទី៨: សារាចរណែនាំស្តីពីនិតិវិធីគយលើទំនិញមានតម្លៃទាប និងសំណើរសុំសហការទប់ស្កាត់ការនាំចេញសំណាក់រ៉ែ

ឧបសម្ព័ន្ធទី៩: ប្រកាសស្តីពីបញ្ញើហាមឃាត់ និងអនុក្រិត្យលេខ២០៩

ឧបសម្ព័ន្ធទី១០: គម្រូនៃB/L; Air waybill; Manifest និងដីការអម

ឧបសម្ព័ន្ធទី១១: វែបសាយបញ្ញើឆាប់រហ័សពិភពលោក

## បញ្ជីរូបភាព

រូបភាពទី១៖ មុខងារនៃការគ្រប់គ្រង ..........៩
រូបភាពទី២៖ ដំណើរការបញ្ញើផ្ញើរាបបញ្ជូនតាមអាកាសយាន ..........២៥
រូបភាពទី៣៖ កម្រងតែមប្រៃប្រៃសណីយ៍ ..........២៦
រូបភាពទី៤៖ រថយន្តដឹកជញ្ជូនបញ្ញើ និងអ្នកដំណើរក្នុងស្រុក .......... ៣៣
រូបភាពទី៥៖ គេហទំព័រផ្លូវការរបស់ប្រៃសណីយ៍កម្ពុជា ..........៤០
រូបភាពទី៦៖ បញ្ញាត្តិទូទៅនៃប្រព័ន្ធត្រួតពិនិត្យសលក ..........៤២
រូបភាពទី៧៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ប្រៃសណីយ៍កម្ពុជា .......... ៤៧
រូបភាពទី៨៖ មុខចំណូលអាជីវកម្មប្រៃសណីយ៍ឆ្នាំ២០១៦ ..........៥៥
រូបភាពទី៩៖ សៀលបញ្ជាក់ពីវត្ថុងាយបែក ..........៦១
រូបភាពទី១០៖ មុខទំនិញដែលបានត្រួតពិនិត្យ និងទប់ស្កាត់ការនាំចេញ .......... ៧០
រូបភាពទី១១៖ លទ្ធផលនៃការវាស់ស្ទង់ភាពពេញចិត្តរបស់អតិថិជន ..........៧៣

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសម័យសកលភាវូបនីយកម្មបច្ចុប្បន្ន សេដ្ឋកិច្ចអន្តរជាតិកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍឆ្ពោះទៅរកភាពជឿនលឿន នៃបណ្តាប្រទេសនីមួយៗ ។ សកម្មភាពទាំងអស់នេះស្តែងចេញពីការចរាចរនៃលំហូរនៃទំនិញនាំចេញនាំចូល ។ ក្នុងនោះផងដែរ ក្រៅពីការនាំចេញនាំចូលដែលមានលក្ខណៈពាណិជ្ជកម្ម ឬទ្រង់ទ្រាយធំ យើងក៏សង្កេតឃើញមានការនាំចេញនិងនាំចូលដែលគ្មានលក្ខណៈពាណិជ្ជកម្ម ឬមានទំហំតូចតាចផងដែរ ។ ជាក់ស្តែងការដឹកទំនិញនាំចេញនាំចូលតាមច្រកប្រៃសណីយ៍កម្ពុជាកំពុងមានសន្ទុះ ទទួលបានការចាប់អារម្មណ៍ និងការនិយមពេញចិត្តពីសំណាក់អតិថិជនទាំងក្នុង និងក្រៅប្រទេស ។ យើងឃើញថា ប្រជាជនកម្ពុជា តែងតែផ្ញើទំនិញពីកន្លែងមួយទៅកន្លែងមួយទៀតតាមរយៈតាក់ស៊ី ដែលមិនមានការធានាលើការខូចខាត ឬបាត់បង់នោះទេ ហើយក៏អាចធ្វើអោយខាតបង់ពេលវេលាជាច្រើនក្នុងការដឹកជញ្ជូនពីរថយន្តឈ្នួលមួយទៅរថយន្តឈ្នួលមួយទៀត ឬដឹកទៅតាមខេត្ត ។ ដោយមើលឃើញពីចំនុចអវិជ្ជមានមួយចំនួនដូចជា បញ្ហាសុវត្ថិភាព សុខមាលភាព កត្តាពេលវេលា កត្តាថវិកា ទំនុកចិត្តនិងភាពជឿជាក់ ដែលជាមូលហេតុនាំអោយមានកើតមាននូវបញ្ហាទាំងអស់នោះ ទើបធ្វើឲ្យពួកគេបាត់បង់ទំនុកចិត្ត លើការប្រើប្រាស់សេវាកម្មដឹកជញ្ជូនតាមរយៈតាក់ស៊ី ហើយងាកមកប្រើប្រាស់សេវាកម្មប្រៃសណីយ៍កម្ពុជាវិញ[១]។ ទន្ទឹមនឹងនោះដែរប្រៃសណីយ៍កម្ពុជាក៏មានដៃគូរ ១៩២ប្រទេសដែលចែកចាយបញ្ញើនូវពាសពេញពិភពលោក ហើយតួលេខបានបង្ហាញថា ទំនិញនាំចេញទៅកាន់ទីផ្សារអន្តរជាតិមានប្រមាណជាង២តោនក្នុងមួយថ្ងៃ[២]។ ដោយផ្អែកលើមូលហេតុខាងលើនេះហើយ ទើបធ្វើឲ្យយើងខ្ញុំសូមធ្វើការសិក្សាស្រាវជ្រាវ ពីដំណើរការនៃការគ្រប់គ្រងការនាំចេញកញ្ចប់បញ្ញើប្រៃសណីយ៍កម្ពុជា និង តាមដាននូវរាល់ប្រតិបត្តិការនៃការដឹកជញ្ជូន ព្រមទាំងការចែកចាយបញ្ញើផងដែរ ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

បច្ចេកវិទ្យា ព័ត៌មានវិទ្យា កំពុងតែបានផ្លាស់ប្តូរសេដ្ឋកិច្ចពិភពលោកឈានទៅរកភាពជឿនលឿននិងបានធ្វើអោយប្រជាជាតិទាំងអស់កាន់តែមានភាពជិតស្និទ្ធ ជាមួយគ្នាកាន់តែខ្លាំងឡើងៗ។ ជាពិសេសវាបានផ្តល់ឱកាស ក៏ដូចជាជួយសម្រួលទៅដល់ការធ្វើពាណិជ្ជកម្មកាន់តែមានទំនើបកម្មមានប្រសិទ្ធិភាព ស្របពេលជាមួយគ្នានោះ វិស័យប្រៃសណីយ៍កម្ពុជាក៏បានចាប់ផ្តើមរស់រានឡើងវិញ ដោយបានចូលរួមចំនែកយ៉ាងច្រើន ក្នុងការផ្តល់នូវគុណភាព និងទំនុកចិត្តដល់អតិថិជនដែលសម្រេចចិត្តជ្រើសរើសយកសេវាកម្មបញ្ញើរបស់ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជា ។

[១] គេហទំព័រFresh New: http://m.freshnewasia.com/index.ph/en/17765-2016-02-11-07-13-21.html

[២] គេហទំព័រ: http://www.tradingeconomics.com/cambodia/balance-of-trade

ជាក់ស្តែងប្រទេសកម្ពុជាត្រូវបានគេរាយការណ៍អោយដឹងថា មានឱនភាពជញ្ជីងពាណិជ្ជកម្ម ប្រមាណជា៩៩៤.៩៤ប៊ីលានរៀល ក្នុងខែ វិច្ឆិកា ឆ្នាំ២០១៦ ដោយសារតែការនាំចូលទំនិញពីបរទេសច្រើនជាងការនាំចេញ។ ម្យ៉ាងវិញទៀតការនាំចេញទំនិញ ឬបញ្ញើ និងការដឹកជញ្ជូននៅក្នុងប្រទេសកម្ពុជានៅមិនទាន់មានសក្តានុពលខ្លាំង បើប្រៀបធៀបនឹងបណ្តាប្រទេសជាដៃគូរ ។ ដូច្នេះតើយើងត្រូវធ្វើបែបណាខ្លះ ក្នុងការជំរុញលើការនាំចេញទំនិញតាមប្រៃសណីយ៍កម្ពុជាអោយមានលក្ខណៈប្រកួតប្រជែងជាងមុន ? តើវិស័យប្រៃសណីយ៍បញ្ញើនាំចេញមានដំណើរការដូចម្តេច ? និងមានបញ្ហាអ្វីខ្លះដែលត្រូវដោះស្រាយ ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណង ដើម្បីលើកស្ទួយ និងអភិវឌ្ឍន៍ការនាំចេញ តាមរយៈប្រៃសណីយ៍ក្នុងប្រទេសកម្ពុជាតាមរយៈការបញ្ជ្រាបព័ត៌មាន ចំណេះដឹង និងអត្ថប្រយោជន៍របស់វាទៅកាន់ប្រជាជនកម្ពុជាអោយមានការប្រើប្រាស់សេវាកម្មនេះអោយបានច្រើន ព្រមទាំងចង់ធ្វើការផ្សព្វផ្សាយពីនិតិវិធីនៃការប្រគល់ទទួលទំនិញ និងបញ្ញត្តិស្របច្បាប់នានាក្នុងព្រះរាជាណាចក្រកម្ពុជាដែលទាក់ទិននឹងការដឹកជញ្ជូន ។ លើសពីនេះទៅទៀតគោលបំណងនៃការស្រាវជ្រាវនោះ ចង់ធ្វើការបង្ហាញពីរបកគំហើញថ្មី ដែលប្រទេសជឿនលឿនមួយចំនួនកំពុងតែអនុវត្តន៍ ប៉ុន្តែមិនទាន់មានវត្តមាននៅក្នុងប្រទេសកម្ពុជា ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

វិស័យប្រៃសណីយ៍កម្ពុជា មានផលិតផល និងសេវាកម្មយ៉ាងច្រើនដូចជា ការនាំចេញ ការនាំចូល សេវាផ្ទេរប្រាក់ ការផ្ញើសំបុត្រ ឬលិខិត សេវាកម្មដឹកជញ្ជូនតាមរថយន្ត សេវាបញ្ញើឆាប់រហ័ស ប្រៃសណីយ៍ភ័ណ្ឌ ប្រអប់សំបុត្រ តែមប្រ៊ីជាដើម ។ ប៉ុន្តែការស្រាវជ្រាវនេះផ្តោតទៅលើការគ្រប់គ្រងសេវាកម្មនាំចេញទំនិញរបស់ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជា(Cambodia post) និងការអនុវត្តការងារនាពេលបច្ចុប្បន្ន ក៏ដូចជាការស្វែងរកនូវយន្តការគន្លឹះៗ ដើម្បីអភិវឌ្ឍន៍អង្គភាពខ្លួនឯងផ្ទាល់ព្រមទាំងសង្គមជាតិទាំងមូល ។ ឯកសារដែលប្រមូលបាន សម្រាប់ជាទឡ្ហីករណ៍និងជាតឹកតាងក្នុងការសរសេរ ត្រូវបានជ្រើសរើសយកទីតាំងស្ថិតនៅក្នុងប្រៃសណីយ៍កម្ពុជា រវាងចន្លោះឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៦ ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

- **តម្រូវការព័ត៌មាន**

ក.ទិន្នន័យចម្បង៖ ការសម្ភាសន៍ផ្ទាល់មាត់ជាមួយថ្នាក់ដឹកនាំ និងបុគ្គលិកបម្រើការ នៅក្នុងក្រុមហ៊ុនប្រៃសណីយ៍កម្ពុជាតាមរយៈការតាក់តែងជាប្រភេទកម្រងសំណួរ ដើម្បីទទួលបានព័ត៌មានពីដំណើរការ និងប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា ។

ខ.ទិន្នន័យបន្ទាប់បន្សំ៖ របាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្មឆ្នាំ ២០១៦ និងទិសដៅឆ្នាំ២០១៧ ច្បាប់ស្តីពីវិស័យប្រៃសណីយ៍ និងតារាងតម្លៃសេវាប្រៃសណីយ៍ (អនុវត្តចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧) និង គេហទំព័រផ្លូវការរបស់សហគ្រាសប្រៃសណីយ៍កម្ពុជា (www.cambodiapost.com) គេហទំព័រហ្វេកប៊ុកផ្លូវការរបស់ក្រុមហ៊ុន និង វិបសាយដទៃទៀតដែលមានពាក់ព័ន្ធនឹងវិស័យប្រៃសណីយ៍នៅកម្ពុជា ។ ព័ត៌មាន និងទិន្នន័យភាគច្រើនប្រមូលបានមកពីឯកសារ អត្ថបទផ្សព្វផ្សាយ វិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី និងរបាយការណ៍ផ្សេងៗដែលក្រុមហ៊ុនផ្តល់អោយ ព្រមទាំងការតាមដានលើគេហទំព័រផ្លូវការរបស់ក្រុមហ៊ុន Cambodia Post សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការស្រាវជ្រាវ វិភាគ និងតាក់តែង ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

**-ចំពោះក្រុមហ៊ុនផ្ទាល់**

- ផ្សព្វផ្សាយពីសេវាប្រៃសណីយ៍លើការនាំចេញអោយកាន់តែទូលំទូលាយ
- បង្ហាញពីវិធីសាស្ត្រក្នុងការគ្រប់គ្រងបញ្ញើ
- បង្កើនចំណេះដឹងស្តីពីវិស័យប្រៃសណីយ៍កម្ពុជា និងច្បាប់ផ្សេងៗដែលទាក់ទិននឹងវិស័យនោះ
- ដើម្បីស្វែងរកនូវរបកគំហើញដែលមានលក្ខណៈប្រកួតប្រជែង
- ដើម្បីគ្រប់គ្រងលើការធានាសុវត្ថិភាព និងការទទួលខុសត្រូវលើការបាត់បង់ ។

**-ចំពោះនិស្សិត**

- ទទួលបាននូវសេវាកម្មដឹកជញ្ជូនដែលមានតម្លៃទាបសមរម្យ
- សម្រួលដល់ការយកទំនិញតាមខ្លួនច្រើន ឬហួសការកំណត់
- បង្ហាញការចំណេញពេលវេលា ចំណេញថវិកា ក្នុងនាំយកទំនិញពីកន្លែងមួយទៅកន្លែងមួយទៀត។

- ផ្តល់នូវភាពកក់ក្តៅ ក្នុងការធានារ៉ាប់រងលើគ្រប់ទំនិញទាំងអស់ របស់អ្នកដែលប្រើប្រាស់សេវាកម្មប្រៃសណីយ៍ ។

**-ចំពោះសង្គមជាតិ**

- ជំរុញអោយការនាំចេញទំនិញទៅកាន់ទីផ្សារអន្តរជាតិកាន់តែច្រើន
- សង្គមទទួលបានចំណូលបន្ថែមដោយសារតែការនាំចេញ
- បង្កើតការងារដល់ប្រជាពលរដ្ឋអោយមានការងារធ្វើគ្រប់ៗគ្នា
- កាត់បន្ថយនូវភាពអនាធិបតេយ្យ និងអសន្តិសុខនៅក្នុងសង្គម
- កំណត់ពីវិសាលភាពនៃសេវាកម្មដឹកជញ្ជូន តាមប្រៃសណីយ៍កម្ពុជា ដែលជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះមានការរចនាសម្ព័ន្ធនៃការស្រាវជ្រាវសំខាន់ៗចំនួនបីផ្នែកគឺ សេចក្តីផ្តើម ខ្លឹមសារនៃការស្រាវជ្រាវ និងសេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ ដោយបានធ្វើការរៀបរាប់ដូចខាងក្រោម៖

### ១. សេចក្តីផ្តើម

សេចក្តីផ្តើម គឺជាលំនាំបញ្ហាមួយដែលចង់បង្ហាញអោយអ្នកអានបានស្វែងយល់ពី ប្រធានបទពីកម្មវត្ថុ វត្ថុបំណងរបស់អ្នកស្រាវជ្រាវ និងយល់ពីអ្វីដែលអ្នកស្រាវជ្រាវចង់បង្ហាញអោយកាន់តែច្បាស់បន្ថែមក្នុងការចង់ដោះស្រាយបញ្ហាដោយប្រើប្រាស់ វិធីសាស្ត្រទៅតាមលំដាប់លំដោយមួយសមស្រប និងមានការស៊ីសង្វាក់គ្នាពីរឿងមួយទៅរឿងមួយទៀត ។

សេចក្តីផ្តើម បានបរិយាយពី លំនាំបញ្ហានៃការស្រាវជ្រាវ ចំនោទបញ្ហានៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ។

### ២. ខ្លឹមសារនៃការស្រាវជ្រាវ

ខ្លឹមសារនៃការស្រាវជ្រាវនេះបានបែងចែកជាបីជំពូក រួមមាន៖

-ជំពូកទី១៖ រំលេចឡើង នៃការសិក្សាលើទ្រឹស្តី ដែលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មលក្ខណៈអន្តរជាតិបែបកញ្ចប់បញ្ញើ និងឯកសារគតិយុទ្ធដែលបង្ហាញអំពីសកម្មភាពនៃការគ្រប់គ្រងអាជីវកម្មរបស់ក្រុមហ៊ុន ។

-ជំពូកទី២៖ ស្តែងឡើងពីការអនុវត្តន៍លើកញ្ចប់បញ្ញើនាំចេញ នៃវិស័យប្រៃសណីយ៍កម្ពុជា ដែលរួមបញ្ចូលនូវ ប្រវត្តិ ទីតាំងរបស់ក្រុមហ៊ុន ទស្សនៈវិស័យ ស្លាកសញ្ញា និងពាក្យស្លោក សក្តានុពលសេដ្ឋកិច្ចរបស់ក្រុមហ៊ុន រចនាសម្ព័ន្ធការគ្រប់គ្រង និងដំណើរការលើការនាំចេញដោយរួមមាន ការទទួលបញ្ញើ ការត្រួតពិនិត្យបញ្ញើជារូបវន្ត ការវេចខ្ចប់បញ្ញើ ការដាក់អោយឆ្លងកាត់ម៉ាស៊ីនស្កេន ការដឹកជញ្ជូនបញ្ញើ ការធានានិងការទទួលខុសត្រូវលើបញ្ញើ ។

-ជំពូកទី៣៖ វិភាគលើលទ្ធផល និងសមិទ្ធិផលដែលសម្រេចបាន ដោយមានដូចជា កំណើននៃការនាំចេញ ប្រសិទ្ធិភាពក្នុងការត្រួតពិនិត្យ ភាពស្តង់ដារនៃការវេចខ្ចប់ ការស្រាវជ្រាវទប់ស្កាត់និងបង្ក្រាបបាននូវទំនិញហាមឃាត់ និងភាពឆាប់រហ័សនៃការដឹកជញ្ជូនបញ្ញើ ។ លើសពីនេះទៅទៀតបានវិភាគទៅលើបញ្ហាប្រឈមដែលជាចំណុចរសើបរបស់ក្រុមហ៊ុន ជាពិសេសបានធ្វើការវែកញែក រិះរកនូវដំណោះស្រាយដែលទាក់ទងនឹងទ្រឹស្តីបទពិសោធន៍និងច្បាប់ជាដើម ។

### ៣.សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

ជាការបូកសរុបសង្ខេប ការសន្និដ្ឋានចុងក្រោយ ទៅលើការអនុវត្តន៍ និងការផ្គត់ផ្គង់សេវាកម្មរបស់ក្រុមហ៊ុន ដោយកំណត់នូវចំនុចខ្លាំង ចំនុចខ្សោយ និងបញ្ហានានាដែលកំពុងកើតឡើង ។ ព្រមទាំង បានផ្តល់ជាអនុសាសន៍ ក្នុងការចូលរួមជាមតិយោបល់ ទៅលើការស្រាវជ្រាវសកម្មភាពរបស់ក្រុមហ៊ុនដោយធ្វើយ៉ាងណាអោយក្រុមហ៊ុន កាន់តែមានការរីកចម្រើននិងការវិវត្តឈានទៅមុខជានិច្ច ។

# ជំពូកទី ១

# ការសិក្សាលើផ្នែកទ្រឹស្តី

## ១.១ និយមន័យ

### ១.១.១ ការគ្រប់គ្រង

គេមិនអាចបញ្ជាក់បានទេថាតើនិយមន័យនៃការគ្រប់គ្រងមួយណា ជានិយមន័យដែលត្រឹមត្រូវនិងគ្រប់គ្រាន់នោះទេ ។ អ្នកប្រាជ្ញល្បីៗជាច្រើនរូបលើពិភពលោក បានកំណត់នូវនិយមន័យនៃការគ្រប់គ្រងខុសៗគ្នាទៅតាមបរិបទសង្គម ទ្រឹស្តីចិត្តវិទ្យា និងទស្សនៈវិជ្ជារៀងៗខ្លួន ។ ប្រសិនបើអ្នកស្វែងរកមើលវចនានុក្រម **និយមន័យនៃការគ្រប់គ្រង** ក្នុងចំណោមឧទាហរណ៍ជាច្រើនខាងក្រោមនេះ អ្នកនឹងរកឃើញគន្លឹះឆ្ពោះទៅរកនិយមន័យពិតប្រាកដនៃការគ្រប់គ្រង ។

***"ការគ្រប់គ្រង" (មកពីពាក្យ ménagement របស់បារាំងសម័យបុរាណបកប្រែថា "សិល្បៈនៃការដឹកនាំ", បានមកពីឡាតាំង Manu agere គឺ"ដឹកនាំដោយដៃ") ដែលមានបុគ្គលិកលក្ខណៈជាដំណើរការនៃការដឹកនាំ និងតម្រង់ទិសគ្រប់ផ្នែកទាំងអស់ ឬផ្នែកមួយនៃអង្គភាព ដែលភាគច្រើនជាការគ្រប់គ្រងអាជីវកម្មមួយតាមរយៈការដាក់ពង្រាយ និងពង្រឹងធនធាន (មនុស្ស, ហិរញ្ញវត្ថុ, សម្ភារៈ, បញ្ញា ឬអរូបី) ។***

និយមន័យនេះ គួរឱ្យចាប់អារម្មណ៍មែនទែន ដោយសារតែវាមានឫសគល់ចេញមកពី ឃ្លាប្រយោគឡាតាំងមានន័យថា "ដឹកនាំដោយដៃ" ។ ការដឹកនាំដោយដៃបង្កប់អត្ថន័យថាជាការផ្តល់ទិសដៅច្រើនជាងការគ្រាន់តែការផ្តល់ជាការសំណូមពរ ឬការស្នើសុំ ។ ការដឹកនាំដោយដៃនេះផងដែរបញ្ជាក់ថា មនុស្សជាអ្នកដឹកនាំគេត្រូវបានអ្នកនៅក្រោមបង្គាប់គោរពនិងឲ្យតម្លៃ ។ អ្នកដឹកនាំល្អមិនដែលស្នើសុំឬបង្ខំឲ្យកូនចៅធ្វើអ្វីមួយដែលពួកគេគ្មានឆន្ទៈធ្វើវានោះទេ ។

***គឺជាការណែនាំ និងការត្រួតពិនិត្យសកម្មភាពចាំបាច់ដើម្បីប្រតិបត្តិកម្មវិធី ។ ហើយបុគ្គលម្នាក់ៗមានបន្ទុកក្នុងការទទួលខុសត្រូវលើការដឹកនាំកម្មវិធីនោះ ។***

និយមន័យនៃការគ្រប់គ្រងនេះសំដៅទៅលើ "កម្មវិធី"។ នេះបញ្ជាក់ថាសម្រាប់ការគ្រប់គ្រងដើម្បីឲ្យមានប្រសិទ្ធិភាពនោះវាចាំបាច់ត្រូវមានប្រភេទ នៃវិធីសាស្ត្រមួយចំនួន ដែលបានកំណត់ឬប្រព័ន្ធដែលបានដាក់ចេញ ។ ប្រព័ន្ធនេះបានក្លាយទៅជាផែនការ ឯការគ្រប់គ្រងបានក្លាយជាអ្នកចង្អុលបង្ហាញផ្លូវ នៅក្នុងផែនការដែលមាន ។ ប្រសិនបើអ្នកគ្រប់គ្រងមិនមានផែនការឬប្រព័ន្ធទេនោះ ជាលទ្ធផលពួកគេហាក់ដូចជាធ្វើសកម្មភាពអ្វីមួយដែលចៃដន្យ មិនអាចទៅដល់គោលដៅនិងនាំឲ្យមានការខកចិត្ត ។ នេះគឺជាមូលហេតុដែលសៀវភៅណែនាំបុគ្គលិក មានសារៈសំខាន់ណាស់

សម្រាប់ការគ្រប់គ្រងអាជីវកម្ម។ បើគ្មានសៀវភៅណែនាំនិយោជិកទេ អ្នកគ្រប់គ្រងនឹងត្រូវមានបន្ទុកធ្ងន់ជាងនេះ ដើម្បីធ្វើឲ្យមានតុល្យភាព និងភាពត្រឹមត្រូវនៃការប្រព្រឹត្តរបស់បុគ្គលិក ។

*គឺជាដំណើរការរបស់អង្គភាព ដែលរួមបញ្ចូលទាំងផែនការយុទ្ធសាស្ត្រ ការកំណត់គោលបំណង ការគ្រប់គ្រងធនធាន, ដាក់ពង្រាយមនុស្ស និងទ្រព្យសកម្មហិរញ្ញវត្ថុចាំបាច់ដើម្បីសម្រេចបាននូវគោលបំណង រួចធ្វើការវាយតំលៃលទ្ធផល។ ការគ្រប់គ្រងរួមបញ្ចូលទាំងការថតនិងការរក្សាទុកអង្គហេតុ និងព័ត៌មានសម្រាប់ប្រើនៅពេលក្រោយ ឬសម្រាប់ឲ្យបុគ្គលដទៃទៀតនៅក្នុងអង្គភាពប្រើប្រាស់។ មុខងារនៃការគ្រប់គ្រងមិនត្រូវបានកំណត់តែទៅលើអ្នកគ្រប់គ្រង និងអ្នកចាត់ការទូទៅប៉ុណ្ណោះទេ តែសមាជិកនៃអង្គភាពទាំងអស់មានការគ្រប់គ្រង និងការធ្វើរបាយការណ៍ទៅតាមមុខងារមួយចំនួនដែលជាផ្នែកនៃការងាររបស់ពួកគេ ។*

និយមន័យនៃការគ្រប់គ្រងនេះ គឺជាការបន្ថែមកាន់តែស៊ីជម្រៅ និងជាក់លាក់សម្រាប់ការគ្រប់គ្រងអាជីវកម្ម ។ ចូរកត់សំគាល់ថា វាមានសកម្មភាពចម្បងៗចំនួនបីគឺ ទីមួយ ការគ្រប់គ្រងបង្កើតផែនការមួយ ។ ផែនការនេះបានក្លាយជាផែនទីសម្រាប់បង្ហាញផ្លូវនូវអ្វីដែលនឹងត្រូវធ្វើ និងអ្វីដែលបានធ្វើ។ ទីពីរគឺការគ្រប់គ្រងចាត់ចែងធនធានដើម្បីអនុវត្តបំពេញផែនការ។ទីបីជាការគ្រប់គ្រងវាស់លទ្ធផល ដើម្បីមើលពីការប្រៀបធៀបលទ្ធផលចុងបញ្ចប់ធៀបជាមួយនឹងអ្វី ដែលត្រូវបានមើលឃើញពីដំបូង។ ភាពបរាជ័យនៃការគ្រប់គ្រងភាគច្រើនកើតឡើង ដោយសារតែមិនមានសមត្ថភាពគ្រប់គ្រាន់ នៅក្នុងការតាមដានតំបន់មួយក្នុងចំណោមតំបន់ទាំងបីខាងលើនេះ ។

*គឺជាសកម្មភាពនៃការសម្រេចបានលទ្ធផលអ្វីមួយ ដែលមានការជំរុញពីធនធានមនុស្សនិងធនធានដទៃផ្សេងទៀត ។*

និយមន័យនៃការគ្រប់គ្រងនេះផ្តោតទៅលើ ប្រភេទនៃការគ្រប់គ្រងមួយដែលជាដំណើរការនៃការបំពេញការងារតាមរយៈការខិតខំ និងលទ្ធភាពធ្វើការងាររបស់អ្នកដទៃ ។ អ្នកគ្រប់គ្រងម្នាក់ដែលមានជំនាញ អាចសម្រេចជោគជ័យបានច្រើនជាងអ្នកគ្រប់គ្រងធម្មតា ដោយពួកគេចេះប្រើប្រាស់មនុស្សបានត្រឹមត្រូវ ជាជាងការធ្វើវាដោយខ្លួនឯង ។

*ជាការប្រើប្រាស់ និងការសម្របសម្រួលធនធានដូចជាមូលធន, រោងចក្រ, សម្ភារៈ និងកម្លាំងពលកម្ម ដើម្បីសម្រេចបាននូវគោលបំណងមួយដែលមានប្រសិទ្ធិភាពជាអតិបរមា។*

និយមន័យនៃការគ្រប់គ្រងនេះ មិនមែនសង្កត់ធ្ងន់ត្រឹមតែទៅលើបុគ្គលម្នាក់នោះទេ ប៉ុន្តែគឺធនធានទាំងមូលដែលចាំបាច់ ដើម្បីអនុវត្តតាមផែនការមួយ ។ សូមសម្គាល់ពីរបៀបដែលវាផ្តោត

ទៅលើប្រសិទ្ធភាព ។ ការគ្រប់គ្រងមិនមែនគ្រាន់តែទទួលបានពីចំណុច ក មួយទៅចំណុច ខ មួយនោះទេ វាត្រូវតែទៅដល់កន្លែងមួយ ដោយជ្រើសរើសផ្លូវដែលល្អបំផុតតាមដែលអាចធ្វើបាន ។

*1. ដំណើរការនៃការសម្រេចបាននូវសកម្មភាពអ្វីមួយឲ្យមានប្រសិទ្ធិភាព តាមរយៈមនុស្សផ្សេងទៀត; 2. ដំណើរការនៃការកំណត់ និងការសម្រេចបាននូវគោលដៅ តាមរយៈការប្រតិបត្តិមុខងារមូលដ្ឋានក្នុងការគ្រប់គ្រងចំនួនប្រាំ: ការធ្វើផែនការ, រៀបចំ, ចាត់ចែងបុគ្គលិក, ដឹកនាំនិងការត្រួតពិនិត្យ ដែលប្រើប្រាស់មនុស្សធនធាន ហិរញ្ញវត្ថុ និងសម្ភារៈ ។*

និយមន័យដំបូង សំដៅពីសភាពពិតដែលថាការគ្រប់គ្រងត្រូវទទួលបានជោគជ័យគ្រប់ជ្រុងជ្រោយតាមរយៈមនុស្សផ្សេងទៀត ។ និយមន័យទីពីរបានបែងចែកចូលទៅក្នុងសមាសភាគគ្រប់គ្រងទាំងប្រាំ។ សមាសភាគទាំងនេះចម្រាញ់ពីគ្រប់ផ្នែកទាំងអស់ នៃសមាសភាគទាំងបី (ផែនការប្រតិបត្តិ និងវិធានការ) ដែលយើងបានសិក្សាខាងលើ ។

*ជាតួនាទីនៃការដឹកនាំ និងការត្រួតពិនិត្យអាជីវកម្ម ។*

នេះជានិយមន័យទូលំទូលាយនៃការគ្រប់គ្រង ដែលមិនបានចាត់ទុកការគ្រប់គ្រងជាអ្វីមួយដែលស្ថិតនៅខាងក្រៅនៃអាជីវកម្ម[៣] ។

- **មុខងារនៃការគ្រប់គ្រង**

ក.ការធ្វើផែនការ: សំដៅទៅដល់ការកំណត់នូវគោលបំណងមួយដែលសមរម្យច្បាស់លាស់ រួចទើបជ្រើសរើសមធ្យោបាយ ឬយុទ្ធសាស្ត្រដែលល្អបំផុតក្នុងការសម្រេច និងទទួលបានជោគជ័យ ។ លើសពីនេះទៅទៀត ការធ្វើផែនការ ក៏ទាក់ទងនឹងយុទ្ធសាស្ត្រធ្វើផែនការអាជីវកម្ម ការព្យាករណ៍ និងកត្តាសំខាន់ៗក្នុងការធ្វើអាជីវកម្ម ។

ខ.ការចាត់តាំង : ទាក់ទងនឹងការបង្កើតនូវភារកិច្ច និងអំណាចដែលអនុញ្ញាតអោយមនុស្សធ្វើការជាមួយគ្នា ដើម្បីអោយសម្រេចបានគោលបំណងរួមរបស់អង្គភាព ។ ហើយនៅក្នុងការចាត់តាំងនោះរួមមានដូចជា សមាសធាតុនៃរចនាសម្ព័ន្ធក្នុងការចាត់តាំង រចនាសម្ព័ន្ធមុខងារ ។

គ.ការដឹកនាំ : ផ្តោតទៅលើការណែនាំ ការបង្រៀន ការលើកទឹកចិត្ត ដោយធ្វើយ៉ាងណាអោយសម្រេចគោលបំណងរបស់អង្គភាព ។ នៅក្នុងការដឹកនាំ ក៏បានរួមបញ្ចូល អ្នកដឹកនាំ អ្នកគ្រប់គ្រង ហើយជាពិសេសនោះគឺ គុណភាពនៃភាពអ្នកដឹកនាំ។

[៣] គេហទំព័រ: http://www.leadership501.com/definition-of-management/21/

ឃ.ការត្រួតពិនិត្យ : ទាក់ទិននឹងការបង្កើតនូវការត្រួតពិនិត្យដែលត្រឹមត្រូវ និងបង្កើតប្រព័ន្ធត្រួតពិនិត្យដើម្បីវាយតម្លៃអោយដឹងថាសម្រេចបានគោលបំណងដល់កម្រិតណា។ ជាក់ស្តែងនៅក្នុងការត្រួតពិនិត្យ គឺពាក់ព័ន្ធនឹងការវាស់ ឬប៉ាន់ស្មានលើការអនុវត្តជាក់ស្តែង នូវសកម្មភាពគ្រប់គ្រង ការត្រួតពិនិត្យលើបរិមាណ គុណភាព ពេលវេលា និងការចំណាយ។

**រូបភាពទី១៖ មុខងារនៃការគ្រប់គ្រង**




### ១.១.២ សហភាពប្រៃសណីយ៍សកល (UPU)

សហភាពប្រៃសណីយ៍សកល គឺជាភ្នាក់ងារឯកទេសមួយ នៃអង្គការសហប្រជាជាតិដែលសហប្រតិបត្តិការណ៍គោលនយោបាយប្រៃសណីយ៍ ក្នុងចំនោមប្រជាជាតិជាសមាជិក និងគ្រប់គ្រងប្រព័ន្ធប្រៃសណីយ៍ពាសពេញពិភពលោក ។ សហភាពប្រៃសណីយ៍មកពី ពាក្យពេញថា Universal Postal Union ដោយហៅកាត់ថា UPU និងបានបង្កើតឡើងនៅឆ្នាំ១៨៧៤ ។ ភាសាបារាំងជាភាសាផ្លូវការដំបូងបង្អស់របស់សហភាពប្រៃសណីយ៍សកល UPU ។ បន្ទាប់មកភាសាអង់គ្លេសត្រូវបានដាក់បញ្ចូលជាភាសាផ្លូវការនៅឆ្នាំ១៩៩៤ ។ បច្ចុប្បន្នភាសាផ្លូវការរបស់UPUមានចំនួន០៦ គឺ ភាសាបារាំង អង់គ្លេស អារ៉ាប់ ចិន រុស្ស៊ី និងអេស្ប៉ាញ ។

ទីស្នាក់ការកណ្តាលរបស់ UPU ស្ថិតនៅទីក្រុងBern ប្រទេសNewZealandសព្វថ្ងៃមានសមាជិកជាង១៩២ប្រទេស រួមទាំងកម្ពុជាផងដែរ[៤]។

សហភាពប្រៃសណីយ៍សកល (UPU) បង្កើតឡើងក្នុងគោលបំណង៖

- បង្កើតកិច្ចប្រតិបត្តិការណ៍គ្នាទៅវិញទៅមក រវាងបណ្តាប្រទេសជាសមាជិក ក្នុងការធ្វើការដឹកជញ្ជូន និងចែកចាយបញ្ញើ
- ទប់ស្កាត់ការចរាចរ និងចែកចាយគ្រឿងញៀន ឬអាវុធជាតិផ្ទុះ
- បង្កើតទំនាក់ទំនង ក្នុងការជួយសម្រួលដល់សេវាកម្មអតិថិជនទាំងអស់ ដែលស្ថិតក្នុងជាប្រទេសជាសមាជិក UPU
- ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងតាមដានទិន្នន័យ ទាក់ទងនឹងការដឹកជញ្ជូន និងចែកចាយបញ្ញើនៅទូទាំងពិភពលោក ។

### ១.១.៣ បញ្ញើប្រៃសណីយ៍នាំចេញ

បញ្ញើ (Mail) និង ប្រៃសណីយ៍(Post) គឺជាប្រព័ន្ធនៃការដឹកជញ្ជូន ឯកសារនិងកញ្ចប់តូចៗដទៃទៀត អាចជាប៉ុស្តិ៍កាត លិខិត និងកញ្ចប់ធំៗ ។ សេវាកម្មប្រៃសណីយ៍អាចជាសេវាកម្មឯកជន ឬសេវាកម្មសាធារណៈ បើទោះបីជារដ្ឋាភិបាលប្រទេសជាច្រើនមានការរឹតបន្តឹងទៅលើ សេវាកម្មឯកជនក៏ដោយ ។ ពាក្យ Mail មកពីពាក្យអង់គ្លេសសម័យកណ្តាល Male ដែលសំដៅទៅលើកាបូប ឬកញ្ចប់ធ្វើដំណើរ ។ រហូតមកដល់សតវត្សន៍ទី១៧ ក៏មានការបកប្រែខុសប្លែកថា ប្រអប់ធំ (Malle) ក្នុងភាសាបារាំង ។ នៅឆ្នាំ១៦៥៤ ពាក្យបញ្ញើ (Mail) ត្រូវបានគេសំដៅទៅលើកញ្ចប់ឬកាបូបដែលពេញទៅដោយសំបុត្រឬលិខិត ។ មកដល់សតវត្សន៍ទី១៩ ជនជាតិអង់គ្លេសចាត់ថ្នាក់ពាក្យបញ្ញើ (Mail) នេះថាជាលិខិតផ្ញើពីក្រៅប្រទេស និងពាក្យប្រៃសណីយ៍ (Post) ថាជាលិខិតសម្រាប់ដឹកជញ្ជូនក្នុងតំបន់ ។ ចាប់តាំងពីពាក់កណ្តាលសតវត្សន៍ទី១៩ ប្រព័ន្ធប្រៃសណីយ៍ជាតិបានបង្កើតជារដ្ឋាភិបាលផ្តាច់មុខលើការនាំចេញ និងដឹកជញ្ជូនបញ្ញើ ដោយយកកម្រៃជាមុនទៅលើការផ្ញើ ។ ម្យ៉ាងទៀត ភស្តុតាងនៃការទូទាត់នេះត្រូវបានកំណត់ ជាទំរង់តែមប្រ៍[៥] ។ បច្ចុប្បន្ន បញ្ញើប្រៃសណីយ៍ជាបញ្ញើអន្តរវត្ថុគ្រប់ប្រភេទ ដែលអាចផ្ញើទាំងក្នុងស្រុក និងក្រៅស្រុក ។

បញ្ញើប្រៃសណីយ៍នាំចេញ គឺជាការផ្ញើចេញជាទំនិញ ឬកញ្ចប់ទំនិញដែលមានលក្ខណៈជាសំបុត្រ ឯកសារលិខិត សំភារៈប្រើប្រាស់ប្រចាំថ្ងៃ ម្ហូបអាហារ និងរបស់របរផ្សេងៗទៀតនាំចេញទៅ

[៤] គេហទំព័រ: Universal Postal Union

[៥] គេហទំព័រ: https://en.wikipedia.org/wiki/Mail

ក្រៅប្រទេសនានាទូទាំងពិភពលោក ។ បញ្ញើប្រៃសណីយ៍ដែលបានផ្ញើចេញត្រូវបានគ្រប់គ្រងចាត់ចែង និងដឹកជញ្ជូននៅគ្រប់ទីកន្លែងទាំងអស់នៅលើសកលលោក ។ ជាក់ស្តែងរាល់បណ្តាបញ្ញើដែលផ្ញើទៅអន្តរជាតិ ចំពោះការទទួលបញ្ញើប្រៃសណីយ៍ គឺគ្មានសាខាប្រៃសណីយ៍រាជធានីខេត្តណាមួយនៅក្នុងប្រទេស ឬប្រទេសជាសមាជិកសហភាពប្រៃសណីយ៍សកល ដែលមិនព្រមទទួលបញ្ញើ តួយ៉ាងដូចជាការចែកចាយបញ្ញើទៅអោយអ្នកទទួល ទោះបីជាអ្នកផ្ញើនោះ មានជាតិសាសន៍ សញ្ជាតិអ្វីក៏ដោយ អោយតែពួកគេបានរស់នៅលើទឹកដី ដែលអ្នកផ្ញើស្នាក់នៅ ឬស្នាក់នៅបណ្តោះអាសន្ន ។ ហើយលើកលែងតែអន្តរវត្ថុនោះមានចែងក្នុងច្បាប់ និងបទបញ្ញត្តិនៃប្រទេសទទួលហាមឃាត់តែប៉ុណ្ណោះ ។

### ១.១.៤ ពាក្យគន្លឹះក្នុងវិស័យប្រៃសណីយ៍

**កញ្ចប់តូច** ជាកញ្ចប់ឬប្រអប់ផ្ញើវត្ថុផ្សេងៗ ដោយយកមកបិត និងខ្ចប់អោយជិតចំពោះមុខមន្ត្រីសមត្ថកិច្ច ។ លិខិតមានទំនាក់ទំនងជាបុគ្គលដែលដាក់នៅក្នុងកញ្ចប់តូចត្រូវគិតតម្លៃសេវាដូចការផ្ញើសំបុត្រ ។

**កត្តាប្រៃសណីយ៍** ជាភ្នាក់ងារចែកចាយបញ្ញើប្រៃសណីយ៍ លិខិតអញ្ជើញឲ្យមកបើកបញ្ញើដល់លំនៅដ្ឋានអ្នកត្រូវទទួល ។

**កត្តាប្រៃសណីយ៍ជនបទ** ភាគច្រើនគឺជាស្មៀន ឬជំទប់នៅតាមភូមិឃុំដាច់ស្រយាល សំរាប់ជួលមុខអោយប្រៃសណីយ៍ ក្នុងការបញ្ជូន ឬទទួលបញ្ញើប្រៃសណីយ៍ដើម្បីចែកជូនដល់អតិថិជន ។

**ការខូចខាតបញ្ញើបង្ករឡើងដោយធម្មជាតិនៃបញ្ញើ** ជាប្រភេទបញ្ញើដែលពុំអាចរក្សាទុកបានយូរ ឬក៏ងាយប្រែប្រួលពីរូបភាពដើមបើសិនផ្លាស់ប្តូរទីកន្លែង រឺ អាកាសធាតុ រឺ ការដឹកជញ្ជូនបណ្តាលអោយខូចខាតបញ្ញើ ។

**ការទទួលបញ្ញើផ្ទាល់ដៃ** ជាប្រភេទបញ្ញើដែលអតិថិជន ត្រូវទទួលដោយផ្ទាល់ដៃ ឬក៏នៅគេហដ្ឋានរបស់ខ្លួន ។ បញ្ញើនេះត្រូវប្រើជាមួយសេវាអនុសិដ្ឋ ។

**ការបញ្ជូនតាមយន្តហោះ** ជាប្រភេទសេវាពិសេសអនុលោមទៅតាមតំរូវការរបស់អតិថិជនអោយបញ្ជូនបញ្ញើរបស់ខ្លួនតាមយន្តហោះ ។ នៅលើបញ្ញើមានវាយត្រារឺបិទស្លាក BY AIRMAIL រឺ BY AIR រឺ AIR MAIL រឺ PAR AVION ។

**ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល** ក្រដាសបោះពុម្ពពណ៌ផ្កាឈូក បោះជា AR បិទពីក្រោយសំបុត្រ ពេលចែកអ្នកទទួលត្រូវចុះហត្ថលេខាទទួល ហើយប្រៃសណីយ៍មានភារកិច្ចបញ្ជូនទៅម្ចាស់ដោយពុំយកអាករបន្ថែមឡើយ ។ សម្រាប់ការផ្តល់ដំណឹងនេះ ប្រើបានតែចំពោះបញ្ញើមួយ

ចំនួនតែប៉ុណ្ណោះតួយ៉ាងដូចជា បញ្ញើអនុសិទ្ធ ប្រៃសណីយ៍ភ័ណ្ឌ ការផ្ទេរប្រាក់បញ្ញើឆាប់រហ័ស ដោយផ្តល់ដំណឹងទៅអ្នកផ្ញើវិញពីកាលបរិច្ឆេទនៃការចែកបញ្ញើ ឬបើកប្រាក់អោយអ្នកទទួល ។

**ការផ្លាស់ប្តូរបញ្ញើបិទជិត** ការបិទបញ្ញើច្រកបាវបិទជិត ទៅវិញទៅមកដោយមានបំពាក់លេខជើងបញ្ញើ ទំងន់បញ្ញើ និងប្រភេទបញ្ញើត្រឹមត្រូវដើម្បីផ្លាស់ប្តូរជាមួយប្រៃសណីយ៍ដទៃទៀត ។

**ការសុំប្រើប្រាស់អាស័ដ្ឋានប្រអប់ប្រៃសណីយ៍** ជាការសុំប្រើប្រាស់ប្រអប់ប្រៃសណីយ៍ ដែលប្រៃសណីយ៍ កសាងនិងរក្សានៅនឹងកន្លែងរបស់អាជ្ញាធរសំរាប់ដាក់បញ្ញើ។ ប្រអប់ប្រៃសណីយ៍នេះមានលេខរៀង និងលេខកូដរបស់ប្រៃសណីយ៍តាមតំបន់នីមួយៗ ។ អតិថិជនដែលពុំចង់អោយកត្តាប្រៃសណីយ៍យកទៅចែកចាយដល់លំនៅដ្ឋាន ឬ ក៏អតិថិជនពុំមានអាស័យដ្ឋានច្បាស់លាស់ អាចជាវប្រអប់សំបុត្រធ្វើជាអាស័យដ្ឋានរបស់ខ្លួន ដោយប្រើប្រាស់សោរសំរាប់បើកយកបញ្ញើដោយខ្លួនឯង ។

**ការិយាល័យប្តូរបញ្ញើអន្តរជាតិ** ការិយាល័យនេះមានសិទ្ធិបិទ និងប្តូរបញ្ញើជាមួយប្រទេសក្រៅ ។ ប្រទេសកម្ពុជាមានការិយាល័យប្តូរបញ្ញើអន្តរជាតិតែ ០១ គឺ PHNOM PENH ។ ប្រទេសធំៗមានការិយាល័យប្តូរបញ្ញើច្រើន ដូចជា USA មានការិយាល័យប្តូរបញ្ញើ : SEA, SANFRANCISCO, HONOLULU ។ល។

**កលិកប័ត្រ** ជាបណ្តាលសារពត៌មាន ទស្សនាវដ្តី ឯកសារបោះពុម្ពគ្មានលក្ខណៈពត៌មានបុគ្គល គ្រាន់តែជាការផ្សព្វផ្សាយ ផ្ញើជាចំហរមានទំងន់ជាអតិបរិមា ៥គក្រ ប្រសិនបើជាសៀវភៅ ។

**ចរន្តការប្រៃសណីយ៍អន្តរជាតិ** គឺជាការងាររបស់ប្រៃសណីយ៍នៃប្រទេសនីមួយៗដែលកំពុងអនុវត្តចាប់តាំងពីបែបបទនៃការទទួល ហើយត្រូវមានទំនាក់ទំនងជាមួយប្រទេសដទៃអោយប្រព្រឹត្តទៅជាធម្មតាពុំមានរអាក់រអួល ។

**ជើងបញ្ញើប្រៃសណីយ៍** ដើម្បីចំណាំ ឬងាយស្រួលក្នុងការងារក៏ដូចជាតាមដានការបាត់បង់ ឬយឺតយាវបញ្ញើ ។ ឧទាហរណ៍ : ភ្នំពេញ – ប៉ារីសមាន៤ជើងក្នុង ០១ សប្តាហ៍ហើយជើងនីមួយៗមានពាក់លេខនិងកាលបរិច្ឆេទបញ្ញើប្រៃសណីយ៍ ។

**ជើងបញ្ញើឆ្លងកាត់ដោយចំហ** ការប្តូរបញ្ញើប្រៃសណីយ៍ទៅគ្រប់ប្រទេសលើសកលលោក ។ ការវិចខ្ចប់ច្រកបាវបញ្ញើប្រភេទនេះគឺធ្វើតាមបច្ចេកទេស២បែប :

1- បើបរិមាណបញ្ញើច្រើនទៅមក ។ យើងជូនដំណឹងគ្នាទៅវិញទៅមកដើម្បីរៀបចំបិទបញ្ញើដោយបិទជិតទៅលើ Depeche close ។

2- បើបញ្ញើមានបរិមាណតិចតួច យើងចង់ជាបាច់ ច្រកជាមួយបាវ ប្រទេសផ្សេងៗដែលនៅជិតហៅថាបញ្ញើចំហ ។

**ជើងបញ្ញើផ្ទៃរាប** បញ្ញើទទួល បញ្ជូនតាមរថយន្ត រថភ្លើង ឬនាវា ។

**ជើងបញ្ញើផ្ទៃរាបបញ្ជូនតាមយន្តហោះ** គឺជាបញ្ញើទទួល-បញ្ជូន-ឆ្លងកាត់តាមយន្តហោះ ។

**ជើងបញ្ញើអាកាស** បញ្ញើបញ្ជូន ទទួលគ្រប់ទិសដៅតាមជើងយន្តហោះ ។

**តម្លៃដឹកជញ្ជូនបញ្ញើអនុគ្រោះ** គឺជាការកំណត់តម្លៃដឹកជញ្ជូនបញ្ញើប្រៃសណីយ៍រវាងសហភាពប្រៃសណីយ៍សកល និងក្រុមហ៊ុនអាកាសចរណ៍ស៊ីវិលអន្តរជាតិមានតម្លៃ 0.439DTS/T/Km អោយបណ្តាក្រុមហ៊ុនយន្តហោះគ្រប់ប្រទេសជាសមាជិកនៃអង្គការនេះអនុវត្ត ។ តម្លៃនេះបើប្រៀបធៀបនឹងការដឹកជញ្ជូនធម្មតានេះ មានភាពអនុគ្រោះច្រើន ។

**តម្លៃតែមប្រើម៉ាស៊ីន** ជាម៉ាស៊ីនសំរាប់បោះតម្លៃតែមប្រ៊ើលើស្រោមសំបុត្រ ឬសន្លឹកក្រដាសពិសេសរបស់ប្រៃសណីយ៍សំរាប់បិទលើបញ្ញើគ្រប់ប្រភេទដោយពុំបាច់ប្រើតែមប្រ៊ើប្រៃសណីយ៍ឡើយ ។

**តម្លៃសេវាប្រៃសណីយ៍** គឺជាតារាងតម្លៃដែលបានសំរេចដោយ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដាក់ជូនអតិថិជនប្រើប្រាស់សេវាប្រៃសណីយ៍ ។ ចំពោះតម្លៃផ្ញើទៅអន្តរជាតិត្រូវបានរៀបចំដោយអនុលោម ទៅតាមអនុសញ្ញាសហភាពប្រៃសណីយ៍សកល និងតម្លៃដឹកជញ្ជូនរបស់ក្រុមហ៊ុនយន្តហោះដែលជាសមាជិករបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ។

**តម្លៃសេវាលើអាណត្តិប្រៃសណីយ៍** គឺកំរៃជើងសារ ដែលទទួលបានពីការផ្ទេរប្រាក់របស់អតិថិជនដោយគិតទៅតាមភាគរយនៃចំនួនប្រាក់បញ្ញើ ។

**តម្លៃសេវាបន្ទាប់បន្សំ** គឺជាតម្លៃដែលត្រូវគិតបន្ថែមលើតម្លៃសេវាប្រៃសណីយ៍ អាស្រ័យលើការស្នើសុំរបស់អ្នកប្រើប្រាស់ ដែលរួមមានតម្លៃតាមយន្តហោះ អនុសិដ្ឋ ប្រកាសតម្លៃរហ័ស ។ល ។

**តែមប្រ៊ើប្រៃសណីយ៍** ក្រដាសបោះពុម្ពតូចៗមានធ្មេញ ឬអត់ធ្មេញ ហើយមានរូបភាព និងមានដាក់តម្លៃពន្ធអាករប្រៃសណីយ៍ ។ មានតែប្រៃសណីយ៍ទេ ដែលមានសិទ្ធិបោះពុម្ពតែមប្រ៊ើប្រៃសណីយ៍ ។

**ត្រាថ្ងៃខែប្រៃសណីយ៍** គឺជាត្រាសំគាល់ឈ្មោះប្រៃសណីយ៍ ដែលមានឈ្មោះការិយាល័យកាលបរិច្ឆេទសំរាប់ប្រថាប់បញ្ញើមកដល់ ចេញ ឬសំលាប់តែមប្រ៊ើ ។

**ត្រាអាចម៍ល័ខ** ជាត្រារាងមូលមានអក្សរ និងលេខសំគាល់ការិយាល័យប្តូរបញ្ញើអន្តរជាតិនៃប្រទេសនីមួយៗ សំរាប់វាយលើអាចម៍ល័ខដែលបានស្លអោយរលាយភ្ជិតលើខ្សែចំណងការពារការលួចកាត់ឬបើកបាវ កញ្ចប់ហិបទំនិញ ។

**ធនប័ត្រ** គឺជាក្រដាសប្រើសំរាប់ចាយជំនួសប្រាក់ ដែលចេញដោយធនាគាររួមមានដូចជាមូលទានប័ត្រ Bank Draff ។

**បញ្ញើ** គឺបណ្តាសំភារៈទាំងឡាយដែលផ្ញើតាមប្រៃសណីយ៍ ។

**បញ្ញើខុសទិសដៅ** ជាបញ្ញើដែលវង្វេង ឬផ្ញើច្រឡំទិសដៅដែលត្រូវបញ្ជូនទៅដោយសារកំហុសរបស់អ្នកបែងចែក។ បញ្ញើនេះមានច្រើនលក្ខណៈជួនកាលអាចខុសទិសដៅដោយក្រុមហ៊ុនដឹកជញ្ជូន ។

**បញ្ញើងាយបែកបាក់** ជាសេវាពិសេសតាមសំណូមពររបស់អ្នកផ្ញើ ជាបញ្ញើដែលងាយបែកបាក់ ។ នៅលើកញ្ចប់ ឬកេះទំនិញមានរូបកែវនិងអក្សរ (Fragile) ។

**បញ្ញើច្រងេងច្រងាង** ជាប្រភេទប្រៃសណីយ៍ភ័ណ្ឌ ដែលមានខ្នាតមិនប្រក្រតី ពុំអាចបត់ឬកាច់បំបាក់អោយត្រឹមត្រូវតាមទំហំកំណត់និងពុំអាចដាក់ក្នុងហិបឬកេះទំនិញ ឬច្រកចូលក្នុងបាវបានឡើយ។ បញ្ញើប្រភេទនេះត្រូវរៀបចំដោយឡែកពីបញ្ញើធម្មតា ហើយអ្នកផ្ញើត្រូវថែមតម្លៃលើសពីបញ្ញើធម្មតាដែរ ។

**បញ្ញើបង់តម្លៃសេវាជាមុន** ជាប្រភេទបញ្ញើដែលអ្នកផ្ញើសុំបង់ប្រាក់កក់ទុកជាមុនរ ឬក៏សុំផ្ញើជារបៀបកំណត់តម្លៃសេវា ។ បញ្ញើប្រភេទនេះពុំចាំបាច់បិទតែមប្រៃប្រៃសណីយ៍ទេ ដោយគ្រាន់តែវាយត្រា TP រឺ PP ជាការស្រេច ។

**បញ្ញើផ្សាយពាណិជ្ជកម្ម** គឺការផ្សាយពាណិជ្ជកម្ម តាមរយៈប្រៃសណីយ៍ដោយឆ្លងកាត់ការចែកចាយខិតប័ណ្ណផ្សព្វផ្សាយ ឬឆ្លងកាត់តាមរយៈឧបករណ៍ព័ត៌មានវិទ្យា ។

**បញ្ញើមានប្រកាសតម្លៃ** ជាប្រភេទសេវាបន្ថែមលើបណ្តាសេវាពិសេសផ្សេងៗក្នុងការធានាអន្តរវត្ថុឬកញ្ចប់បញ្ញើ ។ អ្នកផ្ញើត្រូវប្រកាសពីតម្លៃអោយបានត្រឹមត្រូវ និងត្រឹមកំរិតមួយដែលប្រៃសណីយ៍ផ្ញើ និងប្រៃសណីយ៍ទទួលបានឯកភាពគ្នា ។ អ្នកផ្ញើត្រូវបង់ភាគរយអោយប្រៃសណីយ៍ទៅតាមតម្លៃដែលបានកំណត់ និងទៅតាមតម្លៃដែលខ្លួនបានប្រកាស ។ ប្រៃសណីយ៍ទទួលសងគ្រប់តម្លៃដែលបានប្រកាសនៅពេលបាត់បង់ ។

**បញ្ញើបន្ត** គឺជាបញ្ញើផ្ញើឆ្លងកាត់ការិយាល័យមួយសំរាប់បញ្ជូនបន្ត ទៅការិយាល័យប្រៃសណីយ៍ទទួលចែក ។

**បញ្ញើសងប្រាក់ពេលទទួល** ប្រការនេះទាល់តែមានការព្រមព្រៀងគ្នារវាង ប្រៃសណីយ៍នៃបណ្តាប្រទេស ដោយកំណត់អោយបានតម្លៃដែលត្រូវទូទាត់ ។ អ្នកទទួលបញ្ញើអាចស្នើរសុំទិញ

ទំនិញពី ប្រទេសដទៃដោយបានបង់ប្រាក់របស់ខ្លួននៅពេលបានទទួលទំនិញនោះ ហើយចាត់ចែងទារប្រាក់ដោយប្រៃសណីយ៍ ។

**បញ្ញើសំណល់** ជាបញ្ញើដែលពុំអាចចែកចាយដល់អ្នកទទួល និងគ្មានអាស័យដ្ឋានអ្នកផ្ញើ ឬគ្មានឈ្មោះប្រទេសដើម ឬបញ្ញើទាំងនេះ អ្នកផ្ញើគេបានប្រាប់អោយបោះបង់ចោលក្នុងករណីចែកមិនបាន ត្រូវបានចាត់ទុកថាជាបញ្ញើសំណល់ ។ បញ្ញើសំណល់នេះត្រូវបានគណកម្មការរួមមានប្រៃសណីយ៍គយធ្វើការពិនិត្យពិច័យទៅលើសំភារៈនៅខាងក្នុងដែលប្រភេទខ្លះត្រូវដុតចោល (ទំនិញហួសគុណភាព សំបុត្រ ឯកសារ ផ្សេងៗ) និងប្រភេទខ្លះដែលនៅមានគុណភាពត្រូវឡាយឡុងយកថវិកាចូលរដ្ឋ ឬក៏ធ្វើជា អំណោយជូនកុមារកំព្រា ។

**បញ្ញើស្ថាប័នរដ្ឋនិងបញ្ញើការទូត** គឺមាននូវបញ្ញើរបស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ស្ថាប័នតុលាការ និងក្រសួងការបរទេស ដែលអាចផ្ញើសុំរៀបចំជាបញ្ញើដោយឡែកពីបញ្ញើប្រៃសណីយ៍របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍មានភារកិច្ចរៀបចំផ្លូវប្រៃសណីយ៍ជូន ប៉ុន្តែក្រសួងសាមីពុំអាចធ្វើអាជីវកម្មក្នុងលក្ខណៈឯកជនបានក្រៅពីបំរើក្នុងវិស័យរបស់ស្ថាប័នខ្លួន ។ ចំពោះក្រសួង និងស្ថាប័នផ្សេងពីនេះត្រូវប្រើប្រាស់ តាមរយៈប្រៃសណីយ៍ធម្មតាវិញ ។

**បញ្ញើរហ័ស** ជាប្រភេទសេវាពិសេសទៅតាមសំណូមពររបស់អ្នកផ្ញើឬអ្នកទទួល អោយបញ្ជូនឬចែកចាយបញ្ញើជាប្រញាប់ ។ បញ្ញើបញ្ជូនតាមរយៈជើងបញ្ញើធម្មតាហើយប្រសិទ្ធិនៃការ ចែកមានតែមួយដងប៉ុណ្ណោះ ។

**បញ្ញើរួចតម្លៃសេវា** គឺការកំណត់ជារួមរបស់សហភាពប្រៃសណីយ៍មិនអាចគិតតម្លៃសេវា និងមិនអោយមានការបែងចែកតម្លៃពីប្រទេសមួយទៅប្រទេសមួយនូវបញ្ញើដូចខាងក្រោមៈ

១- ការផ្ញើទំនាក់ទំនងរវាងប្រៃសណីយ៍និងប្រៃសណីយ៍ពីប្រទេសមួយទៅប្រទេសមួយឬហៅបញ្ញើរបស់ប្រៃសណីយ៍។

២- បញ្ញើផ្ញើទៅអ្នកទោសក្នុងសឹកសង្គ្រាម ឬដោយអ្នកនោះ ឬតំណាង ផ្ញើតាមរយៈប្រៃសណីយ៍ ត្រូវបានលើកលែងតែតម្លៃសេវាប្រៃសណីយ៍ប៉ុណ្ណោះ។

៣- សំភារៈសិក្សាសំរាប់មនុស្សខ្វាក់ ត្រូវបានលើលែងតម្លៃសេវាប្រៃសណីយ៍។ តម្លៃបន្ទាប់បន្សំដទៃទៀតរួមទាំងការដឹកជញ្ជូនតាមយន្តហោះនៅគិតដដែល។

**បញ្ញើសំបុត្រប្រៃសណីយ៍** មាន ៥ ប្រភេទៈ

១- សំបុត្រ

២- ប្រៃសណីយ៍ប័ត្រ

៣- កាលិកប័ត្រ

៤- កញ្ចប់តូច

៥- សំភារៈសិក្សាមនុស្សខ្វាក់។

**បញ្ញើអនុសិដ្ឋ** ជាប្រភេទសេវាពិសេសដែលមានការកត់ត្រាក្នុងពេលទទួល ផ្ញើ បញ្ជូន និង ចែកចាយអោយអ្នកទទួលបញ្ញើ ដោយមានកត់ត្រាលេខអត្តសញ្ញាណប័ណ្ណផង។ ប្រៃសណីយ៍ ទទួលខុសត្រូវលើការបាត់បង់បញ្ញើដោយមានសំណង $៤៥ ចំពោះអនុសិដ្ឋអន្តរជាតិនិងចំនួន ៣០.០០០៛ ចំពោះអនុសិដ្ឋក្នុងប្រទេស។

**បញ្ញើប្រកាសតម្លៃ** បណ្តាប្រភេទបញ្ញើដែលបានប្រកាសតម្លៃជាក់ស្តែង រាល់សំភារៈដែល បានផ្ញើជូនដល់ភ្នាក់ងារប្រៃសណីយ៍។ ការយកពន្ធអាករ បើប្រកាសច្រើន យកពន្ធច្រើន ហើយ សំណងពេលបាត់បង់ក៏ច្រើន។

**បណ្តឹងតវ៉ាប្រៃសណីយ៍** ការប្រគល់សិទ្ធិជូនអ្នកប្រើប្រាស់ ប្រៃសណីយ៍ធ្វើការប្តឹង ឬតវ៉ាអំពី ដំណើរការសេវាកម្មពុំបានល្អ ឬធ្វើអោយខូចខាត ប៉ះពាល់ដល់បញ្ញើរបស់ខ្លួន។ បណ្តឹងនេះមាន ប្រសិទ្ធិភាពត្រឹមរយៈពេល ៦ខែ គិតចាប់ពី ពេលផ្ញើបញ្ញើ។

**ប័ណ្ណប្រៃសណីយ៍** ជាប្រភេទប័ណ្ណដែលបោះពុម្ពដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានរូបភាពតែមប្រ៏ស្រាប់សំរាប់អតិថិជនទិញយកទៅ ប្រើប្រាស់ សរសេរពុំចាំបាច់បិទតែមប្រ៏ឬយកមក ផ្ញើផ្ទាល់នៅប្រៃសណីយ៍ដោយគ្រាន់តែ ផ្ញើតាមប្រអប់សំបុត្រប្រៃសណីយ៍សាធារណៈ។

**ប្រអប់ប្រៃសណីយ៍** ប្រអប់សំបុត្រតាំងនៅក្នុងរង្វង់ប្រៃសណីយ៍សំរាប់ដាក់ ជូនអតិថិជនជាវ និងប្រើប្រាស់សំរាប់ការទទួលបញ្ញើប្រៃសណីយ៍គ្រប់ប្រភេទ។ អតិថិជនដែលមានអាស័យដ្ឋានពុំ ទៀងទាត់ ឬក៏អង្គការរដ្ឋនិងឯកជនធំៗច្រើនប្រើប្រាស់ប្រអប់ប្រៃសណីយ៍ ។ អតិថិជនអាចជាវ ប្រអប់ ហើយទទួលប្រអប់ និងកូនសោរដើម្បីចាក់យកដោយខ្លួនឯង ពេលទំនេរ។

ឧ. ប្រអប់ប្រៃសណីយ៍

លោក គ

ប្រអប់សំបុត្រលេខ ១២៣០

ភ្នំពេញ. កម្ពុជា។

**ប្រៃសណីយ៍ប័ត្រ** ជាប្រភេទប័ណ្ណធ្វើពីក្រដាសរឹង មានទំហំជាកំណត់ អាច មាន ឬគ្មានរូបភាព មានកន្លែង សរសេរពត៌មាននៅខាងខ្នង សំរាប់បញ្ជូលពត៌មានខ្លីៗ ពុំចាំបាច់ច្រកចូលក្នុងស្រោមសំបុត្រ។

**ប្រៃសណីយ៍ប្រចាំតំបន់** គឺជាការបង្កើតសហគមន៍ ប្រៃសណីយ៍ទៅតាមតំបន់ភូមិសាស្ត្រ និងមានប្រហាក់ប្រហែល ដើម្បីងាយស្រួលសហប្រតិបត្តិការជាមួយគ្នា។ ប្រៃសណីយ៍ប្រចាំតំបន់នេះក៏ជាសាខារបស់សហភាពប្រៃសណីយ៍សកលដែរ ប៉ុន្តែគេក៏មានលក្ខណៈអនុគ្រោះ និងមានធម្មនុញ្ញភាពដោយឡែក តម្រូវទៅតាមតំបន់របស់គេ។ សព្វថ្ងៃប្រទេសយើងស្ថិតនៅក្នុងប្រៃសណីយ៍ប្រចាំតំបន់ អាស៊ីប៉ាស៊ីភិក ដែលរួមមានសមាជិក ២៨ ប្រទេសដែលហៅកាត់ថា APPU។

**ប្រៃសណីយ៍ភ័ណ្ឌ** កញ្ចប់ធំមានទំងន់ចាប់ពី ២គីឡូក្រាមដល់ ៣០ ឬ ៥០ គីឡូក្រាម។

**ប្រអប់សំបុត្រអចិន្ត្រៃយ៍តាមផ្លូវសាធារណៈ** ប្រអប់សំបុត្រសាធារណៈ តាំងនៅទីប្រជុំជនពណ៌ទឹកក្រូច សំរាប់ទទួលសំបុត្រផ្ញើចេញក្នុង និងក្រៅប្រទេស។ អតិថិជនត្រូវបិទតែមប្រ៍ លើសំបុត្ររបស់ខ្លួនតាមតម្លៃនៃសំបុត្ររួចយកទៅដាក់ក្នុងប្រអប់ សំបុត្រតាមផ្លូវសាធារណៈនោះភ្នាក់ងារប្រៃសណីយ៍មានភារៈកិច្ច ទៅចាក់សោរប្រមូល សំបុត្រពីប្រអប់នោះរាល់ថ្ងៃសំរាប់បញ្ជូនចេញតាមទិសដៅ។

**ប្រអប់សំបុត្រតាមលំនៅដ្ឋាន** ប្រអប់សំបុត្របើកតាំងនៅមុខលំនៅដ្ឋានឯក ជនគឺសំរាប់ដាក់លិខិតផ្សេងៗ អាស័យដ្ឋានទទួល ជាម្ចាស់ផ្ទះ។

**ប្រៃសណីយ៍តម្កល់ទុក** សំរាប់ប្រើប្រាស់ក្នុងការសរសេរអាស័យដ្ឋាន អ្នកទទួលដែលពុំមានអាស័យដ្ឋានពិតប្រាកដឬក៏ពុំរស់នៅស្ថិតស្ថេរ ឬក៏ជាអ្នកទេសចរណ៍ ដែលធ្វើដំណើរទៅលេងម្តងម្កាលនៅកន្លែងណាមួយ។ អ្នកទទួលបញ្ញើគ្រាន់ តែបង្ហាញលិខិតឆ្លងដែន ឬអត្តសញ្ញាប័ណ្ណក្នុងការសុំបើកយកបញ្ញើដែលមានអាស័យដ្ឋានប្រៃសណីយ៍តម្កល់ទុក នៅប្រៃសណីយ៍ណាដែលអាចថែរក្សាបញ្ញើខ្លួន ហើយបង់តម្លៃ ថែរក្សាជូនទៅប្រៃសណីយ៍វិញ។ ឧ.លោក ក Poste restante Phnom Penh Cambodia។

**ប្រាក់និមិត្តរូប** ជាប្រាក់ដែលគ្មានរូប ដែលកំនត់ឡើងដោយមូលនិធិរូបិយ៍វត្ថុអន្តរជាតិសំរាប់ទូទាត់ជាលក្ខណៈអន្តរជាតិ។

**បាវកញ្ចប់ហិបទំនិញបញ្ញើ** គឺជាបាវ កញ្ចប់ ឬហិប ទំនិញដែលដាក់បញ្ញើប្រៃសណីយ៍សំរាប់បញ្ជូនពីទិសដៅមួយទៅទិសដៅមួយទៀត ដោយមានដីកាបញ្ជូន។ បាវ កញ្ចប់ ហិបទំនិញ បញ្ញើនេះត្រូវមានស្លាកទិសដៅ វាយផ្លាកលើសំបកខាងក្រៅនិងភ្ជិតដោយសំណ ឬត្រាអាចម៍លក្ខ័។

**ផ្លាកប្រៃសណីយ៍** ប្រៃសណីយ៍របស់ប្រទេសនីមួយៗត្រូវ មានផ្លាកសំគាល់មួយ និងមានអក្សរឡាតាំងបញ្ជាក់ពីឈ្មោះប្រទេសខ្លួន។

**ផ្លូវប្រៃសណីយ៍** គឺជាការធ្វើអាជីវកម្មប្រៃសណីយ៍ចាប់ពីពេលទទួល បញ្ញើរៀបចំបញ្ជូននិងចែកចាយអោយដល់អ្នកត្រូវទទួល។

**ផលិតផលប្រៃសណីយ៍** ជារូម មានប័ណ្ណដែលមានតែមប្រើស្រាប់ ប្រអប់ដាក់បញ្ញើ ឧបករណ៍សំរាប់ការធ្វើអាជីវកម្ម។

**ភ្នាក់ងារប្រៃសណីយ៍** ជាបុគ្គលដែលបានស្នើសុំមកក្រសួងប្រៃសណីយ៍ និងទូគមនាគមន៍ធ្វើជាតំណាងក្នុងការលក់តេមប្រ៍ឬផលិតផលប្រៃសណីយ៍នៅតាម តំបន់ឬទីប្រជុំជនដែលគ្មានប្រៃសណីយ៍ ឬដែលមានប្រៃសណីយ៍ដែរ ប៉ុន្តែស្នាក់ការលក់ នោះត្រូវស្ថិតនៅចំងាយ៥០០ម៉ែតពីប្រៃសណីយ៍។ អ្នកតំណាងជាភ្នាក់ងារនេះ បានទទួល កំរៃភាគរយពីការលក់តែមប្រ៍ ឬផលិតផលប្រៃសណីយ៍។

**ម៉ាស៊ីនតែមប្រ៍ប្រៃសណីយ៍** ស្រោមសំបុត្រអតិថិជនផ្ញើ ដែលអាករួចស៊កចូលក្នុងម៉ាស៊ីនប្រថាប់ត្រាមានតម្លៃតែមប្រ៍ដែលត្រូវបង់។ ការប្រើតែមប្រ៍ម៉ាស៊ីននេះ ងាយស្រួលឆាប់ តែសំរេចលើសំណូមពរអតិថិជន។

**លិខិតអាអេរ៉ូក្រាម** ក្រដាសបោះពុម្ពមុខក្រោយអាចសរសេរជា សំបុត្រពេលបត់តាមផ្នត់ ចេញជាតួស្រោមសំបុត្រមានបិទតែមប្រ៍អាចសរសេរអាស័យដ្ឋានផ្ញើ ចេញទៅក្នុង និងក្រៅប្រទេសដោយមិនបាច់មិទតែមប្រ៍ តែហាមមិនអោយដាក់អន្តរវត្ថុ។

**រូបធាតុដែលអាចផ្ទុះ** ជារូបភាពដែលហាមឃាត់ក្នុងការផ្ញើតាម ប្រៃសណីយ៍ រួមមានជាតិផ្ទុះគ្រប់ប្រភេទ។

**រូបធាតុងាយឆាបឆេះ** ជារូបធាតុដែលហាមឃាត់ ក្នុងការផ្ញើតាមប្រៃសណីយ៍ដែលងាយឆាបឆេះគ្រប់ប្រភេទ។

**វត្ថុក្នុងបញ្ញើ** រួមមានរបស់របរ ទំនិញ ឯកសារ ដែលអ្នកផ្ញើបានវិចខ្ចប់ច្រកចូលក្នុងសំបុត្រកញ្ចប់ ហិបទំនិញ។

**សហភាពប្រៃសណីយ៍សកស** គឺជាសហគមន៍ប្រៃសណីយ៍ពិភពលោក ដែលបានបង្កើតឡើងនៅទីក្រុងប៊ែន ប្រទេសស្វីសនាឆ្នាំ១៨៧៥។ បច្ចុប្បន្ន UPU មានសមាជិកចំនួន ១៨៩ប្រទេស ហើយមានទីស្នាក់ការធំនៅទីក្រុងប៊ែនប្រទេសស្វីស។ ព្រះរាជាណាចក្រកម្ពុជាយើង បានចូលជាសមាជិក UPU នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ១៩៥១។ បច្ចុប្បន្ន UPU ជាសាខារបស់ONU ។

**សិទ្ធិប្រកែកមិនទទួលបញ្ញើ** ពលរដ្ឋគ្រប់រូបមានសិទ្ធិប្រកែក ពុំទទួលយកបញ្ញើនៅពេលដែលភ្នាក់ងារប្រៃសណីយ៍យកទៅដល់លំនៅដ្ឋាន ឬអញ្ជើញមកបើកនៅបញ្ជរប្រៃសណីយ៍។ ក្នុងករណីនេះបញ្ញើនោះនៅតែជាកម្មសិទ្ធិរបស់អ្នកផ្ញើដដែល ហើយប្រៃសណីយ៍ត្រូវផ្ញើត្រឡប់ទៅអ្នកផ្ញើបញ្ញើវិញ។

**សេវាបញ្ញើប្រៃសណីយ៍** ជាសេវាទទួលផ្ញើបញ្ញើតាមមាន ពីរប្រភេទគឺ បញ្ញើសំបុត្រប្រៃសណីយ៍ និងប្រៃសណីយ៍ភ័ណ្ឌ។

**សេវាបញ្ញើនាប់រហ័ស** ជាសេវាកម្មប្រៃសណីយ៍ទំនើបដែលបានរៀបចំប្រព័ន្ធ ជាលក្ខណៈអន្តរជាតិ។ សេវានេះធានានូវសុវត្ថិភាពរយៈពេលបញ្ជូន ទទួល និងចែកចាយមានការកត់ត្រាតាមរយៈពត៌មានវិទ្យា និងមានអតិភាពជាងបញ្ញើដទៃទៀត។

**សេវាបញ្ជូនប្រាក់តាមប្រៃសណីយ៍** គឺជាការបញ្ជូនប្រាក់តាមផ្លូវប្រៃសណីយ៍ និងទូរគមនាគមន៍ក្នុង និងក្រៅប្រទេស ក្រោមរូបភាពអាណត្តិប្រៃសណីយ៍ ឬអាណត្តិទូរលិក ឬតាមពត៌មានវិទ្យា។

**សេវាបញ្ជូនតាមរូបភាពទូរគមនាគមន៍** ជាសេវាប្រៃសណីយ៍តាមបច្ចេកវិទ្យាទំនើប ដែលបញ្ជូនលិខិត ឬពត៌មានតាមឧបករណ៍អេឡិត្រូនិចឬ អេឡិចត្រូម៉ាញេទិច របស់វិស័យទូរគមនាគមន៍ជារួមមាន តាមទូរសារ ទូរលេខ ទូរពុម្ព លិខិតអេឡិតត្រូនិចឬតាមពត៌មានវិទ្យា។ល។

**សេវាប្រៃសណីយ៍តាមសំណូមពរ** ជាសំណូមពរបន្ថែមលើការបញ្ជូនលិខិត កញ្ចប់ នូវបណ្តាសេវា ពិសេសដូចជា អនុសិដ្ឋ ប្រកាស់តំលៃ ផ្ញើតាមយន្តហោះឬការធានាផ្សេងៗ ក្នុងពេលបញ្ជូនបញ្ញើ។

**សំណាងដែលមានសញ្ញាសំគាល់ប្រៃសណីយ៍** សំរាប់ភ្ជិតខ្សែចំណងកបារ កញ្ចប់ ឬហិបនៃទំនិញ ។ សំណាងនេះត្រូវបានការិយាល័យប្រៃសណីយ៍ប្រើដង្កប់ ដែលជាសញ្ញាសំគាស់របស់ប្រៃសណីយ៍ នីមួយៗច្របាច់អោយចេញស្នាមដើម្បីការពារ ការលួច ឬហែកបារកញ្ចប់ ឬហិបទំនិញ។

**សំបុត្រ** រួមមានលិខិត កញ្ចប់លិខិត បណ្តាលិខិតសរសេរដោយដៃ វាយអង្គុលីលេខ ឬពុម្ពមានលក្ខណៈ ពិសេសលើការទំនាក់ទំណងរវាងបុគ្គល និងបុគ្គល ត្រូវបានបិតជិត ទំងន់អតិបរមា ២គីឡូក្រាមចំពោះរបបក្រៅប្រទេស និង៣គីឡូក្រាមចំពោះរបបក្នុងប្រទេស។

**សំភារៈសំរាប់មនុស្សខ្វាក់** រួមមានថាសចំរៀងខ្សែអាត់ ប្រដាបពិសេស បង្កើតដោយ មន្ទីពិសោធន៍របស់សាលារៀន សំរាប់មនុស្សខ្វាក់និងអក្សរអណ្តែត ត្រូវបានខ្ទប់ បិតជិត។

**ស្លាកទិសដៅ** សំរាប់ប្រើបញ្ជាក់ពីទិសដៅ ដែលបាវកញ្ចប់ឬហិបទំនិញបញ្ជូនទៅ។ នៅលើស្លាកនោះត្រូវសរសេរឬវាយដោយអង្គុលីលេខ ឈ្មោះប្រៃសណីយ៍ផ្ញើទទួល និងទំនាក់ទំនងបញ្ញើ។

**អនុសញ្ញាសហភាពប្រៃសណីយ៍សកល** គឺជាសេចក្តីសំរេចរបស់ប្រទេស ជាសមាជិករបស់សហភាពប្រៃសណីយ៍សកលដែលបានរៀបចំជាសមាជរៀងរាល់៥ឆ្នាំម្តង ។ ប្រទេសនីមួយៗដែលរដ្ឋាភិបាលរបស់ខ្លួនចូលជាសមាជិកនោះត្រូវតែអោយ ប្រៃសណីយ៍របស់ខ្លួនអនុវត្តទៅតាមសេចក្តីសំរេចនោះក្នុងការប្រតិបត្តិសេវាប្រៃសណីយ៍អន្តរជាតិ។

**អាជីវកម្មឯកជនក្នុងវិស័យប្រៃសណីយ៍និងអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍** គឺការស្នើសុំរបស់បុគ្គល ឬក្រុមហ៊ុនដើម្បីធ្វើអាជីវកម្មប្រៃសណីយ៍ ។ ក្រោយពិនិត្យលទ្ធភាពសមស្របក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវចេញអាជ្ញាប័ណ្ណអោយធ្វើអាជីវកម្ម ។ អាជីវកម្មនេះត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួង ។

**អាណត្តិប្រៃសណីយ៍អន្តរជាតិ** ជាការផ្ទេរប្រាក់ពីប្រទេសមួយទៅប្រទេសមួយ ដោយអ្នកផ្ញើប្រើប្រាស់អាណត្តិនេះ ។ អាណត្តិនេះមាន២រូបភាពគឺរូបភាពបញ្ជូនដោយអ្នកផ្ញើមក អ្នកទទួលផ្ទាល់ និងរូបភាពទី២ដោយប្រៃសណីយ៍អ្នកចាត់ចែង ។

**អាណត្តិទូរលិក** គឺជាអាណត្តិបញ្ជូនតាមទូរលេខ ឬតាមបណ្តាញទូរគមនាគមន៍ផ្សេងទៀតសំរាប់ផ្ទេរប្រាក់អោយបានឆាប់រហ័ស។

## ១.២ សញ្ញាណសំខាន់ៗ

### ១.២.១ អាជីវកម្មជាលក្ខណៈអន្តរជាតិ

ប្រព័ន្ធប្រៃសណីយ៍ ជាស្ថាប័នមួយក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល ដែលធ្វើឲ្យមនុស្សគ្រប់ៗរូបអាចផ្ញើលិខិតមួយ សំបុត្រកញ្ចប់មួយ ឬកញ្ចប់មួយទៅកាន់គ្រប់អាស័យដ្ឋានទាំងអស់នៅក្នុងប្រទេសដូចគ្នា ឬនៅក្រៅប្រទេស ដោយរំពឹងថាវានឹងត្រូវបានប្រព្រឹត្តទៅតាមស្តង់ដាដែលបានកំណត់ឡើង ដើម្បីគ្រប់គ្រងបាននូវភាពទៀងទាត់, ល្បឿននៃការផ្ញើ និងសន្តិសុខ ។ សេវាកម្មនេះគឺត្រូវបានបង់ប្រាក់ជាមុន យោងតាមខ្នាតនៃកម្រៃទូទៅ ដោយផ្អែកលើទម្ងន់ និងលក្ខខណ្ឌដែលនៅក្នុងប្រទេសមួយបានកំណត់ទៅលើល្បឿននៃសេវាកម្ម ។ ជាទូទៅការទូទាត់ជាមុនត្រូវបានធ្វើឡើងដោយមធ្យោបាយនៃបិទតែមដោយម៉ាស៊ីនFranking ជាឧបករណ៍សម្រាប់បោះពុម្ពថ្លៃតម្រាយផ្លូវ ហើយការទូទាត់នេះមិនត្រូវបានទាមទារអាស័យដ្ឋាននោះទេ ។

បើទោះបីជាតម្រូវការមូលដ្ឋានសម្រាប់ប្រព័ន្ធប្រៃសណីយ៍ ដើម្បីផ្លាស់ប្តូរទំនាក់ទំនងគ្នាទៅវិញទៅមក មានការចាប់អារម្មណ៍ដោយសង្គមមនុស្សទាំងមូល និងមានការវិវត្តមួយ ដែលតែងតែផ្លាស់ប្តូរទៅតាមសង្គមផ្សេងៗគ្នាជាច្រើនសតវត្សរ៍យ៉ាងណាក៏ដោយ នៅក្នុងលំនាំនៃសេវាកម្មផ្តាច់មុខរបស់រដ្ឋនាពេលបច្ចុប្បន្ននេះគឺមានភាពស្រដៀងគ្នា ។ សព្វថ្ងៃនេះរដ្ឋាភិបាលនៃប្រទេសជាច្រើនដែលប្រើប្រាស់ប្រព័ន្ធប្រៃសណីយ៍ក្នុងការផ្តល់នូវសេវាកម្មរបស់ខ្លួន ដោយយើងមិនឃើញមានការអនុវត្តមុខងារនៃការផ្ញើសំបុត្របែបបុរាណទៀតឡើយ ។ ដើម្បីផ្តល់ការសម្រាប់ការប្រមូលការដឹកជញ្ជូន និងការចែកចាយលិខិតទូទាំងប្រទេសមួយ គឺវាពិតជាចាំបាច់ត្រូវបង្កើតបណ្តាញការិយាល័យប្រៃសណីយ៍បន្ថែម ដើម្បីពង្រីកខ្លួនចូលទៅក្នុងតំបន់ដាច់ស្រយាលនានា ។ បណ្តាញការិយាល័យទាំងនោះធ្វើការ ដោយភ្នាក់ងាររបស់រដ្ឋត្រូវផ្តល់នូវប្រសិទ្ធិភាព ផ្នែកសេវាធនាគារនៅក្នុងតំបន់ក្រីក្រដែលធនាគារពាណិជ្ជមិនបានបង្កើតសាខាឬការិយាល័យរបស់ខ្លួន។ រដ្ឋាភិបាលជាច្រើនក៏បានធានារាល់ការចំណាយ ដូចជាប្រាក់សោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភក្រុមគ្រួសារ តាមរយៈប័ណ្ណទូទាត់ដែលអាចនឹងដកប្រាក់នៅការិយាល័យប្រៃសណីយ៍ ។ នៅប្រទេសខ្លះទៀត ប្រៃសណីយ៍ជាអ្នកប្រមូលពន្ធ ដូចជា ការលក់អាជ្ញាប័ណ្ណ និងចំណូលពន្ធតែមប្រ៍ ។ តាមការពិតទៅ សេវាបន្ទាប់បន្សំផ្សេងៗទៀតក៏ត្រូវបានផ្តល់ជូនតាមរយៈប្រព័ន្ធប្រៃសណីយ៍ដែរ។ ជាក់ស្តែងនៅក្នុងប្រទេសអាហ្វ្រិកនិងប្រទេសអាស៊ីមួយចំនួនប្រព័ន្ធប្រៃសណីយ៍ បានចូលរួមអ្នកជួយចែកចាយថ្នាំការពារជំងឺគ្រុនចាញ់ ។ ខណៈពេលដែលមានភាពខុសគ្នានៃការផ្តល់សេវាប្រៃសណីយ៍បែបនេះហើយ បានឆ្លុះបញ្ចាំងពីការកើនឡើងនៃការប្រើប្រាស់ ប្រព័ន្ធប្រៃសណីយ៍នៅទូទាំងពិភពលោកក្នុងសម័យទំនើបនេះ ដែលមនុស្សពីមុនផ្តោតតែទៅលើការផ្តល់សេវាប្រៃសណីយ៍ ឬសំបុត្របែបប្រពៃណី[៦] ។

### ១.២.២ ទីផ្សារ និងការប្រកួតប្រជែង

គេអាចប្រើពាក្យសាមញ្ញបំផុតថា ទីផ្សារគឺនិយាយអំពីអតិថិជន ដៃគូប្រកួតប្រជែង ទំនិញ និងការចំណាយ ។ ហើយភាពជោគជ័យនៃអាជីវកម្មមួយគឺអាស្រ័យទៅលើព័ត៌មាន និងចំណេះដឹង ទូលំទូលាយអំពីទីផ្សារដែលពួកគេបានធ្វើប្រតិបត្តិការ ។ អាជីវកម្មប្រៃសណីយ៍ក៏មិនខុសគ្នាដែរ ។

ការទទួលព័តមាននេះបានធ្វើទៅបានតាមរយៈការស្រាវជ្រាវនិងការសិក្សាពីទីផ្សារ។ ចំណេះដឹងពីការស្រាវជ្រាវទីផ្សារ អាចបង្កើតឲ្យមានភាពខុសគ្នារវាងភាពជោគជ័យ និងភាពបរាជ័យ ការ

[៦] គេហទំព័រ: https://www.britannica.com/topic/postal-system

ចាប់ផ្តើមដោយមានទស្សនៈវិស័យយុទ្ធសាស្ត្រ និងអន្តរាគមន៍គោលនយោបាយលើការសម្រេចចិត្ត អាជីវកម្ម ការអភិវឌ្ឍផលិតផលនិងសេវាកម្ម ការបំពេញសេចក្តីពេញចិត្តរបស់អតិថិជន និងចុងក្រោយគឺនិរន្តរភាពហិរញ្ញវត្ថុ ។

នៅក្នុងការផ្លាស់ប្តូរយ៉ាងលឿននៃបរិស្ថានអាជីវកម្មមួយ ការស្រាវជ្រាវទីផ្សារត្រូវតែអនុវត្តឲ្យបានទៀងទាត់ ដូច្នេះភាគីដែលមានការពាក់ព័ន្ធមានលទ្ធភាពទទួលបានព័ត៌មាន ដែលទាន់ពេលវេលា។ យុទ្ធសាស្ត្រប្រៃសណីយ៍របស់UPU ក៏បានកំណត់នូវភាពប៉ិនប្រសប់ និងការអភិវឌ្ឍចំណេះដឹងក្នុងវិស័យប្រៃសណីយ៍ដោយផ្អែកលើមូលដ្ឋានទិន្នន័យ និងស្ថិតិទូលំទូលាយ នៅក្នុងចំណោមប្រភពផ្សេងទៀតដែលជាឱកាសដ៏អស្ចារ្យ ។

**UPU ដាក់ឲ្យអនុវត្តក្រុមស្រាវជ្រាវសេដ្ឋកិច្ច និងទីផ្សារប្រៃសណីយ**

ផែនទីបានបង្ហាញផ្លូវពីការស្រាវជ្រាវទីផ្សារមួយ ដែលច្បាស់លាស់ធានាបាននូវសំណុំនៃការព្យាករណ៍បាននូវផលិតផល និងឧបករណ៍ស្រាវជ្រាវទីផ្សាររបស់ UPU ។ ផែនទីបង្ហាញផ្លូវនេះត្រូវបានក្តោបក្តាប់ដោយក្រុមសិក្សាស្រាវជ្រាវសេដ្ឋកិច្ច និងទីផ្សារប្រៃសណីយ៍របស់ UPU ដែលអនុវត្តក្នុងក្របខណ្ឌនៃគណៈកម្មាធិការក្រុមប្រឹក្សាប្រតិបត្តិការប្រៃសណីយ ស្តីពីការអភិវឌ្ឍទីផ្សារនេះ និងដឹកនាំការងារស្រាវជ្រាវទីផ្សារ ព្រមទាំងអាចរួមចំណែកយ៉ាងខ្លាំងដល់មជ្ឈមណ្ឌល UPU នៃចំណេះដឹង និងភាពវៃឆ្លាតខាងផ្នែកទីផ្សារវិស័យប្រៃសណីយ៍ ។ គោលដៅសំខាន់ និងចម្បងរបស់ក្រុមនេះគឺដើម្បីធ្វើការស្រាវជ្រាវ និងការសិក្សាលើគម្លាតរវាងតម្រូវការដែលបានកំណត់ ទៅនឹងការសិក្សាស្រាវជ្រាវ ។ វាត្រូវបានគាំទ្រដោយទំហំទិន្នន័យធំដែលអាចប្រើបាន ។ ប្រភពចម្បងមួយទៀតនៃទិន្នន័យធំប្រៃសណីយ៍ គឺផ្លាស់ប្តូរសារអេឡិចត្រូនិច(EDI) រវាងប្រតិបត្តិករដែលបានកំណត់ និងរក្សាទុកដោយUPU ។

ទិន្នន័យនេះនឹងត្រូវបានផ្តល់ឲ្យដោយសម្ងាត់ ដើម្បីជូនដំណឹងជាមូលដ្ឋាន នៃលទ្ធផលស្រាវជ្រាវទីផ្សារ ។

**លទ្ធផលនៃការស្រាវជ្រាវទីផ្សារ**

ការចែករំលែក និងផ្លាស់ប្តូរនៃការងារស្រាវជ្រាវដែលមានស្រាប់ អាចបន្តគាំទ្រដល់តម្រូវការបច្ចុប្បន្នដោយជួយកំណត់គម្លាត និងកំណត់ការស្រាវជ្រាវនាពេលអនាគត។ ចំនួននៃឧបករណ៍លើបណ្តាញអ៊ីនធឺណែត ដែលកំពុងត្រូវបានបង្កើតដើម្បីគាំទ្រដល់សកម្មភាពស្រាវជ្រាវទីផ្សារ និងការិយាល័យអន្តរជាតិជាច្រើនត្រូវបានស្វែងរកឱកាសក្នុងភាពជាដៃគូ ជាមួយអង្គភាពអន្តរជាតិផ្សេងទៀតដែលមានឧបករណ៍បែបនេះរួចទៅហើយ ។ លទ្ធផលនៃការស្រាវជ្រាវទាំងនេះនឹងត្រូវបាន

ចែករំលែកតាមគេហទំព័រនេះ ជាមួយនឹងគោលបំណងដើម្បីលើកទឹកចិត្តដល់ការផ្សព្វផ្សាយចំណេះដឹងទីផ្សារ និងការលើកកម្ពស់វប្បធម៌នៃការសិក្សាស្តីពីទីផ្សារទៀងទាត់ក្នុងចំណោមសមាជិក ។

### ១.២.៣ សេវាកម្មដឹកជញ្ជូនបញ្ញើ

តម្រូវការសម្រាប់សេវាកម្មដឹកជញ្ជូន គឺវាកើតឡើងតាមរយៈសេចក្តីត្រូវការនៃពាណិជ្ជកម្ម ។ ហើយសេវាកម្មរបស់ក្រុមហ៊ុនដឹកជញ្ជូនអាចសម្រួល ដល់សកម្មភាពធ្វើពាណិជ្ជកម្មដូចជា ការធ្វើកិច្ចសន្យាសម្រាប់ការលក់ជាអន្តរជាតិ ធ្វើកិច្ចសន្យាសម្រាប់ការដឹកជញ្ជូនឆ្លងប្រទេស និងជួយធ្វើកិច្ចសន្យាធានារ៉ាប់រងទៅលើទំនិញ ។ ពាក់ព័ន្ធនឹងការដឹកជញ្ជូននោះផងដែរ ក៏មានភ្នាក់ងារមួយដែលគេហៅថា ជាភ្នាក់ងារដឹកជញ្ជូនបញ្ញើដែលមានតួនាទីរៀបចំ និងជួយគ្រប់ការដឹកជញ្ជូនទំនិញទាំងអស់ ។ មិនតែប៉ុណ្ណោះ ភ្នាក់ងារនេះ គឺជាឈ្មួញកណ្តាលរវាងអ្នកផ្ញើទំនិញ ឬអ្នកទទួលទំនិញ និងក្រុមហ៊ុនកប៉ាល់។ ដោយឡែកសម្រាប់ភ្នាក់ងារនេះ គ្មានភារកិច្ចក្នុងការទទួលខុសត្រូវលើការបាត់បង់ខូចខាតទំនិញនោះទេ អាចត្រឹមតែជួយតវ៉ាទៅកាន់ក្រុមហ៊ុនកប៉ាល់តែប៉ុណ្ណោះ ។

ការវិវត្តិនៃសេវាកម្មដឹកជញ្ជូនត្រូវបានបែងចែកជាបួនដំណាក់កាលៈ

-ដំណាក់កាលទី១៖ Traditional Forwarding ជារបៀបដឹកជញ្ជូនទំនិញតាមបែបប្រពៃណីក្នុងនោះត្រូវបានគេសំគាល់ថាជា Packing Forwarding ហើយជាសេវាកម្ម Shipping អន្តរជាតិ បន្ទាប់មកផ្តល់ដោយក្រុមហ៊ុនShipping សម្រាប់ទិញតាមអ៊ីនធើណេត ដែលទិញទំនិញឆ្លងប្រទេស ហើយភាគីខាងអ្នកលក់ត្រូវផ្តល់សេវាកម្មក្នុងការដឹកជញ្ជូនទំនិញឆ្លងប្រទេស សម្រាប់ម្ចាស់ទំនិញអ្នកទិញ ហើយអ្នកលក់ត្រូវរ៉ាបរងបង់ថ្លៃក្នុងប្រទេសដែលនាំចូលទំនិញនោះជំនួសអ្នកទិញទំនិញផងដែរ ។

-ដំណាក់កាលទី២៖ Cargo Consolidation សេវាកម្មនេះត្រូវបានផ្តល់ ដោយក្រុមហ៊ុនដឹកជញ្ជូនក្នុងស្ថានភាពដែលទំនិញនាំចេញមានតិចតួច ឬក៏ជាទំនិញរាយ បន្ទាប់មកត្រូវធ្វើការរងចាំបញ្ចូលជាមួយទំនិញរបស់អ្នកដទៃដែលមានគោលដៅដូចគ្នា ដើម្បីកាត់បន្ថយថ្លៃចំណាយលើការដឹកជញ្ជូន និងទទួលបាននូវអត្ថប្រយោជន៍រួមគ្នា ។

-ដំណាក់កាលទី៣៖ Multimodal Transport មានន័យថាសេវាកម្មដឹកជញ្ជូន Multimodal ដែលត្រូវបានគេស្គាល់ថា ជាការផ្តល់សេវាកម្មដឹកជញ្ជូនរួមបញ្ចូលគ្នា ទាំងផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស ដោយមានកិច្ចសន្យាទោល រួចអនុវត្តន៍មធ្យោបាយក្នុងការដឹកជញ្ជូនចាប់ពីពីរប្រភេទឡើងទៅ ។

-ដំណាក់កាលទី៥៖ Logistics and supply chain service គឺជាសេវាកម្មមួយដែលមានការផ្តល់នូវសេវាកម្មជាខ្សែចង្វាក់ផ្គត់ផ្គង់ និងដឹកជញ្ជូន គឺមានន័យថាភ្នាក់ងារដឹកជញ្ជូនបានក្លាយជាអ្នកជំនួសអោយម្ចាស់ទំនិញ ក្នុងការរៀបចំការដឹកជញ្ជូនតាមកប៉ាល់ ដោយមានប្រើប្រាស់នូវឈ្មោះក្រុមហ៊ុនរបស់ខ្លួនផ្ទាល់ និងរៀបចំមធ្យោបាយដឹកជញ្ជូនសរុបទាំងអស់ជូនអតិថិជន[៧] ។

## ១.៣ ផលិតផល និងសេវាកម្ម

### ១.៣.១ សេវាបញ្ញើប្រៃសណីយ៍ធម្មតា

#### ១.៣.១.១ ប្រៃសណីយ៍ប័ត្រ

ប្រៃសណីយ៍ប័ត្រ គឺជាប្រភេទប័ណ្ណដែលមានរូបភាពនៅខាងមុខ និងកន្លែងសរសេរព័ត៌មាននៅខាងខ្នង ដែលធ្វើអំពីក្រដាសរឹងមានទំហំកំណត់ សម្រាប់ប្រើប្រាស់នៅលើការបញ្ជូនព័ត៌មានខ្លីៗ ។

#### ១.៣.១.២ លិខិតអាកាសយាន

លិខិតអាកាសយាន គឺមានន័យថាអតិថិជនគ្រាន់តែសរសេរនៅលើក្រដាសបោះពុម្ពដែលមានតែមប្រ៊ីស្រាប់ ហើយបិទក្លាយជាស្រោមសំបុត្រមួយដោយមិនអាចឃើញអន្តរវត្ថុខាងក្នុងបានឡើយ ។

#### ១.៣.១.៣ សំបុត្រ

សំបុត្រ រួមមានលិខិត និងកញ្ចប់លិខិត គឺជាបណ្តាលិខិតស្នាមសរសេរដៃ វាយដោយអង្គុលីលេខ ឬបោះពុម្ពមានលក្ខណៈពិសេសលើការទំនាក់ទំនងព័ត៌មាន បុគ្គលត្រូវបិទជិត កំណត់ទម្ងន់អតិបរមា ២គីឡូក្រាម ចំពោះរបបអន្តរជាតិ និង៣គីឡូក្រាមចំពោះរបបក្នុងប្រទេស ។

#### ១.៣.១.៤ កលិកប័ត្រ

កលិកប័ត្រ គឺជាបណ្តាសារព័ត៌មាន ទស្សនាវដ្តី ឯកសារដែលបោះពុម្ព និងគ្មានលក្ខណៈពិសេសជាទំនាក់ទំនងបុគ្គល ដោយគ្រាន់តែផ្សាយព័ត៌មាន និងផ្ញើរដោយចំហរ ហើយត្រូវបានកំណត់ទម្ងន់អតិបរមា ៥គីឡូក្រាម ។

#### ១.៣.១.៥ កញ្ចប់តូច

កញ្ចប់តូច គឺជាកញ្ចប់ ឬប្រអប់ដាក់អន្តរវត្ថុ មិនមានលក្ខណៈពិសេសផ្សព្វផ្សាយព័ត៌មានផ្ទាល់ ដោយឡែក និងមិនមានការបិទជិត ឬខ្ទប់ជិត ហើយទំងន់អតិបរមា២គីឡូក្រាម ។

[៧] ឯកសារ: វគ្គបណ្តុះបណ្តាលនៅសមាគមភ្នាក់ងារបញ្ជូនទំនិញកម្ពុជាឆ្នាំ២០១៥ក្នុងមេរៀន ៖ Liability of Multimodal Transport Operation(MTO) ។

### ១.៣.១.៦ សំភារៈសិក្សាសម្រាប់មនុស្សខ្វាក់

សំភារៈសិក្សាសម្រាប់មនុស្សខ្វាក់ រួមមានថាស់ចំរៀង ខ្សែអាត់ ប្រដាប់ពិសេសបង្កើតដោយមន្ទីរពិសោធន៍ សាលារៀនសម្រាប់មនុស្សខ្វាក់ និងអក្សរអណ្តែតច្បាប់បោះពុម្ពតាមអក្សរអណ្តែត ត្រូវបានខ្ចប់ជិត បិទជិត ទំងន់អតិបរមា៧គីឡូក្រាម ។

### ១.៣.១.៧ បញ្ញើផ្ទៃរាបបញ្ជូនតាមអាកាសយាន

បញ្ញើផ្ទៃរាបបញ្ជូនតាមអាកាសយាន គឺមានតម្លៃអនុគ្រោះពន្ធ ត្រូវបានចាត់ទុកជាប្រភេទ S.A.L (Surface Air Lifted) ។ S.A.L (Surface Air Lifted) គឺជាសេវាកម្មបញ្ញើមួយដែលត្រូវបានដឹកជញ្ជូនតាមផ្លូវគោកឬផ្ទៃរាបទៅដល់ប្រទេសចុងទីមួយ និងដឹកជញ្ជូនតាមផ្លូវអាកាសទៅប្រទេសចុងទីមួយទៀតដូចប្រភេទAir Mail ធម្មតាដែរ ។ វាលឿនជាងSurface Mail (ដឹកជញ្ជូនតាមផ្លូវគោក) ប៉ុន្តែវាយឺតនិងថ្លៃជាងបញ្ញើAir Mail ។

**រូបភាពទី២៖ ដំណើរការបញ្ញើផ្ទៃរាបបញ្ជូនតាមអាកាសយាន**




### ១.៣.២ តែមប្រៃសណីយ៍

តែមប្រៃសណីយ៍ គឺជាប្រភេទក្រដាសតូចមួយដែលគេទិញ ដើម្បីទៅលើបញ្ញើនៃអន្តរវត្ថុនានា សម្រាប់ជាកុស្តតាងនៃការចំណាយលើការដឹកជញ្ជូន ។ តែមប្រភេទនេះ មានតែក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍តែមួយប៉ុណ្ណោះ ដែលមានសិទ្ធបោះពុម្ពតែមប្រៃប្រៃសណីយ៍សម្រាប់បិទលើបញ្ញើប្រៃសណីយ៍គ្រប់ប្រភេទ ។ កម្ពុជាប្រើប្រាស់តែមប្រៃប្រៃសណីយ៍ នៃតំបន់ឥណ្ឌូចិនរហូតដល់ដើមទសវត្សរ៍ទី៥០ ។ នៅឆ្នាំ ១៩៤៩ ប្រទេសកម្ពុជាបានក្លាយទៅជារដ្ឋពាក់ព័ន្ធមួយនៃសហជីពបារាំង (French Union) តែក្រោយដណ្តើមបានឯករាជ្យពេញលេញក្នុងកំឡុងឆ្នាំ១៩៥៣ ប្រទេសកម្ពុជា ក៏បានចាកចេញពីសហជីពនេះនៅឆ្នាំ១៩៥៥ ។

តែមប្រៃដំបូងត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៥១ ដែលមានឈ្មោះថា Royaume du Cambodge ដែលជាតែមប្រៃប្រៃសណីយ៍មួយប្រភេទមានព្រះឆាយល័ក្ខណ៍នៃព្រះមហាវីរៈក្សត្រ **នរោត្តម សីហនុ** ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គ្មានការចេញតែមប្រ៊ីនោះទេ រហូតដល់ឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពខ្មែរក្រហមរត់ចាកចេញពីភ្នំពេញអស់ ។ នៅខែមេសា ឆ្នាំ១៩៨០ ទើបគេប្រទះឃើញមានតែមប្រ៊ីប្រៃសណីយ៍ចាប់បដិសន្ធិឡើងវិញ ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា[៨] ។

## រូបភាពទី៣៖ កម្រងតែមប្រ៊ីប្រៃសណីយ៍

កម្រងតែមប្រ៊ីរួមមាន៖

### ទិដ្ឋភាពខ្មែរ



### ឧបករណ៍កសិកម្មបុរាណ



[៨] គេហទំព័រ : https://en.wikipedia.org/wiki/Postage_stamps_and_postal_history_of_Cambodia

**របាំប្រពៃណីខ្មែរ**




**គំរប់ខួបមួយឆ្នាំ នៃការដាក់បញ្ចូលប្រាសាទព្រះវិហារ ជាសម្បត្តិបេតិកភ័ណ្ឌពិភពលោក**



**ដើមត្នោតខ្មែរ**



## ១.៣.៣ ប្រអប់សំបុត្រ

ប្រអប់សំបុត្រត្រូវបានបែងចែកជាពីរគឺ ប្រអប់ប្រៃសណីយ៍ និងមានទីតាំងជួលជាប្រអប់។

ក. ប្រអប់ប្រៃសណីយ៍ចែកចេញជាពីរ រួមមាន៖

- ការចែកបញ្ញើតាមប្រអប់ប្រៃសណីយ៍: រាល់បញ្ញើមានអាស័យដ្ឋាន ជាលេខប្រអប់សំបុត្រ ត្រូវបានបែងចែកទៅតាមប្រអប់សំបុត្រនីមួយៗក្នុងតំបន់របស់ខ្លួន។ ចំពោះបញ្ញើដែលមានទំហំពុំអាចដាក់ចូលក្នុងប្រអប់ប្រៃសណីយ៍បាន កញ្ចប់ភណ្ឌិកាដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ភ្នាក់ងារគយ អាណត្តិបើកប្រាក់ ភ្នាក់ប្រៃសណីយ៍ត្រូវធ្វើលិខិតជូនដំណឹងអោយអ្នកទទួលមកទទួលផ្ទាល់នៅតាមបញ្ជរពាក់ព័ន្ធ។

➢ ប្រអប់សំបុត្រដែលអតិថិជនអាចជួលជាវ មាននៅតាមសាខាប្រៃសណីយ៍រាជធានី- ខេត្ត

| N0 | ឈ្មោះខេត្ត ក្រុង | ចំនួនប្រអប់តូច | ចំនួនប្រអប់ធំ |
|---|---|---|---|
| 1 | ខេត្តកំពង់ធំ | 30 | 30 |
| 2 | ខេត្តព្រះវិហារ | 2 | 4 |
| 3 | ខេត្តកំពង់ចាម | 50 | 50 |
| 4 | ខេត្តស្វាយរៀង | 50 | 50 |
| 5 | ខេត្តពោធិ៍សាត់ | 50 | 50 |
| 6 | ខេត្តកំពង់ឆ្នាំង | 50 | 50 |
| 7 | ខេត្តកណ្តាល | 50 | 50 |
| 8 | ខេត្តព្រៃវែង | 6 | 6 |
| 9 | ខេត្តបន្ទាយមានជ័យ | 40 | 40 |
| 10 | ខេត្តបាត់ដំបង | 96 | 96 |
| 11 | ខេត្តក្រចេះ | 50 | 50 |
| 12 | ខេត្តរតនៈគិរី | 24 | 96 |
| 13 | ខេត្តស្ទឹងត្រែង | 0 | 45 |
| 14 | ខេត្តកំពត | 40 | 40 |
| 15 | ខេត្តកែប | 40 | 40 |
| 16 | ខេត្តព្រះសីហនុ | 180 | 268 |
| 17 | ខេត្តកោះកុង | 50 | 130 |
| 18 | ខេត្តប៉ៃលិន | 50 | 50 |
| 19 | ខេត្តឧត្តរមានជ័យ | 0 | 0 |
| 20 | ខេត្តតាកែវ | 48 | 72 |
| 21 | ខេត្តមណ្ឌលគិរី | | 50 |
| 22 | ខេត្តកំពង់ស្ពឺ | 50 | 50 |

| | | | |
|---|---|---|---|
| 23 | ខេត្តត្បូងឃ្មុំ | 50 | 50 |
| 24 | ខេត្តសៀមរៀប | | 50 |
| 25 | វត្តភ្នំ | 1596 | 279 |
| 26 | បឹងព្រលឹត | 1319 | 80 |
| 27 | ច្បារអំពៅ | | 30 |

**១.៣.៤ សេវាបញ្ញើប្រៃសណីយ៍ភ័ណ្ឌ**

សេវាបញ្ញើប្រៃសណីយ៍ភ័ណ្ឌ គឺជាបណ្តាកញ្ចប់បញ្ញើទាំងឡាយដែលផ្ញើតាមប្រៃសណីយ៍ ដើម្បីបញ្ជូនដល់ដៃអ្នកទទួលតាមរបៀបរបបណាមួយដោយឡែកទៀត ។ ប្រៃសណីយ៍ភ័ណ្ឌ មានទំហំ និងទំងន់ធំជាងបញ្ញើប្រៃសណីយ៍ធម្មតា ។ ខ្លឹមសាររបស់ប្រៃសណីយ៍ភ័ណ្ឌមិនអាចដាក់លិខិត ឬកត់ត្រារាល់ខ្លឹមសារដែលមានទំនាក់ទំនងជាបុគ្គលបានឡើយ ប៉ុន្តែរបៀបរបបវេចខ្ចប់ត្រូវបានបិទជិត ។ បញ្ញើប្រៃសណីយ៍ភ័ណ្ឌដែលមានទំនាក់ទំនងក្នុងក្របខ័ណ្ឌទឹកដីក្នុងប្រទេសយើង ហៅថាប្រៃសណីយ៍ភ័ណ្ឌក្នុងប្រទេស ។ លើសពីនេះទៅទៀត ប្រៃសណីយ៍ភ័ណ្ឌដែលមានទំនាក់ទំនងរវាងប្រទេសយើងនិងប្រទេសដទៃទៀត ហៅថាប្រៃសណីយ៍ភ័ណ្ឌអន្តរជាតិ ។

**១.៣.៥ សេវាបញ្ញើឆាប់រហ័ស**(EMS)

សេវាបញ្ញើឆាប់រហ័ស (EMS) ជាសេវាដែលមានគុណភាពខ្ពស់លើបណ្តាសេវាដទៃទៀត ដែលមានក្នុងប្រៃសណីយ៍កម្ពុជា ហើយសេវានេះក៏មានសារៈសំខាន់ផងដែរ សម្រាប់អតិថិជនដែលមានបំណងផ្ញើ លិខិតសំខាន់ៗទៅក្រៅប្រទេស ក៏ដូចជាក្នុងប្រទេសផងដែរ ។ សេវាបញ្ញើឆាប់រហ័ស(EMS) គឺមានលេខកូដតាមដានបញ្ញើច្បាស់លាស់ ដោយធ្វើការតាមដានដោយខ្លួនឯងនៅលើគេហទំព័ររបស់ប្រៃសណីយ៍កម្ពុជា គេហទំព័ររបស់ប្រទេសទទួល ឬតាមភ្នាក់ងាររបស់ប្រៃសណីយ៍កម្ពុជាដោយផ្ទាល់ ។ មិនត្រឹមតែប៉ុណ្ណោះសេវាបញ្ញើឆាប់រហ័ស(EMS) បានផ្តល់ជាសេវាជំពាក់ពន្ធសម្រាប់អតិថិជនដែលមានបំណងប្រើប្រាស់សេវានេះ ជាចរន្តក្នុងចែកចាយទៅដៃគូរបស់ខ្លួនដោយការជំពាក់ថ្លៃសេវាត្រូវបានគិតរៀងរាល់មួយខែម្តង និងតម្រូវអោយអតិថិជនតម្កល់ទឹកប្រាក់ក្នុងការធ្វើកិច្ចសន្យាប្រើប្រាស់ ។ សេវាបញ្ញើឆាប់រហ័ស (EMS) គឺមានលក្ខខ័ណ្ឌសម្រាប់ការធ្វើការទូទាត់សំណងជូនអតិថិជនលើករណីឥវ៉ាន់ដែលផ្ញើមានការបាត់បង់ក្នុងរយៈពេល១ខែ គឺចាប់ពីថ្ងៃដែលអតិថិជនផ្ញើ ។

### ១.៣.៦ សេវាពិសេស

-បញ្ញើអនុសិដ្ឋ: បញ្ញើគ្រប់ប្រភេទអាចផ្ញើរជាអនុសិដ្ឋនៅគ្រប់ទីកន្លែងក្នុងប្រទេស និងក្រៅប្រទេស។ លើសពីនេះទៅទៀតអ្នកផ្ញើរត្រូវបំពេញអាស័យដ្ឋាន ។ តម្លៃត្រូវបានកំណត់លើ តារាងពន្ធអាករប្រៃសណីយ៍ ។ ដោយឡែកចំពោះប្រទេសកាណាដា និងសហរដ្ឋអាមេរិច មិនអនុញ្ញាតអោយនាំចូលជាបារអនុសិដ្ឋ ។

-ចែកពិសេស: សេវានេះសម្រាប់ទុកអោយអ្នកផ្ញើរ សំណូមពរសុំចែកបញ្ញើដល់អាស័យដ្ឋានអ្នកទទួលភ្លាមៗក្រោយពេលកាត់បញ្ញើ ។ ការចែកពិសេសនេះមានតម្លៃសម្រាប់តែ ការចែកលើកដំបូងបង្អស់ ប្រសិនបើពេលចែកមិនបាននោះ ត្រូវគូសចោលស្លាកចែកពិសេសបញ្ជូនត្រូវបានចែកដូចធម្មតាវិញ ។ នៅលើបញ្ញើប្រៃសណីយ៍ត្រូវបិតស្លាក ឬវាយត្រា (Express) នៃផ្នែកខាងឆ្វេងនៃអាស័យដ្ឋានរបស់អ្នកទទួល ។ សេវានេះមានប្រសិទ្ធិភាពតែក្នុងរង្វង់ចែក ដែលបានកំណត់នៅតាមប្រៃសណីយ៍នីមួយៗ ។ ចំពោះកញ្ចប់ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់គយ សេវានេះមានប្រសិទ្ធិភាពត្រឹមតែចែកលិខិតជូនដំណឹងប៉ុណ្ណោះ ។

-ផលប័ត្រជូនដំណឹង: ចំពោះអ្នកផ្ញើបញ្ញើអនុសិដ្ឋ ឬប្រៃសណីយ៍ភ័ណ្ឌអាចសុំផលប័ត្រជូនដំណឹងពីការចែកក្នុងពេលផ្ញើរ ឬក្រោយពេលផ្ញើរបញ្ញើ ។ តម្លៃ ត្រូវបានគិតសរុបជាមួយតម្លៃផ្ញើរដូចមានក្នុងតារាងពន្ធអាករប្រៃសណីយ៍កម្ពុជា។ នៅលើបញ្ញើត្រូវបិទ ឬវាយត្រា AR ។ ការិយាល័យដែលទទួលបញ្ញើ AR ត្រូវប្រគល់ដល់ដៃអ្នកទទួល ឬប្រគល់សិទ្ធិអោយចុះហត្ថលេខា ហើយបោះត្រាថ្ងៃ ខែ រួចបញ្ជូនត្រឡប់ទៅការិយាល័យដើមរបស់អ្នកផ្ញើរដោយផ្ទាល់ ។ ក្នុងករណីដែលរង់ចាំអ្នកផ្ញើរពុំបានទទួលការឆ្លើយតបណាមួយ ការធ្វើផលប័ត្រជូនដំណឹងជាលើកទី២ ឬធ្វើលិខិតតវ៉ាលើគំរូ ដោយពុំគិតតម្លៃផ្ញើរទៅការិយាល័យទទួលម្តងទៀត ។

### ១.៣.៧ សេវាកម្មលើការងារដឹកជញ្ជូនបញ្ញើ និងដឹកអ្នកដំណើរក្នុងស្រុក

កន្លងមកក្រុមហ៊ុនប្រៃសណីយ៍កម្ពុជា បានដាក់ដំណើរការសេវាកម្មដឹកជញ្ជូនបញ្ញើក្នុងស្រុករួចមកហើយ ដែលដឹកជញ្ជូនបញ្ញើពីភ្នំពេញទៅតាមបណ្តាខេត្ត ឬ ពីខេត្តមកភ្នំពេញ និងពីខេត្តទៅកាន់ខេត្តមួយទៀត ។ ដោយសម្លឹងឃើញពីការរីកលូតលាស់បែបនេះ អគ្គនាយកប្រៃសណីយ៍កម្ពុជាក៏បានបញ្ចូលនូវសេវាកម្មដឹកអ្នកដំណើរក្នុងស្រុកមួយទៀត ដែលរថយន្តមួយមិនត្រឹមតែដឹកទំនិញប៉ុណ្ណោះទេ ប៉ុន្តែអាចដឹកអ្នកដំណើរបានថែមទៀតផង ។ ក្រុមហ៊ុនប្រៃសណីយ៍បានចំណាយរថយន្តទំនើបថ្មីៗចំនួន ១៣គ្រឿង, ប្រភេទ Toyota Hiace 2015 (ប្រភេទ១៥កៅអី) ចំនួន១០គ្រឿង, និងរថយន្ត Hyundia Starex ចំនួន០១គ្រឿងសម្រាប់ Pickup ។

សេវាកម្មដឹកជញ្ជូនបញ្ញើ និងដឹកអ្នកដំណើរក្នុងស្រុកគ្រប់ដណ្តប់ចំនួន១៧ខេត្ត/ក្រុង នៃផ្ទៃប្រទេស៖

ខ្សែរត់ទី១: ផ្លូវជាតិលេខ២ និងផ្លូវជាតិលេខ១ (រត់ដឹកបញ្ញើ)

-ឆ្លងកាត់ខេត្តចំនួន០៥: កណ្តាល ស្វាយរៀង ព្រៃវែង ត្បូងឃ្មុំ និងកំពង់ចាម

ខ្សែរត់ទី២: ផ្លូវជាតិលេខ៣ និងផ្លូវជាតិលេខ២

-ឆ្លងកាត់ខេត្តចំនួន០៤: កំពត កែប តាកែវ និងកណ្តាល

ខ្សែរត់ទី៣: ផ្លូវជាតិលេខ៤

-ឆ្លងកាត់ខេត្តចំនួន០២: ខេត្តកំពង់ស្ពឺ និងព្រះសីហានុ

ខ្សែរត់ទី៤: ផ្លូវជាតិលេខ៥

-ឆ្លងកាត់ខេត្តចំនួន០៥: ខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង និងប៉ោយប៉ែត

ខ្សែរត់ទី៥: ផ្លូវជាតិលេខ៦

-ឆ្លងកាត់ខេត្តចំនួន០២: ខេត្តកំពង់ធំ និងសៀមរាប

ខ្សែរត់ទី៦: ផ្លូវជាតិលេខ៦

-ឆ្លងកាត់ខេត្តចំនួន០៣: ប៉ោយប៉ែត សៀមរាប និងកំពង់ធំ ។

## តម្លៃសំបុត្រតាមខ្សែរត់នីមួយៗ

| ១.តម្លៃសំបុត្រពីភ្នំពេញ ទៅតាមបណ្តាខេត្ត | | | | |
|---|---|---|---|---|
| ល.រ | ទិសដៅធ្វើដំណើរ | ម៉ោងចេញដំណើរ | | តម្លៃ(រៀល) |
| | | ព្រឹក | រសៀល | |
| 1 | ភ្នំពេញ→ស្វាយរៀង | 7:30 | | 20,000 |
| 2 | ភ្នំពេញ→កំពត | 7:30 | | 28,000 |
| 3 | ភ្នំពេញ→កែប | 7:30 | | 28,000 |
| 4 | ភ្នំពេញ→កំពង់ស្ពឺ | 7:30 | | 16,000 |
| 5 | ភ្នំពេញ→ព្រះសីហានុ | 7:30 | | 28,000 |
| 6 | ភ្នំពេញ→កំពង់ឆ្នាំង | 7:30 | | 32,000 |
| 7 | ភ្នំពេញ→ពោធិសាត់ | 7:30 | | 32,000 |
| 8 | ភ្នំពេញ→បាត់ដំបង | 7:30 | | 32,000 |
| 9 | ភ្នំពេញ→បន្ទាយមានជ័យ | 7:30 | | 40,000 |

| | | | | |
|---|---|---|---|---|
| 10 | ភ្នំពេញ→ប៉ោយប៉ែត | 7:30 | | 48,000 |
| 11 | ភ្នំពេញ→កំពង់ធំ | 7:30 | | 24,000 |
| 12 | ភ្នំពេញ→សៀមរាប | 7:30 | | 32,000 |

**២.តម្លៃសំបុត្រពីបណ្ដាខេត្តមកភ្នំពេញ**

| ល.រ | ទិសដៅធ្វើដំណើរ | ម៉ោងចេញដំណើរ | | តម្លៃ(រៀល) |
|---|---|---|---|---|
| | | ព្រឹក | រសៀល | |
| 1 | ព្រះសីហនុ→ភ្នំពេញ | 7:30 | | 28,000 |
| 2 | ប៉ោយប៉ែត→ភ្នំពេញ | 9:30 | | 48,000 |
| 3 | សៀមរាប→ភ្នំពេញ | 7:30 | 2:00 | 32,000 |
| 4 | កែប→ភ្នំពេញ | | 12:30 | 28,000 |

**៣.តម្លៃសំបុត្រចេញពីខេត្តទៅខេត្ត**

| ល.រ | ទិសដៅធ្វើដំណើរ | ម៉ោងចេញដំណើរ | | តម្លៃ(រៀល) |
|---|---|---|---|---|
| | | ព្រឹក | រសៀល | |
| 1 | កំពង់ឆ្នាំង→ពោធិសាត់ | 10:00 | | 16,000 |
| 2 | កំពង់ឆ្នាំង→បាត់ដំបង | 10:00 | | 24,000 |
| 3 | កំពង់ឆ្នាំង→បន្ទាយមានជ័យ | 10:00 | | 32,000 |
| 4 | កំពង់ឆ្នាំង→ប៉ោយប៉ែត | 10:00 | | 40,000 |
| 5 | ពោធិសាត់→បាត់ដំបង | | 12:00 | 16,000 |
| 6 | ពោធិសាត់→បន្ទាយមានជ័យ | | 12:00 | 24,000 |
| 7 | ពោធិសាត់→ប៉ោយប៉ែត | | 12:00 | 32,000 |
| 8 | បាត់ដំបង→បន្ទាយមានជ័យ | | 12:30 | 16,000 |
| 9 | បាត់ដំបង→ប៉ោយប៉ែត | | 12:30 | 24,000 |
| 10 | បន្ទាយមានជ័យ→ប៉ោយប៉ែត | | 1:45 | 16,000 |
| 11 | កំពង់ធំ→សៀមរាប | 11:30 | | 24,000 |
| 12 | កំពង់ស្ពឺ→ព្រះសីហនុ | 9:45 | | 20,000 |
| 13 | ព្រះសីហនុ→កំពង់ស្ពឺ | 7:30 | 1:30 | 20,000 |

**រូបភាពទី៤៖ រថយន្តដឹកជញ្ជូនបញ្ញើនិងអ្នកដំណើរក្នុងស្រុក**




## តារាងតម្លៃផ្ញើបញ្ញើតាមរថយន្តអ្នកដំណើរ

តារាងតម្លៃសេវាដឹកជញ្ជូនឥវ៉ាន់/ទំនិញតាមរថយន្តដឹកអ្នកដំណើរ

| លិខិត/កញ្ចប់<br>ទម្ងន់(kg) | តម្លៃសេវាចែកនៅបញ្ជរ |
|---|---|
| 10g-1kg | 3,000៛ |
| 1kg-5kg | 5,000៛ |
| 5kg-10kg | 10,000៛ |
| 10kg-20kg | 20,000៛ |

| | |
|---|---|
| លិខិតឆ្លងដែន | 20,000៛ |
| ទូរស័ព្ទ | 20,000៛ |
| អាយផេត | 20,000៛ |

| | |
|---|---|
| កុំព្យូទ័រ | 20,000៛ |
| នាឡិកាដៃ | 20,000៛ |
| វ៉ែនតា | 20,000៛ |
| រាល់វត្ថុអនុស្សាវរីយ៍ប្រកាសតម្លៃ | 20,000៛ |

**១.៣.៨ តារាងតម្លៃសេវាប្រៃសណីយ៍អន្តរជាតិ**

តម្លៃសេវាកម្មប្រៃសណីយ៍មានភាពថូរថ្លៃ និងសមរម្យជាងក្រុមហ៊ុនដឹកជញ្ជូនដទៃទៀតបើប្រៀបធៀបទៅនឹង ក្រុមហ៊ុនDHL; FedEx; Linex ជាដើម ។ កន្លងមកតម្លៃសេវាប្រៃសណីយ៍ទាំងអស់ត្រូវគិតជាប្រាក់ដុល្លារអាមេរិក ប៉ុន្តែបច្ចុប្បន្ននេះសេចក្តីសម្រេចស្តីពី ការកែសម្រួលតម្លៃសេវាប្រៃសណីយ៍ ត្រូវបានដាក់អនុវត្ត និងមានប្រសិទ្ធិភាពចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ តទៅ ។ (មើលឯកសារយោង)

**១.៤ ឯកសារពាក់ព័ន្ធ នឹងការធ្វើពាណិជ្ជកម្ម**

**១.៤.១ អនុស្សរណៈនៃការយោគយល់គ្នារវាង UPU និង WCO**

រដ្ឋបាលគយ និងប្រៃសណីយ៍ បានព្រមព្រៀងគ្នាបង្កើតនូវគណកម្មាធិការមួយ ឈ្មោះថា WCO-UPU Contact Committee ដែលគណកម្មាធិការនេះមានតួនាទីដោះស្រាយបញ្ហានានាជាប់ដែលទាក់ទងនឹងការចរាចរណ៍ទំនិញប្រៃសណីយ៍ ជាពិសេសមានការរិះរកមធ្យោបាយយ៉ាងណាដើម្បីៈ

a ពន្លឿន និងសម្រួលការធ្វើទម្រង់ការគយ នៅក្នុងសេវាប្រៃសណីយ៍

b សម្រួលការធ្វើសាមញ្ញកម្ម និងសុខដុមនីយកម្មនៃនីតិវិធីគយលើកញ្ចប់ប្រៃសណីយ៍

c ធានាប្រសិទ្ធិភាពការត្រួតពិនិត្យគយលើកញ្ចប់បញ្ញើប្រៃសណីយ៍

d ធានាឲ្យបាននូវប្រសិទ្ធិភាព និងសុវត្ថិភាពក្នុងការផ្ទុកទំនិញ

e ធ្វើឲប្រសើរឡើងនូវការត្រួតពិនិត្យគយនៅពេលនាំចេញ។

គោលការណ៍គន្លឹះក្នុងការបញ្ចេញទំនិញប្រៃសណីយ៍ពីគយ ត្រូវបានថ្លែងនៅក្នុង Revised Kyoto Convention[៩]

➢ រដ្ឋបាលគយត្រូវកំណត់នូវទំនិញណា ជាកម្មវត្ថុនៃការត្រួតពិនិត្យគយ ដោយពិចារណាទៅលើច្បាប់ជាតិពាក់ព័ន្ធគយ ឬ ស្ថាប័នដទៃទៀត ។ គួរកត់សំគាល់ផងដែរថា គយមានសិទ្ធិធ្វើការ

[៩] customs.gov.ph/wp-content/uploads/2016/10/KYOTO-Convention.pdf

ត្រួតពិនិត្យគ្រប់បញ្ជីសេវាប្រៃសណីយ៍ទាំងអស់ រួមទាំងការបើកសំបុត្រដោយត្រឹមត្រូវ និងសមស្រប តាមច្បាប់ ។

➢ ការត្រួតពិនិត្យគយបឋមអាចធ្វើទៅបាន ចំពោះកញ្ចប់បញ្ញើប្រៃសណីយ៍ណាដែលសំខាន់ និងប្រញាប់ ហើយភាគច្រើនមិនមែនជាកម្មវត្ថុនៃការជាប់ពន្ធនិងអាករ

➢ ដើម្បីជំរុញដំណើរការនៃការត្រួតពិនិត្យគយ ប្រៃសណីយ៍និងគយអាចឯកភាពគ្នាឲ្យបញ្ញើដែលមានលក្ខណៈជាសំបុត្រ ឬ លិខិតចរាចរទៅបាន ដោយមិនចាំបាច់គយត្រួតពិនិត្យជាមុន។

➢ នីតិវិធីនៃការត្រួតពិនិត្យគយបឋម ត្រូវបានបែងចែកតាមថ្នាក់នៃបញ្ញើនីមួយៗដូចជា បញ្ញើអនុសិដ្ឋ ប្រៃសណីយ៍ភ័ណ្ឌ និងបញ្ញើឆាប់រហ័ស។

➢ ភាគីប្រៃសណីយ៍ត្រូវបង្ហាញដល់ភាគីគយនូវកញ្ចប់បញ្ញើនានាដូចជា បញ្ញើតាមផ្លូវអាកាស ឬផ្លូវរាប ស្របតាមគុណភាពនៃការតម្រូវសេវា ។ ចំពោះទំនិញដែលត្រូវបានបើកដោយកម្មវត្ថុនៃការត្រួតពិនិត្យបន្ទាប់មកធ្វើការបើក និងបិទម្តងទៀតត្រូវដែលធ្វើឡើងដោយភាគីគយ ឬភាគីប្រៃសណីយ៍ណាមួយក៏បាន។

ប្រៃសណីយ៍ និងគយអាចឯកភាពគ្នាលើលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

-ប្រៃសណីយ៍អាចប្រគល់ជូនគយនូវឯកសារ (CN22, CN23, វិក័យប័ត្រពាណិជ្ជកម្ម) ឬរូបភាពនៃឯកសារសម្រាប់ត្រួតពិនិត្យ ជាជាងការត្រួតពិនិត្យរូបវន្តដោយខ្លួនឯង។

-ប្រៃសណីយ៍អាចធ្វើសកម្មភាពជំនួសគយបាន ចំពោះប្រតិបត្តិការជាក់លាក់ដូចជា:

១. ប្រៃសណីយ៍អាចធ្វើការត្រួតពិនិត្យគយបឋម ដោយមានការណែនាំ និងបណ្តុះបណ្តាលពីគយ ។

២. ប្រៃសណីយ៍អាចកំណត់ពន្ធ និងអាករដែលត្រូវប្រមូល ដោយគយជាអ្នកផ្តល់នូវសុពលភាព និងជួយដោះស្រាយបញ្ហានានារបស់ប្រៃសណីយ៍ ក្នុងការកំណត់តម្លៃពន្ធក្នុងតារាងពន្ធគយ។

៣. ប្រៃសណីយ៍ក៏អាចដើរតួ ជាភ្នាក់ងារបញ្ចេញទំនិញពីគយដោយផ្ទាល់ ឬដោយប្រយោលឬជាតំណាងឲ្យអ្នកទទួល ហើយត្រូវបង់ពន្ធអាករ ដែលទទួលបានជូនរដ្ឋបាលគយផងដែរ ។

### ១.៤.២ អនុក្រឹត្យ លិខិតអនុញ្ញាត សារាចរណែនាំ និងសេចក្តីជូនដំណឹង

ទន្ទឹមនឹងមានអនុស្សារណៈយោគយល់គ្នា និង ច្បាប់ស្តីពីវិស័យប្រៃសណីយ៍ដែលជាច្បាប់សំខាន់ជាងគេ ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជាបានចូលរួមចំណែកក្នុងការសហការជាមួយនឹង សាមីក្រសួង អាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីពាក់ព័ន្ធក្នុងការពង្រឹងប្រសិទ្ធភាព ការអនុវត្តន៍ច្បាប់ និងបទបញ្ញត្តិផ្សេងៗទៀតនៃព្រះរាជាណាចក្រកម្ពុជា ។ ជាក់ស្តែងក្រសួងរ៉ែ និងថាមពល ធ្លាប់បានជូនដំណឹងមកឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីឲ្យអង្គភាពគយនៅតាមមូលដ្ឋាន(សាខាគយនិងរដ្ឋាករប្រៃសណីយ៍)ជាដើម ក្នុងការជួយសហការទប់ស្កាត់រាល់ការនាំចេញសំណាករ៉ែ និងធនធានរ៉ែគ្រប់ប្រភេទចេញទីក្រៅប្រទេស ដោយគ្មានអនុញ្ញាតពីក្រសួងរ៉ែ និងថាមពល ។ (មើលឧបសម្ព័ន្ធទី៧) ។ ក្រៅពីនោះមានអនុក្រឹត្យលេខ២០៩ របស់រាជរដ្ឋាភិបាលស្តីពីទំនិញហាមឃាត់ និងជាប់កម្រិតកំណត់ សម្រាប់ភ្នាក់ងារគយប្រៃសណីយ៍ធ្វើជាមូលដ្ឋានពិចារណា និងប្រកាសស្តីពីបញ្ជីហាមឃាត់ សម្រាប់ភ្នាក់ងារប្រៃសណីយ៍ ។ (មើលឧបសម្ព័ន្ធទី៨)

### ១.៤.៣ សញ្ញាណខ្លះៗនៃB/L; Air waybill និង Manifest

Bill of Lading និង Air waybill គឺជាឯកសារដឹកជញ្ជូនពីរប្រភេទដែលត្រូវបានគេប្រើប្រាស់នៅក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ ជាច្រើនទសវត្សន៍កន្លងមកហើយ ។

Air waybill គឺជាឯកសារដឹកជញ្ជូនដែលគេប្រើវាសម្រាប់ការផ្ទុកទំនិញតាមផ្លូវអាកាសពីអាកាសយានដ្ឋានមួយទៅអាកាសយានដ្ឋានមួយទៀត ។

Bill of Lading គឺជាឈ្មោះនៃឯកសារដឹកជញ្ជូនមួយប្រភេទដែលប្រើសម្រាប់ការផ្ទុកលើកដាក់ទំនិញ តាមជើងទឹកពីកំពង់ផែមួយទៅកំពង់ផែមួយទៀត[៩] ។

Manifest (Customs Manifest) ជាភាសាខ្មែរមានន័យថានិវេទនប័ណ្ណ គឺជាឯកសារដឹកជញ្ជូនដែលបង្ហាញជាក់លាក់ពីទំនិញ អ្នកដំណើរ ឈ្មោះកប៉ាល់ យន្តហោះ ឬរថយន្តដឹកទំនិញសម្រាប់គ្រប់គ្រងដោយមន្ត្រីគយនិងរដ្ឋាករឬមន្ត្រីពាក់ព័ន្ធដទៃទៀត ។ Manifest គឺជាបញ្ជីនៃមុខទំនិញទាំងអស់ដែលបានរៀបរាប់ នៅក្នុងវិក័យប័ត្រ B/L ឬAir waybill ដែលត្រូវបានផ្ទុកនៅលើនាវា ឬយន្តហោះ ក្នុងកំពង់ផែឬអាកាសដ្ឋានជាក់លាក់ណាមួយ ។ Manifest រាយលម្អិតពីលក្ខណៈនៃទំនិញដូចជាធម្មជាតិ, បរិមាណ, ប្រភេទ និងចំនួន, កាលបរិច្ឆេទ ទិសដៅ និង ប្រភពនៃទំនិញ និងប្រភេទសេវាបញ្ញើសម្រាប់សេចក្តីប្រកាសគយ(ប្រតិវេទន៍គយ) ។

[៩] (http://www.advancedontrade.com/2015/02/what-are-differences-between-air-waybill-and-bill-of-lading.html)

**១.៤.៤ ដីកាអម (ដីកាបញ្ជូន)**

ដីកាអម ឬដីកាបញ្ជូន គឺជាឯកសារមួយប្រភេទដែលត្រូវបានបោះពុម្ព ដែលបង្កើតឡើងដោយភ្នាក់ងារប្រៃសណីយ៍ ដោយយោងតួលេខចេញពីប្រព័ន្ធIPS និងការប្រតិបត្តិជាក់ស្តែង ហើយឯកសារនេះរួមបញ្ចូលទិន្នន័យដូចជា ប្រភេទសេវាបញ្ញើ(EMS; CP; LC/AO), ចំនួនបាវ, ចំនួនកញ្ចប់នាំចេញ និងចំនួនសំបកបាវសរុបដែលត្រូវដាក់ជូនមន្រ្តីគយប្រចាំការ នៅប្រៃសណីយ៍កម្ពុជាត្រួតពិនិត្យ ។ (មើលឧបសម្ព័ន្ធទី៩)

**១.៤.៥ ពន្ធគយ និងពន្ធដទៃទៀត**

រាល់អន្តរវត្ថុដែលផ្ញើតាមរយៈប្រៃសណីយ៍កម្ពុជា អ្នកប្រើប្រាស់សេវាប្រៃសណីយ៍ត្រូវបានជាប់កាតព្វកិច្ចក្នុងការបង់ពន្ធជូនរាជរដ្ឋាភិបាលកម្ពុជា ។ ពន្ធគយ និងពន្ធដទៃផ្សេងៗទៀតត្រូវបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយឡែកករណីដូចខាងក្រោមនេះ គឺត្រូវបានលើកលែង:

- បញ្ជូនត្រឡប់ទៅម្ចាស់ដើមវិញ
- អន្តរវត្ថុត្រូវបានខូចខាត
- ការបញ្ជូនបន្តទៅប្រទេសទីបី
- សារាចរណែនាំលេខ០០៤សហវ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ ស្តីពីនីតិវិធីគយលើទំនិញតម្លៃទាប (De Minimis) [១០] ។

**១.៤.៦ ការរួចអាករប្រៃសណីយ៍**

ជាគោលការណ៍រួម រាល់បញ្ញើប្រៃសណីយ៍ត្រូវបានគិតពន្ធអាករទៅតាមប្រភេទ។ ដោយឡែកចំពោះបញ្ញើដូចខាងក្រោម ត្រូវបានលើកលែង:

❖ រាល់បញ្ញើប្រៃសណីយ៍ដែលផ្ញើ ចេញពីក្រសួងប្រៃសណីយ៍ទៅកាន់បណ្តាប្រៃសណីយ៍គ្រប់ខេត្ត-ក្រុង គ្រប់ប្រភេទទៅអង្គការសហភាពប្រៃសណីយ៍សកល និងទៅអង្គការប្រៃសណីយ៍តំបន់ ។ នៅលើបញ្ញើត្រូវវាយត្រា។

❖ បញ្ញើផ្ញើទៅអោយអ្នកជាប់ទោសស៊ីវិល ឬ ឈ្លើយសឹក ត្រូវវាយត្រា ឬ លើបញ្ញើ អាចអនុញ្ញាតអោយផ្ញើត្រឹមទំងន់ ៥ គីឡូក្រាម ។

❖ សំភារៈសិក្សាសំរាប់មនុស្សខ្វាក់: ត្រូវវាយត្រាលើបញ្ញើ ។

---

[១០] (ព័ត៌មានលំអិតសូមចុចចូលក្នុងគេហទំព័ររបស់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (http://www.customs.gov.kh/km/)

ក្នុងចំនុចទី ២ និង ទី៣ អាចលើកលែងតែអាករប្រៃសណីយ៍ និងអាករបន្ទាប់បន្សំ (ប្រសិនបើមាន) ចំពោះការផ្ញើតាម យន្តហោះត្រូវគិតទៅតាមកន្លែងទទួល ដូចមានចែងលំអិតក្នុងតារាងពន្ធអាករប្រៃសណីយ៍ ។

## ១.៥ ច្បាប់ស្តីពីវិស័យប្រៃសណីយ៍

ច្បាប់នេះមានគោលដៅកំណត់លើការងារសេវាកម្ម អាជីវកម្មប្រៃសណីយ៍ក្នុង និងក្រៅប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ។ ការងារសេវាកម្ម និងអាជីវកម្មប្រៃសណីយ៍គ្រប់ប្រភេទនៃព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្រោមសមត្ថកិច្ចដឹកនាំគ្រប់គ្រង និងចាត់ចែងដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

អតិថិជនអាចផ្ញើបញ្ញើគ្រប់ប្រភេទក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា និងទៅកាន់អន្តរជាតិ លើកលែងតែវត្ថុដែលត្រូវហាមឃាត់ដូចខាងក្រោមនេះ៖

ក. សម្ភារៈទាំងឡាយដែលវេចខ្ចប់មិនបានល្អ អាចបណ្តាលឲ្យមានគ្រោះថ្នាក់ឬធ្វើឲ្យខូចខាតដល់បញ្ញើដទៃទៀត ។

ខ. គ្រឿងញៀនគ្រប់ប្រភេទ និងប្រភេទទំនិញដទៃទៀតដែលច្បាប់ហាមឃាត់

គ. រូបធាតុដែលអាចផ្ទុះ ងាយឆាបឆេះ ឬរូបធាតុផ្សេងៗទៀតដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ ។

ឃ. វត្ថុដែលមានភាពអាសអាភាស ប៉ះពាល់ដល់សីលធម៌សង្គម និងវត្ថុដែលមានខ្លឹមសារប៉ះពាល់ដល់ច្បាប់រដ្ឋ សន្តិសុខ និងរបៀបរៀបរយសង្គម ។

ង. វត្ថុដែលត្រូវហាមឃាត់ដោយប្រទេសទទួល ។

## ១.៦ ការគ្រប់គ្រងបញ្ញើប្រៃសណីយ៍

ការគ្រប់គ្រងបញ្ញើ ពិតជាមានសារៈសំខាន់ក្នុងប្រតិបត្តិការ នៃការនាំចេញបញ្ញើប្រៃសណីយ៍ជាប្រចាំថ្ងៃ ក៏ដូចជាការរួមចំណែកនិងជួយសម្រួលទៅដល់ការធ្វើពាណិជ្ជកម្ម អោយទទួលបាននូវប្រសិទ្ធិភាព និងប្រសិទ្ធិផល ។ ការគ្រប់គ្រងបញ្ញើប្រៃសណីយ៍រួមបញ្ចូលនូវ៖

### ១.៦.១ ប្រព័ន្ធនៃការតាមដានបញ្ញើ

មជ្ឈមណ្ឌលបច្ចេកវិទ្យាប្រៃសណីយ៍របស់សហភាពប្រៃសណីយ៍សកល UPU ដោយក្នុងកិច្ចសហប្រតិបត្តិការជាមួយសហគ្រាសប្រៃសណីយ៍ជាច្រើនទៀត នៅជុំវិញពិភពលោក បានធ្វើការអភិវឌ្ឍប្រព័ន្ធប្រៃសណីយ៍អន្តរជាតិ (IPS) ឡើងដោយសារមានតម្រូវការក្នុងការសម្រួលដល់ការគ្រប់គ្រងបញ្ញើតាមរយៈបង្កើតកម្មវិធីកុំព្យូទ័រ ។ វាត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 1995 ។ប្រព័ន្ធ

IPS គឺជាកម្មវិធីគ្រប់គ្រងបញ្ញើមួយដែលរួមបញ្ចូលគ្នានូវ ដំណើរការនៃការផ្ញើ, ការគ្រប់គ្រងលើប្រតិបត្តិការ និងការផ្ញើសារ EDI ទៅក្នុងកម្មវិធីមួយ ។ ប្រព័ន្ធ IPS ផ្តល់នូវមធ្យោបាយសម្រាប់សហគ្រាសប្រៃសណីយ៍ឱ្យមានជាទស្សនៈត្រឹមត្រូវ និងទូលំទូលាយនៃចលនារបស់ពួកគេ ក្នុងការគ្របដណ្តប់គ្រប់ចំណុចទាំងអស់រវាងចំណុចចាប់ផ្តើម និងចំណុចបញ្ចប់ ព្រមទាំងការផ្លាស់ប្តូរឆ្លងកាត់ការិយាល័យ, ក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិ និងការដោះស្រាយតាមរយៈភ្នាក់ងារគយ ។ ម្យ៉ាងវិញទៀតប្រព័ន្ធIPS ក៏បានផ្តល់តួនាទីសំខាន់មួយក្នុងការសម្រួលដល់អតិថិជនដែលបានផ្ញើរបញ្ញើប្រៃសណីយ៍នៅប្រៃសណីយ៍កម្ពុជារួច អាចធ្វើការតាមដានពីព័ត៍មាន រយៈពេល និងតម្រាយផ្លូវដែលបញ្ញើទៅដល់ និងអាចដឹងថាកញ្ចប់បញ្ញើនោះដល់ទីកន្លែងណា ជាប់នៅឃ្លាំងគយ ឬអ្នកទទួលបានទទួលរួចរាល់ហើយ ។ ការតាមដាននេះធ្វើឡើងតាមរយៈលេខកូដ៩ខ្ទង់(Tracking Number) ដែលអាចអោយពួកគេទទួលបានព័ត៍មានទាំងបញ្ញើក្នុងប្រទេស និងក្រៅប្រទេស ។

- ប្រព័ន្ធ IPS គាំទ្រមុខងារគ្រប់គ្រងសំបុត្រចូលនិងក្រៅស្រុកពេញលេញ, រួមបញ្ចូលទាំង:
  - ✓ ការស្កេនវត្ថុនិងលេខបារកូដ
  - ✓ កាលវិភាគប្រាប់ផ្លូវ : វាក៏មានអនុញ្ញាតឲ្យយើងអាចតាមដានពីកាលវិភាគជើងហោះហើរ តម្រាយផ្លូវយន្តហោះ ដឹងថាបញ្ញើកំពុងស្ថិតនៅត្រង់ចំណុចណាមួយ។ល។
  - ✓ ការគ្រប់គ្រងការបញ្ជូនដោយស្វ័យប្រវត្តិ
  - ✓ សាកសួរលម្អិតពីការផ្ញើរ ការបញ្ជូននិងប្រគល់ទទួល : លក្ខណៈពិសេសនៃការតាមដាននិងសាកសួរនៅក្នុង IPS អនុញ្ញាតឱ្យសហគ្រាសប្រៃសណីយ៍តាមដានដំណើរការបញ្ជូនទំនិញទាំងអស់ដែលបានកំណត់ ។
  - ✓ បោះពុម្ពដោយស្វ័យប្រវត្តិនៃសលាប័ត្រស្តង់ដារ និងឯកសាររបស់UPU
  - ✓ ការផ្លាស់ប្តូរសារឆ្លើយឆ្លង EDI អំពីវត្ថុ លេខកបារនិងព័ត៌មានផ្សេងៗ : IPS ជួយបង្កើនល្បឿន និងភាពត្រឹមត្រូវនៃព័ត៌មានស្វ័យប្រវត្តិកម្មនៃប្រតិបត្តិការ និងការផ្លាស់ប្តូរសារអេឡិចត្រូនិក ។ IPS គាំទ្រគ្រប់ស្តង់ដារដែលបានអនុម័តដោយ UPU សម្រាប់ការផ្ញើសារ បារកូដ និងការកំណត់អត្តសញ្ញាណនិងតាមដានតាមអ៊ីម៉ែល ។

✓ គណនេយ្យអន្តរជាតិ : IPS ដោះស្រាយនូវរាល់ដំណើរការគណនេយ្យទាំងអស់រួមមានថ្លៃដឹកជញ្ជូន កម្រៃឆ្លងកាត់ និងសេវាតាមក្រុមហ៊ុនអាកាសចរណ៍ ដោយត្រូវធ្វើរបាយការណ៍ប្រចាំខែ និងប្រចាំត្រីមាស[១១] ។

### ១.៦.២ ការប្រើប្រាស់នូវម៉ាស៊ីនស្កេន

ម៉ាស៊ីនស្កេនត្រូវបានបំពាក់នៅប្រៃសណីយ៍កម្ពុជា ក្រោមជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរាវរកវត្ថុហាមឃាត់ និងគ្រឿងញៀន។ គ្រប់ទំនិញទាំងអស់មុននឹងធ្វើការនាំចេញ ឬនាំចូលទៅកាន់ប្រទេសក្រៅ ឬពីក្រៅប្រទេសត្រូវនាំចូលក្នុងស្រុក គឺសុទ្ធសឹងតែបានឆ្លងកាត់ការត្រួតពិនិត្យតាមរយៈម៉ាស៊ីនស្កេនបន្ថែមពីលើការត្រួតពិនិត្យរូបវន្ត ដើម្បីជៀសវៀងចំណុចមិនប្រក្រតីកើតឡើង ។ ជាក់ស្តែងក្នុងការត្រួតពិនិត្យ រាល់ទំនិញទាំងអស់នោះ វាមិនមែនសុទ្ធតែអាចមើលឃើញអោយភ្នែកទទេរបានទេ ដូចនេះទាមទារឲ្យមានការប្រើប្រាស់នូវម៉ាស៊ីនស្កេនដែលមានបច្ចេកវិទ្យាកាន់តែទំនើប ជឿនលឿន ទើបអាចអោយការត្រួតពិនិត្យកាន់តែមានភាពសុក្រឹត្យ និងអាចគ្រប់គ្រង់លើហានិភ័យបាន។

### ១.៦.៣ ការប្រើប្រាស់នូវវិបសាយផ្លូវការរបស់ប្រៃសណីយ៍កម្ពុជា

ការប្រើប្រាស់នូវ Website បានផ្តល់នូវភាពងាយស្រួលទៅដល់អតិថិជនទូទៅ អោយទទួលបាននូវចំណេះដឹង ការយល់ដឹងអំពីការទទួល ការផ្ញើ ការគណនាតម្លៃផ្ញើ និងលេខកូដតំបន់ផងដែរ ។ លើសពីនេះទៅទៀតការប្រើប្រាស់បែបនេះ អាចអោយក្រុមហ៊ុនប្រៃសណីយ៍អាចដឹងមុនពីហានិភ័យ ព្រមទាំងអាចគ្រប់គ្រង់នូវហានិភ័យនានា តាមរយៈការរិះគន់របស់អតិថិជន បន្ទាប់ពីពួកគេបានស្វែងយល់ដឹងពីការប្រើប្រាស់នូវប្រព័ន្ធប្រៃសណីយ៍កម្ពុជា ។

**រូបភាពទី៥៖ គេហទំព័រផ្លូវការរបស់ប្រៃសណីយ៍កម្ពុជា**




[១១] សៀវភៅឈ្មោះខួប២០ឆ្នាំនៃប្រព័ន្ធប្រៃសណីយ៍អន្តរជាតិ បោះពុម្ពផ្សាយខែសីហា ឆ្នាំ២០១៦ ដោយUPU

ក្រៅពីនេះ ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជាក៏បានបញ្ចូលតំណរភ្ជាប់ (link) សម្រាប់ទំនាក់ទំនង និងសាកសួរព័ត៌មានជាច្រើនទៀត អំពីការផ្ញើ តម្លៃ ទម្ងន់ដែលអាចផ្ញើបាន វត្ថុហាមឃាត់ និង កាតព្វកិច្ចពន្ធជាដើមរបស់ប្រទេសដទៃទៀតដែលជាសមាជិកUPUផងដែរ ។ (មើលឧបសម្ព័ន្ធទី៥)

### ១.៦.៤ ប្រព័ន្ធគ្រប់គ្រងគុណភាពសេវាកម្ម

មិនអាចមានការអភិវឌ្ឍន៍នៃទីផ្សារប្រៃសណីយ៍ ដោយគ្មានការត្រួតពិនិត្យផ្នែកគុណភាព នោះទេ ។ គ្រប់ប្រតិបត្តិការប្រៃសណីយ៍ទាំងអស់ព្យាយាមធ្វើឲ្យសេវាកម្មរបស់ខ្លួនមានភាពប្រសើរ ឡើង ក្នុងគោលបំណងរក្សាបាននូវអតិថិជនរបស់ខ្លួន ដើម្បីឈរជើងលើទីផ្សារបានយូរអង្វែង និង មានលទ្ធភាពប្រកួតប្រជែង ។ សហជីពប្រៃសណីយ៍សកល UPU បានបង្កើតកម្មវិធីជាច្រើន រួម ទាំងការបន្តធ្វើតេស្តលើការវាស់វែង និងវាយតម្លៃលើគុណភាពនៃសេវាកម្មសម្រាប់តំណរភ្ជាប់ (link) អន្តរជាតិចំនួន៧០០, ការបង្កើតបារកូដសម្រាប់ឆែកនិងតាមដានបញ្ញើ, ការកំណត់នូវស្តង់ ការដឹកជញ្ជូនពីចំណុចចាប់ផ្តើមរហូតដល់ចប់, និងការណែនាំស្តង់ដារ J+5 (ដឹកជញ្ជូននៅថ្ងៃទី៥នៃ ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃដែលបានផ្ញើ) សម្រាប់៨០% នៃបញ្ញើអន្តរជាតិ ។

គុណភាពអាច ប្រសើរជាងមុនប្រសិនបើវាត្រូវបានគេវាស់ស្ទង់ ។ ប្រព័ន្ធត្រួតពិនិត្យសកល (GMS) គឺជាប្រព័ន្ធនៃរង្វាស់ដែលមានកម្រិតខ្ពស់ ដែលគ្រប់គ្រងដោយទីស្នាក់ការកណ្តាលរបស់ UPU ។ គោលបំណងចម្បងរបស់ប្រព័ន្ធនេះ គឺជួយឲ្យបុគ្គលពាក់ព័ន្ធទទួលបាននូវលទ្ធភាពលើការ ប្រតិបត្តិការងារប្រកបដោយគុណភាពខ្ពស់ និងមានប្រសិទ្ធិភាព ។ ព័ត៌មាននេះប្រើប្រាស់ក្នុង គោលដៅរួមចំណែកដល់ការសម្រេចចិត្តអំពីការកែលម្អដំណើរការ និងគុណភាព ។ តើGMSមាន មុខងារនិងតួនាទីអ្វីខ្លះ ? ប្រព័ន្ធGMS ត្រូវបានបង្កើតឡើងដើម្បីប៉ាន់ស្មានពេលវេលាដឹកជញ្ជូន សម្រាប់លិខិត ដែលត្រូវជ្រើសរើសក្នុងចំណោមលិខិតចំនួន431ប៊ីលានច្បាប់ រៀងរាល់ប្រចាំឆ្នាំនៅ ទូទាំងពិភពលោក ។ នៅក្នុងប្រទេសនានាជាច្រើន កញ្ចប់បញ្ញើនីមួយៗត្រូវគេតាមដានដឹង ដោយសារតែមធ្យោបាយបច្ចេកវិទ្យាបារកូដ ។ UPU ប្រើប្រាស់ឧបករណ៍កំណត់អត្តសញ្ញាណ រលកវិទ្យុ (RFID) បង្ហោះតាមរយៈផ្កាយរណប ដើម្បីចាប់មើលពីពេលវេលា នៃការផ្ញើនិងដំណើរ ការ សម្រាប់គ្រប់គ្រងគុណភាពសេវាកម្មរបស់ខ្លួន ។ ប្រព័ន្ធនេះត្រូវបានដាក់ឲ្យប្រើប្រាស់នៅ ប្រទេសជាសមាជិកចំនួន១៩១ប្រទេស និងមាន៦៥០,០០០ការិយាល័យប្រៃសណីយ៍ រួមមានទាំង ប្រទេសកម្ពុជាយើងផងដែរ ។ ដោយសារតែមានប្រព័ន្ធត្រួតពិនិត្យសកលGMSនេះហើយ ទើប ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជាអាចធ្វើការប៉ាន់ស្មាន និងសន្យាចំពោះអតិថិជនបានថា បញ្ញើដែល ពួកគេបានផ្ញើនឹងត្រូវទៅដល់ក្នុងរយៈពេលប៉ុន្មានថ្ងៃដើម្បីទៅដល់ប្រទេសគម្យដ្ឋាន និងថាតើ

កញ្ចប់បញ្ញើមានគុណភាពកម្រិតណា ។ នីតិវិធីទូទៅ គឺអ្នកផ្ញើយកសំបុត្រទៅផ្ញើនៅប្រៃសណីយ៍កម្ពុជា បន្ទាប់មកសំបុត្រត្រូវបញ្ជូនទៅការិយាល័យចុងទី ហើយការិយាល័យចុងទីជាអ្នកកំណត់ពេលវេលាដឹកជញ្ជូននិងពេលវេលាមកដល់ដោយបច្ចេកវិទ្យា RFID ។ បញ្ញើត្រូវបញ្ជូនទៅការិយាល័យដឹកជញ្ជូន រួចចែកចាយឲ្យអ្នកទទួល ។

**រូបភាពទី៦៖ បញ្ញត្តិទូទៅនៃប្រព័ន្ធត្រួតពិនិត្យសកល**




## ១.៦.៥ ការរក្សាការសម្ងាត់

ការធានាសិទ្ធិមិនឲ្យរំលោភលើអាថ៌កំបាំងនៃសំបុត្រ កញ្ចប់តូច និងប្រៃសណីយ៍ភ័ណ្ឌត្រូវបានធានាតាមវិធានការ ដូចខាងក្រោម៖

-ហាមបើកសំបុត្រ និងវត្ថុបញ្ញើដែលត្រូវបានបិទជិត

-ហាមផ្តល់ព័ត៌មានអំពីដំណើរប្រៃសណីយ៍នៃសំបុត្រ និងបញ្ញើរបស់អ្នកណាម្នាក់ ឬអំពីខ្លឹមសាររបស់សំបុត្រ និងបញ្ញើនោះឲ្យទៅអ្នកដទៃ

-ហាមផ្តល់លទ្ធភាព ឬជួយដល់ទង្វើទាំងឡាយខាងលើ ។

ការផ្តល់ពត៌មានអំពីដំណើរសេវាបញ្ជូនប្រាក់តាមប្រៃសណីយ៍ អនុញ្ញាតឲ្យធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីម្ចាស់បញ្ញើរៀវលែង តែក្នុងករណីជាករណីកិច្ចផ្តល់ពត៌មានដែលច្បាប់តម្រូវឲ្យធ្វើ ឬមានដីកាតុលាការដែលបញ្ជាក់ច្បាស់លាស់ទៅលើបញ្ញើណាមួយប្រាកដ ។

# ជំពូកទី ២
# ការអនុវត្តន៍លើកញ្ចប់បញ្ញើនាំចេញនៃវិស័យប្រៃសណីយ៍កម្ពុជា

## ២.១ ស្ថានភាពទូទៅ

### ២.១.១ ប្រវត្តិ

ការិយាល័យប្រៃសណីយ៍ បានសាងសង់ឡើងនាឆ្នាំ១៨៩៥ មានទីតាំងនៅក្នុងសង្កាត់អឺរ៉ុប ឬសង្កាត់បារាំង ហើយបានសាងសងដោយស្ថាបត្យករលោកដានីញែលហ្វាប្រ៉េ ។ នៅឆ្នាំ១៩៤៩ ប្រទេសកម្ពុជា បានប្រែក្លាយជារដ្ឋដែលជាប់ទាក់ទងនៃសហភាពបារាំង ហើយក៏បានប្រើប្រព័ន្ធប្រៃសណីយ៍ចាប់ពីអំឡុងឆ្នាំ១៩៥០។ បន្ទាប់មកនៅឆ្នាំ១៩៥១ តែមប្រើប្រៃសណីយ៍ គឺត្រូវបានបោះពុម្ពអោយប្រើប្រាស់មុនគេ ដោយមានឈ្មោះថា និងអក្សរសសេរថា Royaume du Cambodge ដែលបានបង្ហាញ ពីព្រះបាទនរោត្តមសីហនុ ។ ប៉ុន្តែដោយការទទួលបានឯករាជ្យភាពនៅឆ្នាំ ១៩៥៣ ប្រទេសកម្ពុជាក៏បានចាកចេញពីសហភាពនេះនៅឆ្នាំ១៩៥៥ផងដែរ ។ ជាក់ស្តែងនៅឆ្នាំ ១៩៧០ ដែលជារបបប្រល័យពូជសាសន៍ ប៉ុល ពត សង្គ្រាមផ្ទុះឡើង បានធ្វើអោយប្រៃសណីយ៍ កម្ពុជាស្ទើរតែមិនអាចដំណើរការបាន រហូតដល់ឆ្នាំ១៩៧៥ គឺត្រូវបានផ្អាកដំណើរការ។ ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រៃសណីយ៍កម្ពុជា ត្រូវបានបើកដំណើរការឡើងវិញ ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាលាក្រុងភ្នំពេញ ។ ក្នុងឆ្នាំ១៩៩៣ ប្រៃសណីយ៍កម្ពុជា បានប្រែក្លាយជារដ្ឋលេខាធិការដ្ឋានប្រៃសណីយ៍ និងទូគមនាគមន៍។ លើសពីនេះទៅទៀត នៅឆ្នាំ១៩៩៦ ប្រៃសណីយ៍កម្ពុជា បានក្លាយទៅជារដ្ឋលេខាធិការដ្ឋានប្រៃសណីយ៍ និងទូគមនាមន៍តាមច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ ។ នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១១ រដ្ឋាភិបាលកម្ពុជាបានដាក់អោយដំណើរការជាផ្លូវការសហគ្រាសសាធារណៈ ។

នាពេលបច្ចុប្បន្ននេះ ប្រៃសណីយ៍កម្ពុជា បានដំណើរការអស់រយៈពេល៦៨ឆ្នាំ ហើយក៏ជាអង្គការស្វយ័តភាពស្ថិត ក្រោមការគ្រប់គ្រងរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគម៍ ដោយមានន័យថា ប្រៃសណីយ៍កម្ពុជាជាអង្គភាពស្វែងរកប្រាក់ចំណេញ ប៉ុន្តែស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ។ បន្ថែមលើនេះ ប្រៃសណីយ៍កម្ពុជាជាអង្គភាពផ្តល់សេវាកម្មទទួលផ្ញើ និងចែកចាយកញ្ចប់បញ្ញើទូទាំងពិភពលោក និងទូទាំង២៤ខេត្ត-ក្រុង ក្នុងប្រទេសកម្ពុជា ។ មិនតែប៉ុណ្ណោះ ប្រៃសណីយ៍កម្ពុជាមិនត្រឹមតែផ្តល់សេវាកម្មចែកចាយបញ្ញើនោះទេ ប្រៃសណីយ៍កម្ពុជាក៏មានជាសេវាកម្មផ្ទេរប្រាក់ (EMO) សេវាកម្មដឹកជញ្ជូនអ្នកដំណើរ សេវាកម្មជួលប្រអប់សំបុត្រ និងការលក់តែមប្រ៊ីសម្រាប់បិទលើសំបុត្រ។

### ២.១.២ ទីតាំងរបស់ក្រុមហ៊ុន

ប្រៃសណីយ៍កម្ពុជា មានទីតាំងអាជីវកម្មមូលដ្ឋានសំខាន់ៗ ចំនួន៥៤កន្លែងក្នុងរាជធានីភ្នំពេញ-ខេត្តក្នុងព្រះរាជាណាចក្រកម្ពុជា ។

ទីស្នាក់ការប្រៃសណីយ៍កម្ពុជាកណ្ដាលស្ថិតនៅផ្លូវ១០២ កែងផ្លូវ១៣ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ និងសាខាប្រៃសណីយ៍តាមខេត្តដូចជា៖

-សាខាប្រៃសណីយ៍ខេត្តកំពត
-សាខាប្រៃសណីយ៍កំពង់ចាម
-សាខាប្រៃសណីយ៍ខេត្តព្រៃវែង
-សាខាប្រៃសណីយ៍ខេត្តប៉ៃលិន
-សាខាប្រៃសណីយ៍ខេត្តមណ្ឌលគិរី
-សាខាប្រៃសណីយ៍ខេត្តកែប
-សាខាប្រៃសណីយ៍ខេត្តបន្ទាយមានជ័យ
-សាខាប្រៃសណីយ៍ខេត្តកណ្ដាល
-សាខាប្រៃសណីយ៍ខេត្តកំពង់ធំ
-សាខាប្រៃសណីយ៍ខេត្តត្បូងឃ្មុំ
-សាខាប្រៃសណីយ៍ខេត្តស្ទឹងត្រែង
-សាខាប្រៃសណីយ៍ខេត្តសៀមរាប
-សាខាប្រៃសណីយ៍ខេត្តកំពត
-សាខាប្រៃសណីយ៍ខេត្តក្រចេះ
-សាខាប្រៃសណីយ៍ខេត្តព្រះសីហនុ
-សាខាប្រៃសណីយ៍ខេត្តឧត្តរមានជ័យ
-សាខាប្រៃសណីយ៍ខេត្តតាកែវ
-សាខាប្រៃសណីយ៍ខេត្តកំពង់ឆ្នាំង
-សាខាប្រៃសណីយ៍ខេត្តពោធិ៍សាត់
-សាខាប្រៃសណីយ៍ខេត្តស្វាយរៀង
-សាខាប្រៃសណីយ៍ខេត្តរតនៈគិរី
-សាខាប្រៃសណីយ៍ខេត្តព្រះវិហារ
-សាខាប្រៃសណីយ៍ខេត្តកោះកុង
-សាខាប្រៃសណីយ៍ខេត្តកំពត ។

### ២.១.៣ ទស្សនៈវិស័យ

ផ្អែកលើការអនុវត្តការងារដោយស្វ័យភាព លើការងាររដ្ឋបាលអាជីវកម្ម និងហិរញ្ញវត្ថុដោយក្រុមប្រឹក្សាភិបាល គឺជាអ្នកដឹកនាំស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយក្នុងគោលបំណងជួយជំរុញកំណើនសេដ្ឋកិច្ចសង្គម ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកំពស់កម្រិតជីវភាពនិយោជិត។ ម្យ៉ាងវិញទៀត ប្រៃសណីយ៍កម្ពុជា បានបន្តការអនុវត្តកម្មវិធីកំណែទំរង់ស៊ីជម្រៅទាំងផ្នែករចនាសម្ព័ន្ធរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីរួមចំណែកក្នុងការធ្វើទំនើបកម្មសេវាប្រៃសណីយ៍ ប្រកបដោយគុណភាពស្របទៅតាមស្តង់ដារអន្តរជាតិ ដោយមានតម្លៃថោកសមរម្យ និងបានបង្កភាពងាយស្រួលអោយប្រជាជនអាចប្រើប្រាស់ ព្រមទាំងទទួលបាន នូវផលប្រយោជន៍ពីវិស័យប្រៃសណីយ៍គ្រប់ៗគ្នាទូទាំងប្រទេស។

**ក.គោលដៅ និងគោលបំណង**

សម្រាប់គោលដៅ និងគោលបំណងរបស់ប្រៃសណីយ៍កម្ពុជា គឺចង់បំរើសេវាកម្ម អាជីវកម្ម ប្រៃសណីយ៍ទាំងក្នុង និងក្រៅប្រទេសគ្រប់ប្រភេទ។

**ខ. បេសកម្ម និងភារកិច្ច**

បេសកម្ម និងភារកិច្ចរបស់វិស័យប្រៃសណីយ៍កម្ពុជា រួមមាន៖

- បម្រើសេវាទទួល ដឹកជញ្ជូន និងចែកចាយបញ្ញើ
- បញ្ញើសំបុត្រគ្រប់ប្រភេទ
- បញ្ញើប្រៃសណីយ៍ភ័ណ្ឌ និងបញ្ញើឆាប់រហ័សក្នុង និងក្រៅប្រទេស
- បម្រើសេវាទទួល និងបែងចែកវិក័យបត្ររបស់ស្ថាប័នរដ្ឋ ក្រុមហ៊ុន និងអង្គការនានាតាមកិច្ចព្រមព្រៀង
- លក់តែមប្រៃសណីយ៍នៅតាមបញ្ជរភ្នាក់ងារប្រៃសណីយ៍ទាំងក្នុង និងក្រៅប្រទេស
- លក់សំភារៈផលិតផលសម្រាប់បំរើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍
- បម្រើសេវាប្រអប់សំបុត្រជួលជាវ
- បម្រើសេវាដឹកជញ្ជូនអ្នកដំណើរ
- បម្រើសេវាបញ្ជូនព័ត៌មាន មានរូបភាពទូរគមនាគមន៍ និងតាមរយៈបណ្ដាញផ្សេងៗទៀតអោយមានការរីកចម្រើនរបស់វិស័យទូរគមនាគមន៍ និងព័ត៌មានវិទ្យា
- បម្រើសេវាប្រៃសណីយ៍ផ្សេងៗទៀត ដោយអាស្រ័យទៅតាមការរីកចម្រើនរបស់ប្រៃសណីយ៍។

**២.១.៤ ស្លាកសញ្ញា និងពាក្យស្លោក**

-ពាក្យថា "ប.ក." គឺអក្សរកាត់ជាភាសាខ្មែរ មានន័យថា ប្រៃសណីយ៍កម្ពុជា ។

-ពាក្យថា "C.P." គឺអក្សរកាត់ជាភាសាអង់គ្លេស មានន័យថា Cambodia Post ។

-រូបផែនដី តំណាងថា ប្រៃសណីយ៍កម្ពុជាជាសេវាកម្មដែលមានសកម្មភាពទូទាំងពិភពលោក (Worldwide)។

-រូបសំបុត្រនៅចំកណ្តាល តំណាងឲ្យប្រវត្តិប្រៃសណីយ៍នាពេលដំបូង គឺជាសាររបស់ព្រះមហាក្សត្រ ដែលនៅពេលនោះព្រះអង្គទ្រង់បោះបង់ពីការប្រើប្រាស់ព្រាបនាំសារ ទៅជាការផ្ញើតាមរទេះសេះ ឈ្មួញដឹកជញ្ជូនទំនិញ ឬមន្ត្រីរាជការដែលចេញចូលក្នុងរាជវាំងនាំសារទៅថ្វាយស្តេចនៅនគរផ្សេង ឬមន្ត្រីនៅតាមមូលដ្ឋាន ។ ក្រោយមកក៏ក្លាយទៅជាការផ្ញើជាលក្ខណៈកញ្ចប់ធំៗ និងពេញនិយមរបស់មកដល់សព្វថ្ងៃ ។ [យោងសម្តីរបស់បុគ្គលិកម្នាក់ធ្វើការនៅប្រៃសណីយ៍កម្ពុជា]

-ខ្សែឆ្នូតនៃរង្វង់ផ្នែកខាងលើ តំណាងឲ្យការធ្វើការជាបណ្តាញ ដែលទាមទារឲ្យមានកិច្ចសហការណ៍ និងសាមគ្គីភាពគ្នាទៅវិញទៅមក ។

-ចំនែកឯរង្វង់ផ្នែកខាងក្រោម តំណាងឲ្យខ្សែចង្វាក់ផលិតកម្ម និងចរន្តនៃលំហូរទំនិញនាំចេញ នាំចូល ។

ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជាមានពាក្យស្លោក ថា "**បានដល់គ្រប់គ្នា គ្រប់ទីកន្លែង...**" ដែលមានន័យថាគ្រប់កញ្ចប់បញ្ញើប្រៃសណីយ៍ទាំងអស់ត្រូវបានផ្ញើ បញ្ជូន ទទួល និងឆ្លងកាត់ទៅដល់ដៃគ្រប់បុគ្គល គ្រប់ជាតិសាសន៍ គ្រប់ទីកន្លែងក្នុងប្រទេស និង គ្រប់១៩២ប្រទេសដែលជាសមាជិកនៃសហភាពប្រៃសណីយ៍សកល (UPU) ទាំងបញ្ញើបិតជិត និងបញ្ញើដោយចំហរ ។

### ២.១.៥ សក្តានុពលសេដ្ឋកិច្ច

ក្រោយពីធ្វើស្វ័យយ័តកម្មរួចមក ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជាបានអភិវឌ្ឍន៍ខ្លួនយ៉ាងខ្លាំងក្លាទៅក្នុងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជាដោយបានពង្រីក និងបានបង្កើតនូវសេវាកម្មថ្មីៗជាច្រើនក្នុងទីផ្សារប្រកួតប្រជែងមួយនេះ ។ ក្នុងនោះដែរ នៅឆមាសទី២ ឆ្នាំ២០១៧នេះ ក្រុមហ៊ុនប្រៃសណីយ៍គ្រោងនឹងបង្កើតសេវាកម្មថ្មីប្លែកមួយទៀត គឺ E-Commerce សម្រាប់ផ្តល់សេវាដូចជា Online Shopping, Online Ticketing (BOOKMEBUS), E-payment, E-banking, Logistics and Courier ដែលជួយសម្រួលដល់អតិថជនក្នុងការទិញទំនិញតាមអនឡាញ និងងាយស្រួលក្នុងការទូរទាត់សាច់ប្រាក់ ។ បើតាមរបាយការណ៍ដែលបានធ្វើការបូកសរុប លទ្ធផលការងារនៅឆ្នាំ២០១៦របស់ប្រៃសណីយ៍កម្ពុជាបានបញ្ជាក់ថា ប្រាក់ចំណូលរបស់ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជា បានកើនឡើងដល់៩,៤៥លានដុល្លារសហរដ្ឋអាមេរិកកាលពីឆ្នាំមុន ដែលកើនឡើង៧៤%ធៀបនឹង៥,៤២លានដុល្លារសហរដ្ឋអាមេរិកកាលពីឆ្នាំ២០១៥ ។ ប្រាក់ចំណេញ ដែលក្រុមហ៊ុនប្រៃសណីយ៍ទទួល

បាន គឺមានចំនួន៥៨៦.៨៨១ដុល្លារសហរដ្ឋអាមេរិក ដែលបានកើនឡើង១៩៥%ធៀបនឹងឆ្នាំ២០១៥[១២] ។

## ២.២ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជា

### ២.២.១ តួនាទី និងភារកិច្ច

ប្រៃសណីយ៍កម្ពុជា គឺជាសរសៃឈាមមួយ នៃសហជីពប្រៃសណីយ៍សកល (UPU) ដែលបម្រើសេវាកម្មអាជីវកម្មប្រៃសណីយ៍ក្នុង និងក្រៅប្រទេសគ្រប់ប្រភេទដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ និន្នាការនយោបាយ និងសាសនា ។ ប្រៃសណីយ៍កម្ពុជា សហការជាមួយបណ្តាប្រទេសជាដៃគូរ ដោយរួមមានទាំងប្រទេសជាសមាជិកនៃសហជីពប្រៃសណីយ៍សកល (UPU) ក្នុងកិច្ចការទទួលប្រមូលដឹកជញ្ជូន និងបែងចែករាល់បញ្ញើប្រៃសណីយ៍គ្រប់ប្រភេទទាំងអស់ ដោយធ្វើយ៉ាងណាអោយបញ្ញើទាំងនោះមានសុវត្ថិភាព ភាពឆាប់រហ័ស និងការទទួលបាននូវទំនុកចិត្ត ពីសំណាក់អតិថិជនទូទៅ ។

**រូបភាពទី៧៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ប្រៃសណីយ៍កម្ពុជា**




[១២] គេហទំព័រ: http://m.postkhmer.com/សេដ្ឋកិច្ច/ប្រៃសណីយ៍កម្ពុជា-នឹងបង្កើតក្រុមហ៊ុនសេវាអនឡាញ

រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជាមានលក្ខណៈជាសាជីវកម្ម ដែលក្នុងនោះមានសមាសភាពដូចជាៈ

ក.ក្រុមប្រឹក្សាភិបាលៈ មានតួនាទីជ្រើសតាំងនាយកគ្រប់គ្រង(CEO) និងអ្នកគ្រប់គ្រងទូទៅ (General Manager) ដែលមានតួនាទីយ៉ាងសំខាន់ និងច្បាស់លាស់ក្នុងការទទួលខុសត្រូវនៅក្នុងអង្គភាពទាំងមូល ។ ក្រុមប្រឹក្សាភិបាលធ្វើការវាយតម្លៃនូវទិសដៅជារួម និងយុទ្ធសាស្ត្ររបស់អង្គភាព ។ ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវសំខាន់ៗចំនួន០៦គឺៈ

- ✓ ជ្រើសរើស មើលការខុសត្រូវ រក្សាទុក វាយតម្លៃ និងទូទាត់ចំពោះអ្នកគ្រប់គ្រង (CEO &General Manager)
- ✓ ធ្វើការត្រួសត្រាយផ្លូវ ចក្ខុវិស័យ បេសកកម្ម និងគោលដៅសម្រាប់អង្គភាព
- ✓ បង្កើតគោលនយោបាយជាលក្ខណៈជាប្រព័ន្ធ
- ✓ ដឹកនាំ អភិវឌ្ឍន៍អង្គភាព និងទំនាក់ទំនងល្អជាមួយ CEO
- ✓ កាតព្វកិច្ចផ្តល់នូវទំនុកចិត្ត ក្នុងការការពារទ្រព្យសកម្មរបស់អង្គភាព និងវិនិយោគរបស់សមាជិក
- ✓ ត្រួតពិនិត្យឡើងវិញ ឬសវនកម្មប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ។

ខ.លេខាក្រុមប្រឹក្សាភិបាល : មានតួនាទីជាអ្នកជួយសម្របសម្រួល និងសម្រាលបន្ទុករាល់ការងារទាំងអស់របស់ក្រុមប្រឹក្សាភិបាល (BOD) ។ រៀបចំកាលវិភាគប្រជុំប្រចាំខែ របៀបវារៈការងារ និងសម្ភារៈសម្រាប់កិច្ចប្រជុំនីមួយៗ និងជាអ្នកត្រួតពិនិត្យរាល់កិច្ចការងារចំណាយរបស់ក្រុមប្រឹក្សាភិបាល ។

គ.អគ្គនាយក : មានតួនាទីទទួលខុសត្រូវក្នុងការជ្រើសរើស សម្រិតសម្រាំងបុគ្គលិកដទៃទៀត និងចាំឃ្លាំមើលនូវប្រតិបត្តិការ សកម្មភាពនិងដំណើរការពីមួយថ្ងៃទៅមួយថ្ងៃរបស់អង្គភាព ។

- ✓ អគ្គនាយក មានការទទួលខុសត្រូវគន្លឹះៗចំនួន៥គឺៈ

  ១. បង្កើតចក្ខុវិស័យ

  ២.ផ្តល់ឲ្យនូវធនធានត្រឹមត្រូវ

  ៣.បង្កើតបានជាវប្បធម៌ល្អក្នុងការងារ

  ៤. ធ្វើការសម្រេចចិត្តច្បាស់លាស់

  ៥. ព្យាករណ៍ និងដឹកនាំការប្រតិបត្តិរបស់ក្រុមហ៊ុន ឬអង្គភាព

ឃ.ជំនួយការ :មានតួនាទីជាអ្នកជួយសម្របសម្រួល និងជួយសម្រាលរាល់ការងាររបស់អគ្គនាយកផងដែរ ។

ង.អគ្គនាយករង :មានតួនាទីស្ថិតនៅក្រោមអគ្គនាយក និងមានតួនាទីគ្រប់គ្រងបុគ្គលិកទាំងអស់ និងតាមដាននូវប្រតិបត្តិការរបស់របស់បុគ្គលិកក្រោមបង្គាប់តាមរយៈការផ្ទេរអំណាចពីអគ្គនាយក ។

ច.សវនកម្មផ្ទៃក្នុង : មាននាទីជាអ្នកត្រួតពិនិត្យ ស្រាវជ្រាវ គ្រប់ឯកសារ សកម្មភាព និងដំណើរការទាំងអស់ក្នុងក្រុមហ៊ុនទាំងមូល ។

ឆ.នាយកដ្ឋាន : នៅប្រៃសណីយ៍កម្ពុជាមាននាយកដ្ឋានចំនួន០៨ គឺនាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្ស នាយកដ្ឋានផែនការនិងហិរញ្ញវត្ថុ នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានបញ្ញើនិងដឹកជញ្ជូន នាយកដ្ឋានទីផ្សារ នាយកដ្ឋានសេវាហិរញ្ញវត្ថុ នាយកដ្ឋានទូទាត់-ទំនាក់ទំនងអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មានវិទ្យា (IT) ។

នាយកដ្ឋានសំខាន់ៗចំនួនពីរដែលមានតួនាទី និងភារកិច្ចគ្រប់គ្រងបញ្ញើទំនិញនាំចេញតាមប្រៃសណីយ៍ គឺនាយកដ្ឋានអាជីវកម្ម និងនាយកដ្ឋានបញ្ញើ និងដឹកជញ្ជូន ។

- នាយកដ្ឋានអាជីវកម្ម : នាយកដ្ឋានអាជីវកម្មមានការិយាល័យចំណុះចំនួន០៣ គឺការិយាល័យបញ្ជរ ការិយាល័យអាជីវកម្ម និងការិយាល័យតែមប្រិ៍វិទ្យា និងគ្រប់សាខាប្រៃសណីយ៍រាជធានី-ខេត្តទាំងអស់ ។ នាយកដ្ឋាននេះដើរតួនាទីទទួល និងដំណើរការនៃលំហូរបញ្ញើនាំចេញទាំងអស់ដែលអតិថិជនបានផ្ញើនៅក្នុងស្រុក និងអន្តរជាតិ និងជាអ្នករកចំណូលហិរញ្ញវត្ថុសកម្មបំផុតសម្រាប់ជាធនធានប្រើប្រាស់ និងបែងចែកចំណាយរបស់នាយកដ្ឋានដទៃទៀត ។
- នាយកដ្ឋានបញ្ញើនិងដឹកជញ្ជូន : នាយកដ្ឋាននេះមានភារកិច្ចធំៗចំនួន០២យ៉ាង គឺដឹកជញ្ជូនកញ្ចប់បញ្ញើទៅដល់ការិយាល័យចុងទី ឬការិយាល័យឆ្លងកាត់ និងចាត់ចែងបញ្ជូនបញ្ញើពីអន្តរជាតិចែកដល់ដៃអតិថិជន ។

ក្រៅពីនេះ ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជាមាននាយកដ្ឋានផ្សេងៗចំនួន០៦ទៀតដូចជា៖

- នាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្ស : នាយកដ្ឋាននេះជាឆ្អឹងខ្នងរបស់ក្រុមហ៊ុនមានតួនាទីជាអ្នករៀបចំចាត់ចែងការងាររដ្ឋបាលទូទៅរបស់ក្រុមហ៊ុន រួមទាំងជ្រើសរើស សម្រិតសម្រាំងយកបុគ្គលដែលមានជំនាញ និងបទពិសោធន៍ និងបុគ្គលិកថ្មីមកធ្វើការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពការងាររបស់ពួកគេ និងជាអ្នករៀបចំយុទ្ធសាស្ត្រផែនការ ប្រាក់បៀវត្ស និងគ្រប់គ្រងសម្ភារៈរបស់ក្រុមហ៊ុន ។

➢ នាយកដ្ឋានទីផ្សារ : នាយកដ្ឋានទីផ្សារមានកាតព្វកិច្ចជាអ្នកសិក្សា ស្រាវជ្រាវ វិភាគ និងធ្វើផែនការទីផ្សារទាំងក្នុងស្រុក និងក្រៅស្រុក ។ ម៉្យាងវិញទៀត នាយកដ្ឋាននេះជាអ្នកទំនាក់ទំនងសាធារណៈជាមួយផ្នែកលក់ ហើយជាញឹកញាប់ត្រូវចុះផ្សព្វផ្សាយ និងការធ្វើពាណិជ្ជកម្ម ដើម្បីឲ្យអតិថិជនស្គាល់ឲ្យបានកាន់តែច្រើន ។

+ការងារទីផ្សារត្រូវបានបែងចែកជាសកម្មភាពតូចៗដូចជា៖

-សកម្មភាពតាមប្រព័ន្ធផ្សព្វផ្សាយ

- ទូរទស្សន៍ TV3 ក្នុងកម្មវិធី Hot News
- ទូរទស្សន៍ Bayon TV ក្នុងកម្មវិធី Morning News (អរុណសួស្តី)
- តាមវិទ្យុ FM 107.5ABC ក្នុងកម្មវិធីព័ត៌មានទាន់ហេតុការណ៍
- រៀបចំធ្វើសន្និសិទ្ធកាសែត ក្នុងកម្មវិធីបើកសម្ពោធដាក់អោយប្រើប្រាស់ជាផ្លូវការសាខាប.ក. ផ្សារទំនើបអ៊ីអនម៉ល
- រៀចចំធ្វើសន្និសិទ្ធកាសែត ក្នុងកម្មវិធីចុះអនុស្សារណយោគយល់គ្នារវាង ប.ក និងធនាគារឯកទេសវីង (Wing)
- រៀបចំធ្វើសន្និសិទ្ធកាសែត និងចាក់បញ្ចាំងក្នុងកម្មវិធីទូរទស្សន៍ CNC ស្តីអំពីការទទួលពានអន្តរជាតិភាពជាអ្នកដឹកនាំឆ្នើម និងគុណភាពសេវាពីប្រទេសអេស្ប៉ាញ ព្រមទាំងបានផ្សព្វផ្សាយផងដែរតាមរយៈសារអេឡិចត្រូនិចលើគេហទំព័រសប្បាយ (Sabay Page) និងកាសែតកោះសន្តិភាព។

-សកម្មភាពផ្សព្វផ្សាយតាមទីតាំងសាធារណៈ

- ផ្សព្វផ្សាយតាមរឺម៉ក់កង់បីចំនួន២០គ្រឿង
- ផ្លាស់ប្តូរស្លាកយីហោជូនសាខា ប.ក ខេត្តដែលចាស់ ឬស្លេកពណ៌
- រចនារំលេចនូវសេវាប្រៃសណីយ៍លើរថយន្ត
- ផ្ទាំងបដាផ្សព្វផ្សាយអំពីសេវាបញ្ញើឆាប់រហ័ស EMS សេវាកម្មផ្ទេរប្រាក់ឆាប់រហ័ស និងសេវារថយន្តVIP ដឹកអ្នកដំណើរសម្រាប់ចងនៅតាមទីសាធារណៈ និងការធ្វើបទបង្ហាញតាមសកលវិទ្យាល័យ ។
- បង្កើនប្រជាប្រិយភាពលើទំព័រ Facebook រហូតទទួលបាន ៥២.៧៦១ Like និងគេហទំព័រ www.cambodiapost.com.kh និងចុះផ្សាយក្នុងគេហទំព័រ (Yellow Page) ទស្សនាវដ្តីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

-សកម្មភាពផ្សព្វផ្សាយតាមគោលដៅតំបន់រួមមាន៖

- ចូលរួមតាំងពិពណ៌បុណ្យទន្លេលើកទី២ នៅខេត្តកំពង់ចាម ថ្ងៃទី១១ដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៦។
- ចូលរួមពិពណ៌ក្នុងព្រះរាជពិធីច្រត់ព្រះន័ង្គលនៅខេត្តសៀមរាប ថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦។
- ចូលរួមពិពណ៌បុណ្យសមុទ្រលើកទី៥ នៅខេត្តព្រះសីហនុ ថ្ងៃទី២៣ដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៦។

-សកម្មភាពចុះផ្សព្វផ្សាយផ្ទាល់

- ខេត្តពោធិ៍សាត់ បាត់ដំបង កំពង់ស្ពឺ ព្រះសីហនុ ប៉ៃលិន និងខេត្តស្ទឹងត្រែង។
- សកលវិទ្យាល័យភូមិន្ទភ្នំពេញ សកលវិទ្យាល័យជាតិគ្រប់គ្រង សកលវិទ្យាល័យវិទ្យាសាស្ត្រវេជ្ជសាស្ត្រ និងសកលវិទ្យាល័យភូមិន្ទកសិកម្ម ។

-សកម្មភាពចុះសិក្សាស្រាវជ្រាវពីក្រុមហ៊ុនប្រកួតប្រជែង

- ក្រុមហ៊ុន Viettel Post, Cambodia Express, King Ta Express, TSP Express, DHL Express Worldwide, OCS COURIER EXPRESS, FedEx និង PfEx ។ ក្រុមហ៊ុនសូរិយា168ដឹកអ្នកដំណើរ មេគង្គអ៊ិចប្រេស ស៊ីធីលីង (City Link) ឡារីតា វីរៈប៊ុនថាំ មានជ័យអ៊ិចប្រេស ហ្គោលដិនបាយ័នអ៊ិចប្រេស និងចេរ៉ូអ៊ិចប្រេស ។

➢ នាយកដ្ឋានទូទាត់-ទំនាក់ទំនងអន្តរជាតិ

+ ការងារទូទាត់អន្តរជាតិ

-ពិនិត្យឯកសារដែលប្រៃសណីយ៍កម្ពុជាបានចេញ និងទូទាត់ការទារបំណុលសម្រាប់ថ្លៃចែក និងថ្លៃបញ្ញើបាត់បង់ជាមួយបណ្តាប្រៃសណីយ៍ ដែលមានទំនាក់ទំនងលើសកលលោក ក្នុងមួយខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរួមមាន៖

ក. សេវាបញ្ញើធម្មតា មានដូចជា សំបុត្រ និងកញ្ចប់តូច (LC/AO)

ខ. សេវាបញ្ញាឆាប់រហ័ស (EMS)

គ. សេវាប្រៃសណីយ៍ភណ្ឌ (CP/Parcels Post)

ឃ. បញ្ញើឆ្លងកាត់ (Transit Charge)

ង. បញ្ញើដែលទាក់ទងនឹងសំណង (Respect of Indemnity)

-ធ្វើការផ្ទៀងផ្ទាត់សងថ្លៃដឹកជញ្ជូនបញ្ញើប្រៃសណីយ៍អន្តរជាតិ ជាមួយនឹងក្រុមហ៊ុនដឹក

ជញ្ជូនតាមផ្លូវអាកាសរួមមាន៖

ក. Thai Airways

ខ. Dragon Air (Hong Kong, China)

គ. Elite Transport Co., (Malaysia Airline)

-រៀបចំឯកសារទូទាត់ថ្លៃបែងចែកញ្ញប់រួមមាន ៖ Terminal Dues, Imbalance Charge, Inward Land Rate ជាមួយបណ្តាប្រៃសណីយ៍លើសកលលោក ដែលមានទំនាក់ទំនងនៅរាល់បំណាច់ឆ្នាំ ។

➢ នាយកដ្ឋានសេវាហិរញ្ញវត្ថុ: សម្រាប់សេវាអាណត្តិអន្តរជាតិប្រៃសណីយ៍កម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទទួលយកគម្រោងជំនួយរបស់ UPU-IFAD Project ដើម្បីបង្កើតនូវសេវាផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច Electronic Postal Payment Services តាមរយៈប្រព័ន្ធIFSរបស់UPU នៅថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១២។ ជាលទ្ធផលសេវាអាណត្តិប្រៃសណីយ៍អន្តរជាតិ ត្រូវបានដាក់អោយដំណើរការបន្ទាប់ពីប្រៃសណីយ៍បានភ្ជាប់ទំនាក់ទំនងជាមួយLa Banque Postal របស់ប្រទេសបារាំងកាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១២ តាមរយៈប្រព័ន្ធIFS Light របស់UPU។ បច្ចុប្បន្ននេះវិស័យប្រៃសណីយ៍ ក៏បានភ្ជាប់ទំនាក់ទំនងជាមួយនឹងប្រទេសម៉ាឡេស៊ី និងប្រទេសវៀតណាមដោយដាក់អោយដំណើរការសេវានេះ តាមរយៈប្រព័ន្ធIFS របស់ UPU ព្រមទាំងបានចុះកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រៃសណីយ៍ប្រទេសថៃ ក្នុងឆ្នាំ២០១៥នេះផងដែរតាមរយៈការធ្វើ Integerate រវាងប្រព័ន្ធIFS និងEURO-GIRO ។ ក្នុងនោះផងដែរសម្រាប់សេវាអាណត្តិក្នុងប្រទេស ដើម្បីបង្កើនគុណភាពសេវាអាណត្តិប្រៃសណីយ៍ក្នុងប្រទេសអោយបានល្អប្រសើរ និងដើម្បីប្រតិបត្តិការកាន់តែឆាប់រហ័ស និងធានាសុវត្ថិភាព នោះប្រៃសណីយ៍កម្ពុជាដាក់អោយដំណើរការសេវាអាណត្តិប្រៃសណីយ៍ ក្នុងប្រទេសតាមប្រព័ន្ធIFS ចាប់ពីថ្ងៃ ០១ ខែសីហា ឆ្នាំ២០១៤ ជំនួសអោយការប្រើប្រាស់ជាប្រភេទM-27 (PaperBase) ។ ក្រៅពីនេះទៀត ដើម្បីបង្កើននូវចំណូលក៏ដូចជាសហការណ៍ផ្សេងៗ ប្រៃសណីយ៍កម្ពុជាបានចុះកិច្ចព្រមព្រៀងជាមួយធនាគារឯកទេស Wing ហើយបានដាក់ឲ្យសាខាប្រៃសណីយ៍ទាំងអស់ក្លាយជាភ្នាក់ងារWing ជាបន្តបន្ទាប់ចាប់ពីខែកក្កដា ឆ្នាំ២០១៦។

➢ នាយកដ្ឋានផែនការនិងហិរញ្ញវត្ថុ :

+ ការងារផែនការនិងហិរញ្ញវត្ថុ

-រៀបចំផែនការថវិកាប.ក ប្រចាំឆ្នាំ និងទិសដៅចំពោះមុខ

-ចូលរួម និងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

-ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រអាទិភាពក្នុងសេវាប្រៃសណីយ៍

-ចូលរួមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល

-ចូលរួមក្នុងការសិក្សារៀបចំ តារាងតម្លៃថ្មីប្រចាំឆ្នាំ សម្រាប់បញ្ញើប្រៃសណីយ៍ សេវាដឹកជញ្ជូនអ្នកដំណើរ អាណត្តិក្នុង និងក្រៅប្រទេស

-រៀបចំកម្មវិធីចំណូល-ចំណាយប្រចាំខែត្រីមាស ឆមាស និងឆ្នាំ ។

-រៀបចំបេសកកម្មក្នុង និងក្រៅប្រទេសជូនថ្នាក់ដឹកនាំប.ក និងនិយោជិត

-រៀបចំបង់ពន្ធនានាជូនរដ្ឋតាមកាតព្វកិច្ច

-ចូលរួមពិនិត្យ ផ្ទៀងផ្ទាត់ និងទារបំណុលតាមបណ្តាក្រុមហ៊ុន អង្គការ និងក្រសួងនានាដែលនៅជំពាក់ប.ក

-រៀបចំការងារដេញថ្លៃ ប្រេងឥន្ធនៈ សម្ភារៈការិយាល័យរបស់គម្រោង កលិកប័ត្រមុខជំនាញប្រៃសណីយ៍ សម្ភារៈមុខជំនាញប្រៃសណីយ៍ សំបកបារប្រៃសណីយ៍ សំបកកង់និងគ្រឿងបន្លាស់យានយន្ត ឯកសណ្ឋាននិយោជិត សម្ភារៈបរិក្ខារ កុំព្យូទ័រ ព្រីនធ័រ ហ្វូតូកូពី គ្រឿងសង្ហារឹម (តុ ទូ កៅអី) សម្ភារៈឧបករណ៍មុខជំនាញ (ជញ្ជីង ប្រអប់សំបុត្រ)និងផ្សព្វផ្សាយពាណិជ្ជកម្មអំពីវិស័យប្រៃសណីយ៍ ។

- មជ្ឈមណ្ឌលព័ត៌មានវិទ្យាបានអនុវត្តន៍ការងារផ្នែកព័ត៌មានវិទ្យាដូចជា៖

-សហការប្រមូលផ្តុំព័ត៌មានសម្រាប់គេហទំព័រថ្មីរបស់ប្រៃសណីយ៍កម្ពុជា ជាមួយICT របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

-ប្រមូលផ្តុំនិងបន្ថែមព័ត៌មានថ្មីៗសម្រាប់ដាក់បញ្ចូលទៅក្នុងគេហទំព័រ

-បានតម្លើងប្រព័ន្ធ Counter Automation និងBus Counter តាមសាខាប្រៃសណីយ៍កម្ពុជារាជធានី-ខេត្ត

-បានកែទម្រង់ព័ត៌មានរបស់កម្មវិធី Counter Automation ជាភាសាខ្មែរ

-បានតម្លើងម៉ាស៊ីនបោះពុម្ពវិក័យប័ត្រគ្រប់សាខាប្រៃសណីយ៍រាជធានី-ខេត្ត

-បានបង្កើតហ្វេសប៊ុកផ្លូវការដើម្បីផ្សព្វផ្សាយសេវាប្រៃសណីយ៍ និងឆ្លើយតបនឹងតម្រូវការរបស់អតិថិជន ។

### ២.២.២ មុខចំណូលអាជីវកម្មប្រៃសណីយ៍កម្ពុជា

យោងតាមការបូកសរុបលទ្ធផល ការងារអាជីវកម្មប្រៃសណីយ៍កម្ពុជាប្រចាំឆ្នាំ២០១៦ ចំណូលសរុបប្រចាំឆ្នាំ២០១៦ មានចំនួន៩,៤៧៦,២០៧.៨៥ដុល្លារអាមេរិក បើធៀបទៅនឹងផែនការប្រចាំឆ្នាំ២០១៦ មានចំនួន៥,៧៦០,៣២៧.៩០ដុល្លារអាមេរិក កើនឡើង៦៤.៥១% ។ បើធៀបនឹង

ចំណូលប្រចាំឆ្នាំ២០១៥ ចំនួន៥,៤៥៧,៥០៦.៦១ដុល្លារអាមេរិក កើនឡើង៧៣.៦៣% ។ ហើយបើធៀបទៅនឹងចំណូលឆ្នាំ២០១៤ ចំនួន៥,១៩៨,៥០៧.២៤ដុល្លារអាមេរិក កើនឡើង៨២.២៨% ។

➢ ចំណូលអាជីវកម្ម (គិតជាដុល្លារអាមេរិក)

| បរិយាយ | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ |
|---|---|---|---|
| ចំណូលពីការបែងចែកបញ្ញើអន្តរជាតិ | 412,245.14 | 488,015.02 | 3,870,783.82 |
| ចំណូលពីសេវា EMS | 3,102,772.09 | 3,120,288.90 | 3,562,124.07 |
| ចំណូលពីសេវា CP | 982,015.43 | 989,010.44 | 1,033,327.52 |
| ចំណូលពីសេវា LC/AO | 508,360.19 | 510,722.69 | 425,897.24 |
| ចំណូលពីការលក់តែមប្រៃ | 96,855.17 | 98,796.03 | 159,757.29 |
| ចំណូលពីរថយន្តដឹកបញ្ញើប្រៃសណីយ៍ | 26,414.28 | 43,994.38 | 119,044.71 |
| ចំណូលសេវាប្តូរប្រាក់ | 35,692.05 | 23,343.30 | 79,536.99 |
| ចំណូលពីការថែរក្សាទុកដាក់បញ្ញើ | 58,845.36 | 58,598.63 | 66,311.05 |
| ចំណូលពីការលក់ប្រអប់វេចខ្ចប់ | 43,193.67 | 45,371.39 | 58,694.48 |
| ចំណូលពីជួលទ្រព្យសម្បត្តិ | 45.180.00 | 45,352.00 | 56,154.87 |
| ចំណូលពីជួលប្រអប់សំបុត្រ | 26,058.86 | 28,260.83 | 29,553.21 |
| ចំណូលពីសេវាអណត្តិប្រៃសណីយ៍ | 4,246.48 | 4,399.96 | 6,984.61 |
| ចំណូលពីសេវាទូរគមនាគមន៍ | 2,104.02 | 1,197.09 | 3,805.85 |
| ចំណូលពីសេវារឹង | - | - | 3,417.12 |
| ចំណូលពីកញ្ចប់ឥវ៉ាន់អ្នកដំណើរ | 125.42 | 155.95 | 815.02 |
| **សរុប** | **5,198,507.24** | **5,457,506.61** | **9,476,207.85** |

ប្រៃសណីយ៍កម្ពុជាសម្រេចបានបរិមាណផលិតផលសរុប ដោយបញ្ញើនាំចេញប្រភេទបញ្ញើប្រៃសណីយ៍ឆាប់រហ័សទទួលបានចំណូល ៣,៥៦២,១២៤.០៧ ដុល្លារអាមេរិក; បញ្ញើប្រៃសណីយ៍ភ័ណ្ឌទទួលបានចំណូល ១,០៣៣,៣២៧.៥២ដុល្លារអាមេរិក និងបញ្ញើប្រៃសណីយ៍ធម្មតា ទទួលបានចំណូល៤២៥,៨៩៧.២៤ ដុល្លារអាមេរិក ដែលអាចឲ្យប្រៃសណីយ៍កម្ពុជារកបានចំណូល៥៣%នៃចំណូលសរុបប្រចាំឆ្នាំ២០១៦ ។

ចំណូល និងតួលេខទាំងនោះបានបញ្ជាក់ថាបញ្ញើប្រៃសណីយ៍នាំចេញ កាន់តែមានកំនើនខ្លាំងឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ និងបានបង្កើតឱកាសដល់ប្រៃសណីយ៍កម្ពុជាដែលជាសហគ្រាសសាធារណៈស្វយ័តរបស់ក្រសួងអាណាព្យាបាលពីរ គឺក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានលទ្ធភាពគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងលើការងាររដ្ឋបាលបច្ចេកទេសចំណូល ចំណាយដោយខ្លួនឯងនិងពង្រីកសេវាកម្មរបស់ខ្លួន ។ មិនតែប៉ុណ្ណោះវាថែមទាំងបានផ្តល់ការងារយ៉ាងច្រើនទៅដល់ប្រជាពលរដ្ឋក្នុងស្រុក និងទទួលបាននូវប្រាក់កម្រៃបានសមរម្យ ដោយអាចធ្វើឲ្យជីវភាពរបស់ពួកគេមានភាពល្អប្រសើរជាងមុន ។

**រូបភាពទី៨៖ មុខចំណូលអាជីវកម្មប្រៃសណីយ៍ឆ្នាំ២០១៦**




### ២.២.៣ ក្របខ័ណ្ឌបៀវត្ស

| បរិយាយ | ពេញសិទ្ធិ | ជាប់កិច្ចសន្យា | សរុប |
|---|---|---|---|
| -សមាជិកក្រុមប្រឹក្សាភិបាល | - | ០៥នាក់ | ០៥នាក់ |
| -មន្ត្រីត្រួតពិនិត្យរដ្ឋ | - | ០១នាក់ | ០១នាក់ |
| -អគ្គនាយក | ០១នាក់ | - | ០១នាក់ |
| -អគ្គនាយករង | ០៣នាក់ | - | ០៣នាក់ |
| -នាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្ស | ១៥នាក់ | ០៦នាក់ | ២១នាក់ |

| | | | |
|---|---|---|---|
| -នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ | ១៧នាក់ | ០៥នាក់ | ២២នាក់ |
| -នាយកដ្ឋានអាជីវកម្ម | ២៨នាក់ | ១២នាក់ | ៤០នាក់ |
| -នាយកដ្ឋានបញ្ញើ និងដឹកជញ្ជូន | ៦៨នាក់ | ២២នាក់ | ៩០នាក់ |
| -នាយកដ្ឋានទីផ្សារ | ០៥នាក់ | ០២នាក់ | ០៧នាក់ |
| -នាយកដ្ឋានសេវាហិរញ្ញវត្ថុប្រៃសណីយ៍ | ០៦នាក់ | ០២នាក់ | ០៨នាក់ |
| -នាយកដ្ឋានសវនកម្មផ្ទៃក្នុង | ០៦នាក់ | ០១នាក់ | ០៧នាក់ |
| -នាយកដ្ឋានទូទាត់ ទំនាក់ទំនងអន្តរជាតិ | ០៤នាក់ | ០៨នាក់ | ១២នាក់ |
| -មជ្ឈមណ្ឌលព័ត៌មានវិទ្យា | ០៣នាក់ | ០៧នាក់ | ១០នាក់ |
| -សាខាប្រៃសណីយ៍ភ្នំពេញ(០៨សាខា) | ១៧នាក់ | ១៣នាក់ | ៣០នាក់ |
| -សាខាប្រៃសណីយ៍តាមខេត្ត | ៩០នាក់ | ៩៧នាក់ | ១៩៧នាក់ |
| -រថយន្តដឹកអ្នកដំណើររបស់ប្រៃសណីយ៍កម្ពុជា | - | ១២នាក់ | ១២នាក់ |
| -ជំនួយការ | - | ១២នាក់ | ១២នាក់ |
| -ទីប្រឹក្សាអម ប.ក. | - | ០២នាក់ | ០២នាក់ |
| -សន្តិសុខ | - | ០៥នាក់ | ០៥នាក់ |
| សរុបរួមទាំងអស់ | **២៦៣នាក់** | **២១២នាក់** | **៤៧៥នាក់** |

## ២.៣ ដំណើរការលើការនាំចេញទំនិញ

### ២.៣.១ ការទទួលបញ្ញើ

រាល់បណ្តាបញ្ញើដែលផ្ញើក្នុងស្រុក ឬផ្ញើទៅអន្តរជាតិ ការទទួលបញ្ញើប្រៃសណីយ៍គ្មានសាខាប្រៃសណីយ៍រាជធានី-ខេត្តណាមួយ នៅក្នុងប្រទេស ឬក៏ប្រទេសជាសមាជិកសហភាពប្រៃសណីយ៍សកល ដែលមិនព្រមទទួលបញ្ញើ ក៏ដូចជាការចែកបញ្ញើទៅអោយអ្នកទទួល ទោះបីជាអ្នកផ្ញើនោះជាជាតិសាសន៍អ្វីក៏ដោយ ដែលបានរស់នៅលើទឹកដីដែលអ្នកផ្ញើស្នាក់នៅ ឬក៏ស្នាក់នៅបណ្តោះអាសន្ន។ លើកលែងតែច្បាប់នៃប្រទេសទទួលហាមឃាត់ និងអន្តរវត្ត ។ ការទទួលបញ្ញើទាំងអស់ត្រូវបានបែងចែកនៅតាមបញ្ជរផ្សេងៗគ្នា ដែលអាចឲ្យអតិថិជនងាយស្រួលក្នុងការចំណាំ និងស្វែងរក ពិសេសវាបានបង្កលក្ខណៈងាយស្រួលក្នុងការរៀបចំ និងគ្រប់គ្រងផងដែរ ។

**តារាងប្រៀបធៀបបរិមាណបញ្ញើប្រៃសណីយ៍ (គិតជាកញ្ចប់)**

| ល.រ | បញ្ញើ | អនុវត្តជាក់ស្តែងប្រចាំឆ្នាំ | | | ប្រៀបធៀបនឹងឆ្នាំ 2016 (ភាគរយ) | |
|---|---|---|---|---|---|---|
| | | 2014 | 2015 | 2016 | 2014 | 2015 |
| ១ | **បញ្ញើធម្មតា** | **1,022,077** | **1,223,730** | **1,231,707** | **20.51** | **0.65** |
| | ទទួលបាន | 296,401 | 476,961 | 516,894 | **74.39** | **8.37** |
| | បញ្ជូនចេញ | 725,676 | 746,769 | 714,813 | **-1.50** | **-4.28** |
| ២ | **បញ្ញើឆាប់រហ័ស** | **127,941** | **129,089** | **132,273** | **3.39** | **2.47** |
| | ទទួលបាន | 66,843 | 68,181 | 66,935 | **0.14** | **-1.83** |
| | បញ្ជូនចេញ | 61,098 | 60,908 | 65,338 | **6.94** | **7.27** |
| ៣ | **បញ្ញើប្រៃសណីយ៍** | **31,314** | **35,117** | **37,937** | **21.15** | **8.03** |
| | ទទួលបាន | 16,169 | 19,542 | 21,236 | **31.34** | **8.67** |
| | បញ្ជូនចេញ | 15,145 | 15,575 | 16,701 | **10.27** | **7.23** |
| | **សរុប** | **1,181,332** | **1,387,936** | **1,401,917** | **18.67** | **1.01** |

**២.៣.១.១ ការទទួលបញ្ញើធម្មតា**

ក. ការទទួលបញ្ញើជាសំបុត្រ កញ្ចប់តូច ឬឯកសារផ្សេងៗ

ការផ្ញើបញ្ញើជាសំបុត្រ កញ្ចប់តូច ឬឯកសារ តម្រូវឲ្យបុគ្គលអ្នកផ្ញើប្រើប្រាស់សីមីពណ៌គគីរ ឬស្រោមសំបុត្រដែល កំណត់ដោយប្រៃសណីយ៍កម្ពុជា ។ រាល់បញ្ញើជាសំបុត្រ មិនត្រូវបានត្រួតពិនិត្យដោយ មន្ត្រីគយនោះទេ លុះត្រាតែមានការតម្រូវណាមួយចាំបាច់ ។ បន្ទាប់ពីទទួលបានការណែនាំពីរបៀប បំពេញព័ត៌មានផ្ញើ និងតម្លៃផ្ញើទៅតាម ប្រភេទសេវាកម្មដែលអតិថិជនចង់បាន ដោយបុគ្គលិកប្រៃសណីយ៍រួចមក កញ្ចប់បញ្ញើ នោះត្រូវបានបិទជិត និងរក្សា ទុកក្នុងកំឡុងពេលណាមួយរហូត ដល់ពេលដែលបញ្ញើត្រូវបានបញ្ជូន ទៅកាន់ការិយាល័យមន្ត្រីប៉ូលីសគ្រឿងញៀន ធ្វើការវិនិច្ឆ័យ និងសម្រេច មុននឹងទំនិញត្រូវបានច្រកចូលបាវ រួចបញ្ជូនទៅឃ្លាំងទំនិញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ។

ខ. ការទទួលបញ្ញើមិនមែនជាសំបុត្រ កញ្ចប់តូច ឬឯកសារផ្សេងៗ

ក្នុងន័យនេះសម្តៅដល់រាល់កញ្ចប់បញ្ញើប្រៃសណីយ៍ទាំងអស់ ដែលមិនត្រូវបានកំណត់ក្នុងចំណុចខាងលើ ។ ការទទួលបញ្ញើអាចធ្វើទៅបាន ក្នុងករណីមិនមែនជាទំនិញហាមឃាត់ និងមាន

ឯកភាពពីមន្ត្រីគយប្រចាំការ នៅទីនោះ ។ បន្ទាប់ពីទទួលបានការណែនាំពីរបៀប បំពេញព័ត៌មានផ្ញើ និងតម្លៃផ្ញើទៅតាម ប្រភេទសេវាកម្មដែលអតិថិជនចង់បាន ដោយបុគ្គលិកប្រៃសណីយ៍រួចមក កញ្ចប់បញ្ញើ នោះត្រូវបានបិទជិត និងរក្សា ទុកក្នុងកំឡុងពេលណាមួយរហូត ដល់ពេលដែលបញ្ញើ ត្រូវបានបញ្ជូន ទៅកាន់ការិយាល័យមន្ត្រីប៉ូលីសគ្រឿងញៀនធ្វើការវិនិច្ឆ័យ និងសម្រេច មុននឹង ទំនិញត្រូវបានច្រកចូលបាវ រួច បញ្ជូនទៅឃ្លាំងទំនិញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ។

**២.៣.១.២ ការទទួលបញ្ញើប្រៃសណីយ៍ភ័ណ្ឌ**

លក្ខណៈទូទៅនៃសេវាបញ្ញើប្រៃសណីយ៍ភ័ណ្ឌ រួមមាន៖

- លក្ខខ័ណ្ឌនៃការទទួលផ្ញើៈ ប្រៃសណីយ៍ភ័ណ្ឌ ត្រូវមានលក្ខណៈសមស្របដូចខាងក្រោមទើបអាចផ្ញើបាន៖

១.ទំហំ : អតិបរមា គឺបណ្តោយ បូក ទទឹង បូកកំពស់ មិនអោយលើសពី៣ម និង បណ្តោយមិនត្រូវអោយលើសពី១,៥ម ហើយអប្បរមា គឺ៩សម x ១៤សម x ២សម ។

២.ទំងន់ : ក្នុងនិងក្រៅប្រទេសទំងន់អតិបរមា៣០គីឡូក្រាម។ ចំពោះប្រៃសណីយ៍ភ័ណ្ឌ ផ្ញើទៅអន្តរជាតិ គឺក្រៅពីគោលការណ៍ដែលបានចែងក្នុងចំនុច១និង២ខាងលើត្រូវអនុលោមទៅ តាមការកំរិតកំណត់របស់ប្រទេសទទួល។

**២.៣.១.៣ ការទទួលបញ្ញើឆាប់រហ័ស**

ក.សេវាបញ្ញើឆាប់រហ័សអន្តរជាតិ

- ការផ្ញើបញ្ញើនៅបញ្ជរៈ អតិថជនត្រូវបំពេញលើសសាលាកបត្រ(E1) ជាភាសាខ្មែរ ឬភាសាអន្តរជាតិលើអាកាសដ្ឋានអ្នកផ្ញើ ចំពោះអាកាសដ្ឋានអ្នកទទួលត្រូវបំពេញជាភាសាអន្តរ ជាតិ ឬភាសាផ្លូវការនៃប្រទេសទទួល ។ អតិថជនត្រូវបញ្ជាក់អោយច្បាស់ ទៅលើអន្តរវត្ថុដែលផ្ញើ ទៅលើប្រតិវេទគយ(CN22 or CN23) ហើយនិងចុះហត្ថលេខាដើម្បីបញ្ជាក់ថាអន្តរវត្ថុខាងក្នុង គឺជា អន្តរវត្ថុដែលមិនមានការហាមឃាត់ ឬខុសច្បាប់។
- ការទទួលបញ្ញើតាមលំនៅដ្ឋាន : អតិថិជនត្រូវទំនាក់ទំនងតាមទូរស័ព្ទមកភ្នាក់ងារ ទទួល ដោយប្រាប់ទីតាំងសម្រាប់ការទៅទទួលអោយបានច្បាស់ ហើយតម្រូវអោយអតិថជនត្រូវ បំពេញបែបបទផ្ញើដូចចំណុចខាងលើដូចគ្នា ព្រមទាំងបង់ថ្លៃសេវាផ្ញើតាមការកំណត់ទំងន់ ជាមួយ នឹងភ្នាក់ងារផ្ទាល់តែម្តង។

➢ ការផ្ញើតាមសាខារាជធានី ខេត្ត: អតិថជនមិនចាំបាច់ផ្ញើតែនៅសាខាកណ្តាលនោះទេ គឺអតិថជនអាចផ្ញើតាមសាខារាជធានី-ខេត្ត បានដូចគ្នាដោយអាស័យដ្ឋានមានភ្ជាប់ស្រាប់នៅក្នុងគេហទំព័ររបស់ប្រៃសណីយ៍កម្ពុជា។

ខ. សេវាឆាប់រហ័សក្នុងប្រទេស

សេវាឆាប់រហ័សក្នុងប្រទេស គឺមិនមានលក្ខណៈខុសពីសេវាឆាប់រហ័សអន្តរជាតិ គ្រាន់តែការផ្ញើរចេញអតិថិជនត្រូវបំពេញលើស្រោមសំបុត្ររបស់ប្រៃសណីយ៍ ជាមួយនឹងព័ត៌មានបន្ថែមទៀតដោយមិនត្រូវអោយអតិថជនបរិយាយអន្តរវត្ថុ និងមានតម្លៃសេវាសមរម្យ ព្រមជាមួយសំណងក្នុងករណីដែលមានការបាត់បង់ ។

គ. ប្រព័ន្ធនៃការគ្រប់គ្រងបញ្ញើ

➢ បញ្ញើឆាប់រហ័សដំណើរការទៅលើប្រព័ន្ធ International Postal System (IPS) ដែលជាប្រព័ន្ធគ្រប់គ្រងដោយប្រៃសណីយ៍សកល ។

➢ រាល់បញ្ញើទាំងអស់អតិថិជនអាចតាមដានបញ្ញើដោយខ្លួនឯងផ្ទាល់ តាមគេហទំព័ររបស់ប្រៃសណីយ៍ ឬគេហទំព័រប្រៃសណីយ៍របស់ប្រទេសទទួល និងអាចទាក់ទងតាមដានជាមួយនឹងភ្នាក់ងារប្រៃសណីយ៍ដោយតាមរយៈទូរស័ព្ទ ឬមកដោយផ្ទាល់នៅប្រៃសណីយ៍កម្ពុជាគ្រប់សាខារាជធានី-ខេត្ត ។

➢ ការគ្រប់គ្រងជាមួយនឹងលេខកូដបញ្ញើ(Tracking Number) ដែលមិនមានស្ទួនដោយលេខសម្គាល់បញ្ញើ គឺមានចំនួនប្រាំបួនខ្ទង់ រួមជាមួយនឹងអក្សរពីរខ្ទង់មុខ និងក្រោយលេខ។ ឧទាហរណ៍: EE000000001KH ( អក្សរពីខាងមុខបញ្ជាក់ពីសេវា និងអក្សរពីខាងក្រោយបញ្ជាក់ពីប្រទេសដែលផ្ញើរចេញ) ។

## ២.៣.២ ការត្រួតពិនិត្យបញ្ញើជារូបវ័ន្ត

បន្ទាប់ពីទទួលកញ្ចប់បញ្ញើ និងណែនាំពីរបៀបបំពេញសលកប័ត្រផ្ញើ និងប្រាប់ពីតម្លៃផ្ញើរួចមក ការត្រួតពិនិត្យជារូបវ័ន្តជាដំណាក់កាលដែលត្រូវបានធ្វើឡើងដោយសមត្ថកិច្ច និងភាគីពាក់ព័ន្ធដូចជា៖ បុគ្គលិកប្រៃសណីយ៍ និងមន្ត្រីគយចំនួនពីររូប ។ គោលបំណងយ៉ាងសំខាន់ ក្នុងការត្រួតពិនិត្យជារូបវ័ន្ត គឺដើម្បីស្រាវជ្រាវ បង្ការ និងទប់ស្កាត់ការចរាចរណ៍វត្ថុហាមឃាត់ សារធាតុងាយផ្ទុះ និងងាយឆាបឆេះ ក៏ដូចជាទំនិញមានវេតយិទភាពដទៃទៀតដែលមានចែងក្នុងច្បាប់ និងបទបញ្ញត្តិផ្សេងៗទៀតនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាបាននូវសុខភាព សុវត្ថិភាព សុខមាលភាព និង

សន្តិសុខសង្គម និងធ្វើឲ្យប្រាកដថាតើមានជើងហោះហើរ ឬអនុស្សាវរណៈនៃការយោគយល់គ្នារវាងប្រទេសផ្ញើ និងទទួលឬទេ ។ (មើលឧបសម្ព័ន្ធទី២)

ទំនិញនាំចេញ នាំចូលទាំងអស់ ទោះបីជា ឬ មិនមែនជាកម្មវត្ថុ នៃការជាប់ពន្ធ និងអាករក្តី ដែលបាននាំចូល ឬចេញពីដែនគយជាកម្មវត្ថុនៃការត្រួតពិនិត្យគយ (មាត្រា៥៦នៃច្បាប់ស្តីពីគយ) ។ ការត្រួតពិនិត្យកញ្ចប់ប្រៃសណីយ៍ មន្ត្រីគយប្រព្រឹត្តទៅដោយមានវត្តមានមន្ត្រីប្រៃសណីយ៍ ឬម្ចាស់ទំនិញ ឬ តំណាងម្ចាស់។

ការត្រួតពិនិត្យនឹងមិនត្រូវធ្វើលើបណ្តាកញ្ចប់ប្រៃសណីយ៍ទាំងឡាយដូចជា៖

ក. កញ្ចប់បញ្ញើ ដោយបេសកកម្មកុងស៊ុល ឬ ការទូតបរទេស ឬ គណៈប្រតិភូផ្លូវការនៃរដ្ឋាភិបាលបរទេស។

ខ. ប្រៃសណីយ៍បត្រ និងលិខិតដែលមានតែសារផ្ទាល់ខ្លួន អក្សរសាស្ត្រ គឺដើម្បីសម្រាប់មនុស្សពិការភ្នែក។

គ. ឯកសារបោះពុម្ពដែលមិនមែនជាកម្មវត្ថុនៃការជាប់ពន្ធ។

ឃ.កញ្ចប់ប្រៃសណីយ៍ដែលដឹកជញ្ជូនឆ្លងកាត់ជាអន្តរជាតិ។

បន្ទាប់ពីធ្វើការត្រួតពិនិត្យជាក់ស្តែងរួច ភ្នាក់ងារគយ និងភ្នាក់ងារប្រៃសណីយ៍ត្រូវពិភាក្សាគ្នាយ៉ាងម៉ត់ចត់ និងម៉ឺងម៉ាត់ ពីយថាប្រភេទ ទម្ងន់ ភិនភាគនៃអន្តរវត្ថុ និងធ្វើការសម្រេចរួមគ្នាថា ការផ្ញើបញ្ញើចេញអាចធ្វើទៅបានដែរឬទេ? ម្យ៉ាងទៀតភ្នាក់ងារប្រៃសណីយ៍ត្រូវជូនដំណឹងទៅមន្ត្រីគយអំពីកិច្ចព្រមព្រៀង និងសេចក្តីជូនដំណឹងរបស់ប្រទេសសមាជិកនៃសហភាពប្រៃសណីយ៍សកល UPU ស្តីពីការនាំចេញនិងនាំចូល ។

ចំពោះបញ្ញើមានលក្ខណៈជាអង្គធាតុរាវ ឬសន្ទនីយ ភ្នាក់ងារប្រៃសណីយ៍ ត្រូវថតចម្លងនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកផ្ញើ ហើយថតអន្តរវត្ថុនោះព្រីនពណ៌ធម្មជាតិ និងធ្វើរបាយការណ៍ទៅនាយកដ្ឋានបញ្ញើ និងដឹកជញ្ជូនឲ្យមានការប្រុងប្រយ័ត្ន និងរាយការណ៍បន្តទៅអាជ្ញាធរមានសមត្ថកិច្ច នៅឃ្លាំងទំនិញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ។ ចំពោះបញ្ញើមានលក្ខណៈជាវត្ថុផុយស្រួយ និងងាយបាក់បែក ត្រូវវាយត្រាមិនតវ៉ា និងបិទស្លៀលបាក់បែក (Fragile) និងធ្វើរបាយការណ៍អំពីស្ថានភាពបញ្ញើ ដែលត្រូវប្រុងប្រយ័ត្ននៅពេលផ្ទុក លើកដាក់ និងដឹកជញ្ជូនតាមផ្លូវ ។

**រូបភាពទី៩៖ ស៊ៀលបញ្ជាក់ពីវត្ថុខាយបាក់បែក**







### **២.៣.៣ ការវេចខ្ចប់បញ្ញើ**

១. ការវេចខ្ចប់សំបុត្រ និងកញ្ចប់តូច មានលក្ខណៈដូចខាងក្រោម៖

-រាល់បញ្ញើទាំងអស់(អន្តរជាតិ-ក្នុងប្រទេស) ដែលជាប្រភេទកញ្ចប់តម្រូវអោយអតិថិជនប្រើប្រាស់ប្រអប់វេចខ្ចប់របស់ប្រៃសណីយ៍ ដោយទិញសម្រាប់វេចខ្ចប់។

-ចំពោះបញ្ញើប្រភេទលិខិតទាំងអន្តរជាតិ-ក្នុងស្រុក ប្រៃសណីយ៍កម្ពុជាមានស្រោមសំបុត្រសម្រាប់ផ្តល់ជូនអតិថិជនប្រើប្រាស់ដោយមិនចាំបាច់ទិញ។

-រាល់បញ្ញើទាំងអស់មិនត្រូវបានអនុញ្ញាតិ អោយអតិថិជនប្រើប្រាស់ស្កុតស្រអាប់ទេដើម្បីការពារការលោតពណ៌នៅពេលស្កេនកញ្ចប់នៅព្រលាន និងដើម្បីងាយស្រួលពិនិត្យនៅពេលដែលអតិថិជនយកឥវ៉ាន់មកដល់បញ្ជរ ឬផ្ញើតាមភ្នាក់ងារទទួលបញ្ញើតាមគេហដ្ឋាន។

-ការវេចខ្ចប់កញ្ចប់ទាំងអស់អាចមានការច្នៃ ជាប្រអប់វេចខ្ចប់ដោយខ្លួនឯង ឬតាមរយៈភ្នាក់ងារប្រៃសណីយ៍ ដើម្បីសម្រួលដល់អន្តរវត្ថុមួយចំនួន។

២. ការវេចខ្ចប់បញ្ញើប្រៃសណីយ៍ភ័ណ្ឌ

រាល់បណ្តាបញ្ញើប្រៃសណីយ៍ដែលផ្ញើជាកញ្ចប់ ឬប្រៃសណីយ៍ភ័ណ្ឌ ត្រូវបានវេចខ្ចប់បិទជិតដោយវិធីមួយមាំ ហើយជាប់អោយបានសមស្របជាមួយទំងន់ក្នុងរយៈពេលដឹកជញ្ជូនដើម្បីជៀសវៀងការខូចខាតរបែក ធានាបាននូវការបាត់បង់អន្តរវត្ថុខាងក្នុង និងមិនធ្វើអោយប្រលាក់ ខូចខាតដល់បញ្ញើដទៃទៀត។ ចំពោះអន្តរវត្ថុរាវ ជាតិងាយខូច ជាតិងាយហៀរទឹក ត្រូវគោរពទៅតាមរបៀបវេចខ្ចប់ពិសេសដែលបានកំណត់សំរាប់បណ្តាប្រទេសនេះ។

៣. ការវេចខ្ចប់បញ្ញើប្រៃសណីយ៍ឆាប់រហ័ស

-រាល់បញ្ញើទាំងអស់(អន្តរជាតិ-ក្នុងប្រទេស) ដែលជាប្រភេទកញ្ចប់ ត្រូវតម្រូវអោយអតិថិជនប្រើប្រាស់ប្រអប់វេចខ្ចប់របស់ប្រៃសណីយ៍ ដោយទិញសម្រាប់វេចខ្ចប់។

-ចំពោះបញ្ញើប្រភេទលិខិតទាំងអន្តរជាតិ-ក្នុងស្រុក ប្រៃសណីយ៍កម្ពុជាមានស្រោមសំបុត្រសម្រាប់ផ្តល់ជូនអតិថិជនប្រើប្រាស់ដោយមិនចាំបាច់ទិញ។

-រាល់បញ្ញើទាំងអស់មិនត្រូវបានអនុញ្ញាតិ អោយអតិថិជនប្រើប្រាស់ស្កុតស្រអាប់ទេ ដើម្បី ការពារការលោតពណ៌នៅពេលស្កេនកញ្ចប់នៅព្រលាន និងដើម្បីងាយស្រួលពិនិត្យនៅពេលដែលអតិថិជនយកឥវ៉ាន់មកដល់បញ្ជរ ឬផ្ញើតាមភ្នាក់ងារទទួលបញ្ញើតាមគេហដ្ឋាន។ ការវេចខ្ចប់កញ្ចប់ទាំងអស់ អាចមានការកែច្នៃជាប្រអប់វេចខ្ចប់ដោយខ្លួនឯង ឬតាមរយៈភ្នាក់ងារប្រៃសណីយ៍ ដើម្បីសម្រួលដល់អន្តរវត្តុមួយចំនួន ។

## ទំហំបញ្ញើប្រៃសណីយ៍

១- បញ្ញើប្រកចូលស្រោម :

ទំហំអប្បរមា ៩០ មម x ១៤០ មម

អតិបរមា ១២០ មម x ២៣៥ មម

២- បញ្ញើផ្ញើជាកញ្ចប់ :

ទំហំអប្បរមា មុខនិមួយៗតូចបំផុត ១៤០ មម x ៩០ មម

ទំហំអតិបរមាស្មើនិងបណ្តោយទទឹង កំពស់ស្មើ ៩០០ មម

### តារាងប្រអប់វេចខ្ចប់

| បណ្តោយ | ទទឹង | កំពស់ | ទំងន់ | តម្លៃ |
|---|---|---|---|---|
| 28cm | 15cm | 8cm | 0.10kg | 1800R |
| 30cm | 18cm | 15cm | 0.13kg | 2500R |
| 30cm | 20cm | 20cm | 0.18kg | 3500R |
| 40cm | 26cm | 25cm | 0.30kg | 4500R |
| 50cm | 35cm | 36cm | 0.60kg | 6000R |
| 56cm | 40cm | 40cm | 1.20kg | 7500R |

### ២.៣.៤ ការដាក់ឲ្យឆ្លងកាត់ម៉ាស៊ីនស្កេន

បន្ទាប់ពីបញ្ញើត្រូវបានធ្វើការត្រួតពិនិត្យជារូបវន្តពីសំណាក់មន្ត្រីគយ និងភាគីពាក់ព័ន្ធរួច និងត្រូវបានវេចខ្ចប់ យ៉ាងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងស្តង់ដារអន្តរជាតិ រាល់កញ្ចប់បញ្ញើប្រៃសណីយ៍ទាំងអស់ (លើកលែងតែ សំបុត្រនិងកញ្ចប់មួយចំនួនដែលច្បាប់មិនតម្រូវ) នឹងត្រូវដាក់ឲ្យឆ្លងកាត់ម៉ាស៊ីនស្កេន X-ray ដែលត្រូវបានឃ្លាំមើល និងត្រួតពិនិត្យដោយមន្ត្រីប៉ូលីសគ្រឿងញៀន ដើម្បីធ្វើការវិនិច្ឆ័យថាតើ ក្នុងកញ្ចប់បញ្ញើទាំងនោះមានបង្កប់ ឬលួចលាក់ នូវសារធាតុងាយផ្ទុះងាយឆាបឆេះ សារធាតុញៀន និងទំនិញមាន ហានិភ័យផ្សេងទៀតដែលមិនត្រូវបានអនុញ្ញាត ឲ្យផ្ញើចេញ ឬត្រូវបានហាមឃាត់ដោយប្រទេសគម្យដ្ឋាន ។ ចំពោះកញ្ចប់ប្រៃសណីយ៍តាមបណ្តាខេត្ត ត្រូវបញ្ជូនតាមរថយន្តមកកាន់ទីស្នាក់ការកណ្តាល ដើម្បីធ្វើការត្រួតពិនិត្យ និងស្កេន ។ ការស្កេនត្រូវបានធ្វើឡើងចំនួនពីរដងក្នុងមួយថ្ងៃ គឺពេល ព្រឹក និងពេលរសៀល រៀងរាល់ម៉ោងធ្វើការពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ។ ក្នុងករណីមានការសង្ស័យ មន្ត្រីប៉ូលីសគ្រឿងញៀនត្រូវធ្វើការស្នើសុំទៅមន្ត្រីគយ និងរដ្ឋាករ ដើម្បីឆែកឆេរ យកវត្ថុឬសារធាតុហាមឃាត់ទាំងអស់នោះ ទៅធ្វើការពិសោធន៍រួចធ្វើកំណត់ហេតុបញ្ជូនទៅតុលាការ ដើម្បីចាត់វិធានការជាធរមានតាមផ្លូវច្បាប់ ។

### ២.៣.៥ ការដឹកជញ្ជូនបញ្ញើ

ការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ធ្វើតាមមធ្យោបាយ ផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាសចែកជាដំណាក់កាលដូចខាងក្រោម៖

១. ការដឹកជញ្ជូនបញ្ញើសំបុត្រប្រៃសណីយ៍ពីប្រអប់សំបុត្រតាមផ្លូវសាធារណៈ និងបញ្ញើប្រៃសណីយ៍ពីលំនៅដ្ឋាន ឬការិយាល័យមកមន្ទីរប្រៃសណីយ៍ ។

២. ការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍មួយទៅកាន់មន្ទីរប្រៃសណីយ៍ផ្សេងៗទៀត

៣. ការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ទៅចែកចាយសល់អាស័យដ្ឋានអ្នកទទួល

៤. ការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ពីព្រះរាជាណាចក្រកម្ពុជា ចេញទៅបណ្តាលប្រទេសនៅលើពិភពលោក ។

ការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ អាចត្រូវបានធ្វើឡើង តាមរយៈមធ្យោបាយដឹកជញ្ជូនរបស់ក្រុមហ៊ុនដឹកជញ្ជូន ឬឯកជន ដោយផ្អែកលើកិច្ចព្រមព្រៀងដោយឡែកៗ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រុមហ៊ុនដឹកជញ្ជូន។ ចំពោះតម្លៃដឹកជញ្ជូនត្រូវគិតទៅតាមតម្លៃអនុគ្រោះ[១២]។

---

[១២] ចែងក្នុងមាត្រា៣៣ ច្បាប់ស្តីពីវិស័យប្រៃសណីយ៍

ក្រោយពីដំណើរការស្កេនត្រូវបានបញ្ចប់ កញ្ចប់បញ្ញើទាំងអស់ទាំងនៅភ្នំពេញ និងតាមបណ្តាខេត្តនានា ត្រូវបានរាប់ចំនួន ផ្ទៀតផ្ទាត់ទំនិញ និងតម្លៃឡើងវិញ ។

ក. ក្នុងករណីកញ្ចប់បញ្ញើមានលក្ខណៈប្រក្រតី បុគ្គលិកនៃការិយាល័យបញ្ជូនបញ្ញើត្រូវចុះហត្ថលេខាទទួល និងធ្វើការបែងចែកបញ្ញើដូចខាងក្រោម៖

➢ **បញ្ញើក្នុងស្រុក**

✓ បែងចែកទៅតាមទិសដៅទទួល

✓ រៀបចំបិទបញ្ញើតាមប្រព័ន្ធIPS

✓ រៀបចំឯកសារប្រគល់ទទួលជាមួយភ្នាក់ងារដឹកជញ្ជូន

➢ **បញ្ញើអន្តរជាតិ**

✓ បែងចែកតាមជើងយន្តហោះ

✓ បែងចែករវាងឯកសារ និងកញ្ចប់ទំនិញ

✓ បញ្ចូលទិន្នន័យតាមប្រព័ន្ធIPS

✓ រៀបចំលេខជើងបញ្ញើចេញ

✓ ធ្វើឯកសារCN38 ,ឯកសារសម្រាប់ផ្ទៀងផ្ទាត់ជាមួយភ្នាក់ងារដឹកជញ្ជូន និងភ្នាក់ងារយន្តហោះ

✓ ធ្វើការងារផ្ទៀងផ្ទាត់បាវបញ្ញើជាមួយភ្នាក់ងារដឹកជញ្ជូន ។

ខ. ក្នុងករណីកញ្ចប់បញ្ញើមានលក្ខណៈមិនប្រក្រតី ដោយខុសទំងន់ តម្លៃ បែក និងការមិនទាន់ទទួលពីអតិថិជន គឺត្រូវធ្វើដូចខាងក្រោម៖

✓ បញ្ជូនត្រលប់ទៅការិយាល័យបញ្ញើរ ឬការិយាល័យបញ្ញើចូល

✓ ក្រោយពីការិយាល័យបញ្ញើរ ឬការិយាល័យបញ្ញើចូលធ្វើការកែតម្រូវរួច ត្រូវចុះហត្ថលេខាទទួល និងត្រូវអនុវត្តដោយដូចនឹងប្រតិបត្តិការរបស់បញ្ញើដែលមានលក្ខណៈប្រក្រតី ។

បន្ទាប់មកបុគ្គលិកប្រៃសណីយ៍នៃការិយាល័យទាំងបី គឺការិយាល័យបញ្ជូនបញ្ញើឆាប់រហ័ស ការិយាល័យបញ្ជូន និងទទួលបញ្ញើប្រៃសណីយ៍ និងការិយាល័យបញ្ជូនបញ្ញើប្រៃសណីយ៍ធម្មតា ត្រូវរៀបចំបញ្ចូលទិន្នន័យ និងព័ត៌មានបញ្ញើទៅក្នុងប្រព័ន្ធIPSជារៀងរាល់ថ្ងៃ ដើម្បីងាយស្រួលក្នុងការតាមដានបញ្ញើតាមរយៈ Tracking Number ដោយម៉ាស៊ីនស្កេនបាកូដ រួចហើយបោះពុម្ពដីការអមគយភ្ជាប់ជាមួយនឹង Manifest (និវេទនប័ណ្ណ); Bill of Lading ឬ Air waybill ដើម្បីដាក់ជូនរដ្ឋបាលគយប្រចាំការនៅប្រៃសណីយ៍កម្ពុជាធ្វើការត្រួតពិនិត្យ ឯកភាព និងធ្វើទម្រង់ការចេញចំនួន៤ច្បាប់ គឺ

សម្រាប់មន្ត្រីគយ និងរដ្ឋាករប្រៃសណីយ៍ចំនួនមួយច្បាប់ ការិយាល័យដឹកជញ្ជូនបញ្ញើចំនួនពីរច្បាប់ និងតម្កល់ទុក ជាឯកសារកាលប្បវត្តិ នៅតាមការិយាល័យនីមួយៗចំនួនមួយច្បាប់ ។ ចំណែកឯការិយាល័យដឹកជញ្ជូនបញ្ញើត្រូវចាត់បុគ្គលិកយ៉ាងតិចចំនួនពីរនាក់ដឹកជញ្ជូនកញ្ចប់បញ្ញើ តាមរយៈរថយន្តធំរបស់ប្រៃសណីយ៍ ទៅកាន់ឃ្លាំងទំនិញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដើម្បីធ្វើការស្កេន ។

## ២.៣.៦ ការធានា និងការទទួលខុសត្រូវលើបញ្ញើ

ប្រៃសណីយ៍កម្ពុជាមានភារកិច្ចទទួលខុសត្រូវចាប់តាំងពីការទទួល ការបញ្ជូន រហូតដល់ចែកចាយដល់ដៃអ្នកទទួល ។ ក្នុងរយៈពេលនេះ កំហុសទាំងឡាយ ដែលពាក់ព័ន្ធនិងករណីខាងក្រោម មន្ទីរប្រៃសណីយ៍ត្រូវតែចេញសងការខូចខាតដល់អ្នកផ្ញើ ឬអ្នកទទួលដូច មានចែងក្នុងតារាងពន្ធអាករដូចជាការធ្វើអោយបាត់បង់ ការលួចបាត់អន្តរវត្ថុទាំងអស់ចំពោះបញ្ញើអនុសិដ្ឋ និងប្រកាសតំលៃ ។

- **ការមិនទទួលខុសត្រូវរបស់ប្រៃសណីយ៍**

រាល់បញ្ញើប្រៃសណីយ៍ ដែលមានចែងក្នុងលក្ខខ័ណ្ឌខាងក្រោមនេះ មិនត្រូវបានទទួលខុសត្រូវចំពោះការខូចខាត ការបាក់បែក និង សំណងផ្សេងៗឡើយដូចជា :

1. ក្នុងករណីប្រធានសក្តិ (Force majeure)
2. បណ្តាអន្តរវត្ថុដែលពាក់ព័ន្ធនិងទំនិញហាមឃាត់ចែងក្នុងមាត្រា ២៣ ដោយអន្តរវត្ថុទាំងនោះត្រូវបានរឹបអូស ឬ បំផ្លាញចោល។
3. ក្នុងករណីឃាត់ទុកដោយរងចាំការវិនិច្ឆ័យរបស់សមត្ថកិច្ចជំនាញ។
4. ក្នុងករណីដែលអ្នកផ្ញើពុំបានធ្វើបណ្តឹងតវ៉ាក្នុងរយៈពេលកំណត់១ឆ្នាំចាប់ពីថ្ងៃទទួលផ្ញើ។

- **ការទទួលខុសត្រូវរបស់អ្នកផ្ញើ**

អ្នកផ្ញើបញ្ញើប្រៃសណីយ៍ ត្រូវទទួលខុសត្រូវនូវរាល់ការខូចខាត បណ្តាលមកពីអន្តរវត្ថុរបស់ខ្លួនផ្ញើអោយប្រលាក់ ឬខូចខាតដល់ បញ្ញើដទៃទៀតដូចមានចែងក្នុងមាត្រា ២៣។ ក្នុងករណីនេះដែរ ត្រូវបានលើកលែង បើកំហុសបណ្តាលមកពីប្រៃសណីយ៍ ឬការដឹកជញ្ជូន។

- **សំណងបញ្ញើក្នុងប្រទេស**

ក- <u>ការបាត់អនុសិដ្ឋ</u>(សងចំពោះផ្ញើ) : 30,000៛

ខ- <u>ការបាត់បញ្ញើឆាប់រហ័ស</u>(សងចំពោះអ្នកផ្ញើ)

-ទម្ងន់រហូតដល់ 03គក្រ: 30,000៛

-ទម្ងន់ពី03គក្រ រហូតដល់ 5គក្រ: 45,000៛

-ទម្ងន់ពី05គក្រ រហូតដល់ 07គក្រ: 90,000៛

-ទម្ងន់ពី07គក្រ រហូតដល់ 10គក្រ: 140,000៛

-ទម្ងន់ពី10គក្រ រហូតដល់ 20គក្រ: 180,000៛

គ- <u>ការបាត់បញ្ញើប្រៃសណីយ៍ភ័ណ្ឌ</u>

-សងតាមថ្លៃផ្ញើវិញទាំងអស់ទៅអោយអតិថិជន ដោយរួមមានទាំងសំណាងដែលអនុលោមទៅតាមបញ្ញើឆាប់រហ័សដូចមានចែកចំណុច"ខ" ។

ឃ- <u>សំណងនៃការបាត់បញ្ញើប្រៃសណីយ៍ដោយក្រុមហ៊ុនដឹកជញ្ជូន</u>

+ម្ចាស់មធ្យាបាយដឹកជញ្ជូនត្រូវសងមកប្រៃសណីយ៍កម្ពុជា:

-ទម្ងន់រហូតដល់ 10គក្រ : 250,000៛

-ទម្ងន់លើសពី 10គក្រ : 500,000៛

(ដោយបន្ថែមនូវទឹកប្រាក់សរុបបញ្ញើ) ដូចជាតែមប្រ៍របស់ប្រៃសណីយ៍ក្នុងករណីដែលបាវបញ្ញើបានបាត់បង់នូវអនុវអន្តរវត្ថុប្រកាសតម្លៃ ។

➢ **សំណងបញ្ញើអន្តរជាតិ**

ក-បញ្ញើអនុសិដ្ឋ (Registered Mail)

-ក្នុងមួយញ្ញើ : 100,000.00៛

ខ-ប្រៃសណីយភ័ណ្ឌ(Parcel Post)

-ក្នុងមួយញ្ញើ : 180,000.00៛

-បូកបន្ថែមតម្លៃក្នុង 1 គ.ក : 20,000.00៛/.គ.ក្រ

គ-បញ្ញើឆាប់រហ័ស(EMS)

-ក្នុងមួយញ្ញើ : 180,000.៛

-បូកបន្ថែមតម្លៃក្នុង 1 គ.ក : 20,000.00៛/.គ.ក្រ

-បូកបន្ថែមថ្លៃផ្ញើ(យោងតាមសាលាប័ត្រដើម) ។

**២.៣.៧ សារៈសំខាន់នៃវិស័យប្រៃសណីយ៍**

វិស័យប្រៃសណីយ៍កម្ពុជា បានផ្តល់នូវអត្ថប្រយោជន៍ និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ជាតិអោយមានការរីកចម្រើន។ សារៈសំខាន់នៃវិស័យប្រៃសណីយ៍រួមមានៈ

✓ បង្កើតនូវឱកាសការងារក្នុងស្រុក

- ✓ ជំរុញអោយមានការបង្កើតនូវការនាំចេញ នាំចូលអោយបានច្រើន
- ✓ សម្រួលដល់ការដឹកជញ្ជូនទំនិញ និងអ្នកដំណើរ និងការយកទំនិញតាមខ្លួនច្រើនហួសកំណត់
- ✓ កាត់បន្ថយលើការចំណាយក្នុងដឹកជញ្ជូន ការលើកដាក់ និងការចែកចាយបញ្ញើ
- ✓ កាត់បន្ថយហានិភ័យរាល់ការបាត់បង់ និងខូចខាតដោយផ្ញើរតាមតាក់ស៊ី
- ✓ បម្រើសេវាហិរញ្ញវត្ថុ និងផ្ទេរសាច់ប្រាក់
- ✓ ផ្តល់នូវភាពងាយស្រួលក្នុងការទំនាក់ទំនង និងទិញទំនិញតាមOnline
- ✓ ធានាសុវត្ថិភាព និងភាពទុកចិត្ត
- ✓ ចំណេញពេលវេលា និងថវិកា ក្នុងការនាំយកទំនិញពីកន្លែងមួយទៅកន្លែងមួយទៀត

ថ្លៃដឹកជញ្ជូនទាប សមរម្យ បើប្រៀបធៀបទៅនឹងក្រុមហ៊ុនដឹកជញ្ជូនដទៃទៀត ។

# ជំពូកទី ៣

# ការសិក្សាលើលទ្ធផល

## ៣.១ សមិទ្ធផលដែលសហគ្រាសប្រៃសណីយ៍កម្ពុជាសម្រេចបាន

### ៣.១.១ កំនើននៃបរិមាណបញ្ញើនាំចេញ

ដោយផ្អែកលើការអនុវត្តកន្លងមក យើងអាចសង្កេតឃើញថា បរិមាណបញ្ញើនាំចេញមានការកើនឡើងនិងថយចុះក្នុងកំឡុងពេលពីឆ្នាំនេះ គឺរវាងឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥ ។ ចំពោះប្រភេទបញ្ញើធម្មតា បរិមាណនៃបញ្ញើដែលទទួលបានពីបរទេសមានកំណើនជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ដែលតួលេខនេះកើនឡើង74.39%ធៀបនឹងឆ្នាំ២០១៤ និង8.37%ធៀបនឹងឆ្នាំ២០១៥ ។ ចំពោះការបញ្ជូនបញ្ញើនាំចេញទៅបរទេសវិញមានការកើននិងចុះមិនទៀងទាត់ ដែលបើធៀបនឹងឆ្នាំ២០១៤ និងឆ្នាំ២០១៥ គឺមានការធ្លាក់ចុះ1.5% និង4.28%រៀងគ្នា ។ យ៉ាងណាមិញចំពោះប្រភេទបញ្ញើឆាប់រហ័សវិញការទទួលបញ្ញើពីអន្តរជាតិមានប្រហាក់ប្រហែល និងការបញ្ជូនបញ្ញើចេញដែរ ប៉ុន្តែបើតាមស្ថិតិការទទួលបានមានការធ្លាក់ចុះ ហើយការនាំចេញមានការកើនឡើង6.94%ធៀបនឹងឆ្នាំ២០១៤ និង7.27%ធៀបទៅនឹងឆ្នាំ២០១៥ ។ ដោយឡែកបញ្ញើប្រៃសណីយ៍ភ័ណ្ឌ ការទទួល និងការបញ្ជូនចេញមានកំណើនជាវិជ្ជមានដូចគ្នា ។ សរុបមកយើងអាចសន្និដ្ឋានបានថាការបញ្ជូនបញ្ញើនាំចេញតាមប្រៃសណីយ៍កម្ពុជា កំពុងតែបង្ហាញសញ្ញាមួយដ៏ល្អប្រសើរ ពីមួយឆ្នាំទៅមួយឆ្នាំ បើទោះបីជាប្រជាជនកម្ពុជាយើង នៅតាមបណ្តាខេត្តនានានិងតំបន់ដាច់ស្រយាលមួយចំនួនមិនទាន់ជ្រួតជ្រាបពីបញ្ញើប្រៃសណីយ៍ក៏ដោយ ។

### ៣.១.២ ប្រសិទ្ធិភាពនៃការត្រួតពិនិត្យ

ក្រោយការអនុវត្តន៍កន្លងមក មន្ត្រីគយដែលប្រចាំការនៅប្រៃសណីយ៍កម្ពុជា នៅរៀងរាល់ម៉ោង និងថ្ងៃធ្វើការតែងតែរង់ចាំគយគន់ នៅចាំឃ្លាំមើល និងត្រួតពិនិត្យនូវភាពមិនប្រក្រតីណាមួយដែលអាចកើតឡើង ។ នៅឆ្នាំ២០១៤ មន្ត្រីគយ និងអាជ្ញាធរមានសមត្ថកិច្ចនៅប្រៃសណីយ៍កម្ពុជា បានទប់ស្កាត់ការនាំចេញទំនិញហាមឃាត់ និងជាប់កម្រិតកំណត់ជាច្រើនដូចជា វត្ថុសិល្បៈចម្លាក់ពីថ្មមានចំនួន១៥ករណី វត្ថុសិល្បៈចម្លាក់ធ្វើពីឈើមានចំនួន០៩ករណី តម្រូវឲ្យទៅសុំលិខិតអនុញ្ញាតឲ្យធ្វើការនាំចេញពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រីឯវត្ថុធ្វើពីសំណាករ៉ែ ឬថ្ម មានចំនួន០៧ករណីដែលសមត្ថកិច្ចគយតម្រូវ ឲ្យទៅសុំលិខិតអនុញ្ញាតនាំចេញពីក្រសួងរ៉ែនិងថាមពល ។ ករណីបម្រុងនាំចេញខ្សាច់មានចំនួន ១០ករណី ដែលជាប្រភេទខ្សាច់ទន្លេ និងខ្សាច់សមុទ្រ ដែល

ឈ្មួញមានបំណងផ្ញើទៅធ្វើពិសោធន៍នៅប្រទេសជប៉ុន និងចិន ភ្នាក់ងារគយក៏បានឲ្យពួកគេទៅស្នើសុំលិខិតអនុញ្ញាតពីធនាគារជាតិ ដោយយោងអនុក្រឹត្យលេខ២០៩ ស្តីពីការទប់ស្កាត់ទំនិញហាមឃាត់ និងជាប់កម្រិតកំណត់ មុនពេលធ្វើការនាំចេញ ។ ករណីគ្រឿងញៀនមាន០១ករណីលាក់ក្នុងកំប៉ុងត្រីខផ្ញើចេញទៅប្រទេសអូស្ត្រាលី ។ នៅក្នុងឆ្នាំ២០១៥ វត្ថុសិល្បៈចម្លាក់ពីថ្មមានចំនួន១៨ករណី វត្ថុសិល្បៈចម្លាក់ធ្វើពីឈើមានចំនួន១២ករណី ភ្នាក់ងារគយតម្រូវឲ្យទៅសុំលិខិតអនុញ្ញាតឲ្យធ្វើការនាំចេញពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រីឯវត្ថុធ្វើពីសំណាករ៉ែ ឬថ្ម មានចំនួន០៨ករណី ដែលសមត្ថកិច្ចគយតម្រូវឲ្យទៅសុំលិខិតអនុញ្ញាតនាំចេញពីក្រសួងរ៉ែ និងថាមពល។ ករណីបម្រុងនាំចេញខ្សាច់មានចំនួន ០៧ករណី ដែលជាប្រភេទខ្សាច់ទន្លេ និងខ្សាច់សមុទ្រ ដែលឈ្មួញមានបំណងផ្ញើទៅធ្វើពិសោធន៍នៅប្រទេសជប៉ុននិងចិន ភ្នាក់ងារគយក៏បានឲ្យពួកគេទៅស្នើសុំលិខិតអនុញ្ញាតពីធនាគារជាតិ ។ ដោយឡែកបញ្ហាគ្រឿងញៀនសមត្ថកិច្ចឃាត់ចាប់បានចំនួន០១ករណីដែលមន្ត្រីគយបានឆែកឆេរឃើញ និងមានការសង្ស័យទៅលើអាវទ្រនាប់ដែលមានទម្ងន់ធ្ងន់ខុសពីធម្មតា ក្រោយមកក៏បានស្នើសុំការសហការណ៍ ពីមន្ត្រីប៉ូលីសគ្រឿងញៀនយកទៅត្រួតពិនិត្យឃើញមានផ្ទុកសារធាតុញៀន ដែលអ្នកផ្ញើរជាជនជាតិវៀតណាម បម្រុងផ្ញើចេញទៅប្រទេសអូស្ត្រាលី ។ ម្យ៉ាងទៀតករណីការផ្ញើអាវុធមានលក្ខណៈជាកាំភ្លើងបាញ់ខ្យល់ (បាញ់សត្វ) ក៏មាន០១ករណីផងដែរ ដែលតម្រូវឲ្យមានលិខិតអនុញ្ញាតពីក្រសួងមហាផ្ទៃ ។ នៅឆ្នាំ២០១៦ វត្ថុសិល្បៈចម្លាក់ពីថ្មមានចំនួន០៨ករណី វត្ថុសិល្បៈចម្លាក់ធ្វើពីឈើមានចំនួន១០ករណី ភ្នាក់ងារគយតម្រូវឲ្យទៅសុំលិខិតអនុញ្ញាតឲ្យធ្វើការនាំចេញពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រីឯវត្ថុធ្វើពីសំណាករ៉ែ ឬថ្ម មានចំនួន០៤ករណី ដែលសមត្ថកិច្ចគយតម្រូវឲ្យទៅសុំលិខិតអនុញ្ញាតនាំចេញពីក្រសួងរ៉ែនិងថាមពល។ ករណីបម្រុងនាំចេញខ្សាច់មានចំនួន ០២ករណី ដែលជាប្រភេទខ្សាច់ទន្លេ និងខ្សាច់សមុទ្រ ដែលឈ្មួញមានបំណងផ្ញើទៅធ្វើពិសោធន៍នៅប្រទេសជប៉ុន ភ្នាក់ងារគយក៏បានឲ្យពួកគេទៅស្នើសុំលិខិតអនុញ្ញាតពីធនាគារជាតិ ។ ដោយឡែកបញ្ហាគ្រឿងញៀន និងអាវុធយុទ្ធភ័ណ្ឌ ពុំមានសកម្មភាពនោះទេ ។ សរុបមកយើងអាចសន្និដ្ឋានបានថា ការងារត្រួតពិនិត្យរូបវន្តទៅលើបញ្ញើប្រៃសណីយ៍ នៅតែអនុលោមទៅតាមច្បាប់និងបទបញ្ញត្តិជាធរមាន ហើយទទួលបានលទ្ធផលជាវិជ្ជមាន ។ ពីមួយឆ្នាំទៅមួយឆ្នាំ ករណីនៃការផ្ញើវត្ថុហាមឃាត់កាន់តែមានការថយចុះ ដែលអាចធានាបាននូវសុវត្ថិភាព និងហានិភ័យផ្សេងៗប្រកបដោយប្រសិទ្ធិភាពនិងប្រសិទ្ធិផល ។

**រូបភាពទី១០៖ មុខទំនិញដែលបានត្រួតពិនិត្យនិងទប់ស្កាត់ការនាំចេញ**




### ៣.១.៣ ការវេចខ្ចប់ប្រកបដោយស្តង់ដារ

ការវេចខ្ចប់អាចមានសុវត្ថិភាព និងភាពរឹងមាំទៅបានដោយសារតែមានការយកចិត្តទុកដាក់ខ្ពស់ ឧស្សាហ៍ព្យាយាម និងរួសរាយរាក់ទាក់របស់ភ្នាក់ងារប្រៃសណីយ៍ និងការបណ្តុះបណ្តាលបន្ថែមពីថ្នាក់ដឹកនាំ កញ្ចប់បញ្ញើត្រូវបានវេចខ្ចប់ប្រកបដោយចំណេះដឹង និងជំនាញច្បាស់លាស់ ។ រាល់កញ្ចប់បញ្ញើប្រៃសណីយ៍ទាំងអស់ត្រូវបានវេចខ្ចប់ជាមួយនឹងផ្លាស្ទិច កេសស្នោរប្រអប់ការពារចំពោះវត្ថុដែលផុយស្រួយ ដូចជាកែវ ចាន វត្ថុសិល្បៈ និងគ្រឿងអេឡិចត្រូនិកដទៃទៀត ឯចំពោះម្ហូបអាហារ នំនែក ផ្អក ប្រហុក ម្ទូរ ជាដើម ត្រូវបានខ្ចប់ដោយថង់ផ្លាស្ទិចឬក្រឡ ដើម្បីការពារកុំឲ្យធ្លាយ ផ្ទុះ រហែក និងហៀរទឹក ។ តាមទិន្នន័យបានបង្ហាញថានៅឆ្នាំ២០១៤ មានបញ្ញើបញ្ជូនចេញចំនួន៨០១,៩១៩កញ្ចប់ ក្នុងនោះមានបញ្ញើចំនួន០៥កញ្ចប់ហៀរទឹកធ្វើឲ្យសើមកេស បញ្ញើចំនួន០៧កញ្ចប់ ដែលត្រូវបាក់បែកពេលទៅដល់ប្រទេសទទួល និងមានបញ្ញើចំនួន១០កញ្ចប់ដែលខូចគុណភាព ។ នៅឆ្នាំ២០១៥ មានបញ្ញើបញ្ជូនចេញចំនួន៨២៣,២៥២កញ្ចប់ ក្នុងនោះមានបញ្ញើចំនួន០៧កញ្ចប់ហៀរទឹកធ្វើឲ្យសើមកេស បញ្ញើចំនួន០៤កញ្ចប់ ដែលត្រូវបាក់បែកពេលទៅដល់ប្រទេសទទួល និងមានបញ្ញើចំនួន០៨កញ្ចប់ដែលខូចគុណភាព ។ នៅឆ្នាំ២០១៦ មានបញ្ញើបញ្ជូនចេញចំនួន៧៩៦,៨៥២កញ្ចប់ ក្នុងនោះមានបញ្ញើចំនួន០៣កញ្ចប់ហៀរទឹកធ្វើឲ្យសើមកេស បញ្ញើចំនួន០៣កញ្ចប់ ដែលត្រូវបាក់បែកពេលទៅដល់ប្រទេសទទួល និងមាន

បញ្ញើចំនួន០៣កញ្ចប់ដែលខូចគុណភាព ។ នេះសរបញ្ជាក់ឲ្យឃើញថា បញ្ហាការវេចខ្ចប់កាន់តែមានការធ្លាក់ចុះជាលំដាប់បើប្រៀបធៀប កញ្ចប់បញ្ញើដែលខូចខាតក្នុងអំឡុងពេលបីឆ្នាំនេះ ។

ដោយឡែកចំពោះ វត្ថុដែលប្រៃសណីយ៍កម្ពុជាហាមឃាត់មិនឲ្យនាំចេញ ឬប្រៃសណីយ៍បរទេសមិនឲ្យនាំចូល មិនត្រូវបានអនុញ្ញាតឲ្យផ្ញើចេញនោះទេ ក្នុងគោលបំណងធានាសុវត្ថិភាពនៃការទទួល និងរក្សាទុកកញ្ចប់បញ្ញើប្រកបដោយគុណភាព ។ មិនត្រឹមតែការវេចខ្ចប់មានស្តង់ដារបច្ចេកទេស និងអនាម័យប៉ុណ្ណោះទេ តែកំនើននៃការលក់ប្រអប់វេចខ្ចប់ប្រៃសណីយ៍ក៏មានការកើនឡើងផងដែរ ដោយតួលេខចំណូលពីការលក់ប្រអប់វេចខ្ចប់សម្រាប់ឆ្នាំ២០១៦មាន ៥៨,៦៩៤.៥៨ ដុល្លារអាមេរិកស្មើនឹង០.៦២%នៃចំណូលសរុបឆ្នាំ២០១៦ ។

### ៣.១.៤ ការរុករកឃើញ និងទប់ស្កាត់វត្ថុហាមឃាត់

ការដាក់ឲ្យត្រួតពិនិត្យកញ្ចប់បញ្ញើដោយប្រើប្រាស់ម៉ាស៊ីនស្កេន ត្រូវបានប្រព្រឹត្តទៅដោយទទួលបានជោគជ័យមួយរយភាគរយ ទៅលើកញ្ចប់បញ្ញើនាំចេញទៅអន្តរជាតិស្ទើរតែទាំងស្រុង ។ ក្រោយពីការដាក់ឲ្យដំណើរការម៉ាស៊ីនស្កេននេះ ជាលទ្ធផលសហគ្រាសប្រៃសណីយ៍កម្ពុជាបានចូលរួមជាមួយមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្ការ និងបង្ក្រាបនូវការនាំចេញនូវវត្ថុដែលមានសារធាតុវិទ្យុសកម្ម ដូចជាទូរស័ព្ទដៃ និងកុំព្យូទ័រមានថ្មនៅខាងក្នុង គ្រឿងអេឡិចត្រូនិកដែលមានប្រតិកម្មជាមួយនឹងម៉ាស៊ីនស្កេន ដាវ អាវុធ ជាតិផ្ទុះ និងវត្ថុដទៃទៀតដែលគំរាមកំហែងដល់សុខភាព សុខមាលភាព អាយុជីវិត និងសន្តិសុខសង្គម ។ ជាក់ស្តែងនៅវេលាម៉ោង១០និង៣០នាទី ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧ កន្លងទៅ បន្ទាប់ពីទទួលបានរូបភាពដ៏គួរឲ្យសង្ស័យនិងជឿជាក់ ដែលផ្តល់ដោយម៉ាស៊ីនស្កេន មន្ត្រីគយប្រៃសណីយ៍បានសហការជាមួយនឹងកិច្ចតុលាការ មន្ត្រីប៉ូលីសគ្រឿងញៀន និងភ្នាក់ងារប្រៃសណីយ៍ធ្វើតេស្តពិសោធន៍ចាប់បានកញ្ចប់បញ្ញើនាំចេញ ចំនួន០១កាតុង ដែលផ្ទុកសារធាតុប្រភេទមេតំផេតាមីនចំនួន៦កញ្ចប់ មានទម្ងន់សរុប១៨៥,២៨ក្រាម លួចបង្កប់ក្នុងស្បែកជើងស្ត្រី ដែលអ្នកផ្ញើរមានបំណងផ្ញើរចេញទៅប្រទេសអូស្ត្រាលី នៅពេលល្ងាចថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ (មុន០១ថ្ងៃដែលចាប់បាន) ដែលនៅពេលនោះបុគ្គលិកប្រៃសណីយ៍និងមន្ត្រីមានសមត្ថកិច្ចមិនបានមើលឃើញដោយភ្នែកទទេរក៏ទទួល និងបញ្ជូនទៅកាន់កន្លែងស្កេនទើបប្រទះឃើញ ។

### ៣.១.៥ ការបញ្ជូនបញ្ញើមានភាពឆាប់រហ័ស

ចំពោះបណ្តាញ មានទំនាក់ទំនងក្នុងស្រុកប្រៃសណីយ៍កម្ពុជាមានទីតាំងអាជីវកម្មចំនួន៥៤កន្លែងក្នុងរាជធានីភ្នំពេញ ខេត្តក្នុងព្រះរាជាណាចក្រកម្ពុជាដែលជួយសម្រួលដល់ការទទួល និង

ចែកចាយទំនិញដែលផ្ញើតាមប្រៃសណីយ៍នៅទូទាំងប្រទេស បានលឿន និងឆាប់រហ័ស ។ ហើយបណ្តាញទំនាក់ទំនងអន្តរជាតិរួមមាន១៩២ប្រទេស ជាសមាជិករបស់សហភាពប្រៃសណីយ៍សកល UPU ដូចជា China Post , India Post , Deutsch Post , UPS… និងមានក្រុមហ៊ុនដឹកជញ្ជូនបញ្ញើអន្តរជាតិធំៗក្នុងពិភពលោកដូចជា Elite TransportCo.,Ltd(Malaysia Airline), Thai Airways , Dragon air (Hong Kong)ជាដើម ។ រយៈពេលដែលទំនិញទៅដល់មាន១៥ថ្ងៃសម្រាប់បញ្ញើធម្មតា (LC/AO) , ចាប់ពី៧-១០ថ្ងៃ គឺសម្រាប់សេវាបញ្ញើប្រៃសណីយ៍ភ័ណ្ឌ និង៣-៥ថ្ងៃ សម្រាប់សេវាបញ្ញើប្រៃសណីយ៍ឆាប់រហ័ស។ លើសពីនេះទៅទៀតចំពោះការបំពេញបែបបទនាំចេញទំនិញ តាមប្រៃសណីយ៍កម្ពុជាមានលក្ខណៈងាយស្រួល ដោយមិនចាំបាច់ធ្វើប្រតិវេទន៍តាមប្រព័ន្ធASYCUDA ហើយជំនួសដោយការប្រើប្រាស់ប្រតិវេទន៍គយសង្ខេប(Declaration CN22/CN23) ដែលមានសុគស្នាញសម្រាប់អ្នកនាំចេញម្តងម្កាល ឬគ្មានលក្ខណៈពាណិជ្ជកម្ម ។ ម្យ៉ាងវិញទៀតប្រព័ន្ធ IPS បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនលទ្ធភាពនៃការគ្រប់គ្រង និងតាមដានបញ្ញើជាលក្ខណៈអន្តរជាតិអោយកាន់តែប្រសើរឡើង និងពន្លឿនការបញ្ជូនទិន្នន័យទៅទូទាំងសកល ព្រមទាំងមានការព្រីន Receipt ជូនឲ្យអតិថិជនភ្លាមៗបន្ទាប់ពីពួកគេផ្ញើរួច ។ ជាពិសេសជាងនេះទៅទៀត ប្រៃសណីយ៍កម្ពុជាមានភ្នាក់ងារបំរើសេវាកម្មអតិថិជនតាមOnline សម្រាប់អោយពួកគេធ្វើការ ឆ្លើយតបទៅនឹងការសួរនាំព័ត៌មាន និងបញ្ចេញមតិរិះគន់តាមរយៈមធ្យោបាយអេឡិចត្រូនិច ដោយមិនបាច់ចំណាយពេលវេលាធ្វើដំណើរទៅកាន់សាខាប្រៃសណីយ៍ផ្ទាល់នោះទេ ។

### ៣.១.៦ ទំនុកចិត្ត និងភាពពេញចិត្តរបស់អតិថិជន

ទំនុកចិត្តនិងភាពពេញចិត្តរបស់អតិថិជនត្រូវបានគេវាយតម្លៃ តាមរយៈការស្ទង់មតិ និងការសាកសួរយោបល់ផ្ទាល់របស់ពួកគេ ចំពោះសំណួរតែមួយគត់ដែលសួរថា "តើអ្នកយល់បែបណាចំពោះការប្រើប្រាស់សេវាកម្មបញ្ញើប្រៃសណីយ៍នាំចេញ? សេវាកម្មនេះល្អ? មិនល្អ? ឬមិនដឹង?" រួចឲ្យក្រដាសចំនួន០៣ពណ៌ គឺពណ៌បៃតងសរសេរអក្សរ "ល្អ" ពណ៌លឿងសរសេរអក្សរ "មិនដឹង" និងពណ៌ក្រហមអក្សរ"មិនល្អ" ប្រគល់ជូនមនុស្សចំនួន៥០០នាក់ក្នុងរាជធានីភ្នំពេញក្នុងពេលសកម្មភាពផ្សព្វផ្សាយពីសេវាកម្មប្រៃសណីយ៍កម្ពុជា ។ ជាលទ្ធផលទទួលបានពីមនុស្សដែលបានចូលរួមឆ្លើយ និងផ្តល់យោបល់ផ្សេងៗគ្នា យើងទទួលបានក្រដាសពណ៌បៃតងចំនួន៤១៩សន្លឹក ពណ៌ក្រហមចំនួន៣៨សន្លឹក និងពណ៌លឿងចំនួន៤១សន្លឹក ។ ដូច្នេះយើងអាចសន្និដ្ឋានបានថា អតិថិជនភាគច្រើនជឿជាក់លើការប្រើប្រាស់សេវាកម្មបញ្ញើប្រៃសណីយ៍ ដោយហេតុផលថាមានការធានារ៉ាប់រងល្អ ការទទួលខុសត្រូវរាល់ការបាត់បង់ និងសេវាកម្មឆាប់រហ័សទាន់ចិត្ត ។

**រូបភាពទី១១៖ លទ្ធផលនៃការវាស់ស្ទង់ភាពពេញចិត្តរបស់អតិថិជន**




## ៣.២ បញ្ហាប្រឈម

### ៣.២.១ បញ្ហាពេលទទួលបញ្ញើពីអតិថិជន

ទោះបីជាការទទួលបញ្ញើបានច្រើន និងមានការរក្សាទុកប្រកបដោយសុវត្ថិភាពយ៉ាងណាក៏ដោយ ប៉ុន្តែអាស័យដ្ឋានអតិថិជននៅតែជាបញ្ហាញឹកញាប់មួយ ដែលតែងតែកើតមានឡើងដោយសារតែបុគ្គលិកមិនមានចំណេះដឹងគ្រប់គ្រាន់ ឬមានការធ្វេសប្រហែសមិនបានពិនិត្យត្រឹមត្រូវ និងមិនបានពន្យល់ណែនាំអតិថិជនឲ្យបានច្បាស់លាស់ ។ បញ្ហាទាំងនោះរួមមានដូចជាបញ្ហាលេខផ្ទះ លេខផ្លូវមានភាពស៊ាំញ៉ាំ ពិបាកក្នុងការចែកបញ្ញើដល់អាស័យដ្ឋានអតិថិជន, បញ្ហាលេខទូរស័ព្ទទំនាក់ទំនងមិនត្រឹមត្រូវ ឬភ្លេចមិនដាក់លេខទូរស័ព្ទ, បញ្ហាលេខកូដតំបន់មិនត្រឹមត្រូវ ឬមិនបានដាក់អាស័យដ្ឋានមិនគ្រប់គ្រាន់ គ្មានលេខផ្ទះ គ្មានលេខផ្លូវ, បញ្ហាឈ្មោះជាន់គ្នា, បញ្ហាអ្នកទទួលបានប្តូរទីលំនៅទៅកាន់អាស័យដ្ឋានថ្មី ។

បញ្ហាទាំងអស់នេះសុទ្ធជាបញ្ហារសើប និងជាបញ្ហាដែលតែងកើតឡើងញឹកញាប់ជាងគេក្នុងចំណោមបញ្ហាប្រឈមដទៃទៀត ដែលនេជាហេតុធ្វើឲ្យខាតឯកសារសលាកប័ត្រផ្ញើនៅពេលអតិថិជនបានសរសេរខុស លុប ឬឆូត គូសវាសពិបាកមើល និងមើលមិនដាច់ ។ លើសពីនេះទៅទៀតគឺបញ្ញើមិនអាចបញ្ជូនផ្ញើចេញ ហើយមិនអាចទំនាក់ទំនងទៅកាន់អ្នកផ្ញើបានព្រោះមិនបាន

ដាក់លេខទំនាក់ទំនង និងធ្វើឲ្យបញ្ញើត្រូវរក្សាទុកចោលដោយគ្មានម្ចាស់ ខូចគុណភាព ប៉ះពាល់ដល់បរិស្ថាន និងកិត្តិយសរបស់ក្រុមហ៊ុន ។

**៣.២.២ បញ្ហាចន្លោះប្រហោងនៃការត្រួតពិនិត្យនៅតាមមន្ទីរប្រៃសណីយ៍ខេត្ត**

ជាទូទៅ កញ្ចប់ប្រៃសណីយ៍ទាំងអស់ មិនថានៅតាមបញ្ជរប្រៃសណីយ៍នៅភ្នំពេញ ឬនៅតាមមន្ទីរប្រៃសណីយ៍ខេត្តនោះទេ បន្ទាប់ពីធ្វើការផ្ទៀងផ្ទាត់ លេខបញ្ញើ ទម្ងន់ និងតម្លៃចប់សព្វគ្រប់នឹងត្រូវបញ្ជូនមកការិយាល័យកណ្តាលប្រៃសណីយ៍វត្តភ្នំ ដើម្បីបែងចែកតាមទិសដៅ ឬប្រទេសទទួល និងរៀបចំឯកសារដឹកជញ្ជូនចេញ ។ បាតុភាពនេះកើតឡើងដោយមូលហេតុពីរយ៉ាងគឺទីមួយមន្ត្រីគយ និងរដ្ឋាករប្រៃសណីយ៍មានប្រចាំការតែនៅទីស្នាក់ការប្រៃសណីយ៍កម្ពុជាកណ្តាលប៉ុណ្ណោះធ្វើការត្រួតពិនិត្យរូបវ័ន្ត និងទីពីរគឺមានតែយន្តហោះនៃឃ្លាំងទំនិញអាកាសយានដ្ឋានអន្តរជាតិភ្នំពេញតែមួយគត់ដែលទទួលបានសិទ្ធិ និងអាជ្ញាប័ណ្ណស្របច្បាប់ក្នុងការដឹកជញ្ជូនបញ្ញើទៅកាន់អន្តរជាតិ។ ដូច្នេះវាបានឆ្លុះបញ្ចាំងឲ្យឃើញពីចំណុចខ្សោយ ដែលអាចឲ្យបុគ្គលខិលខូច និងឧក្រិដ្ឋជន ឆ្លៀតឱកាសបន្លំលួចលាក់វត្ថុខុសច្បាប់នៅតាមខេត្តមុនពេលដឹកជញ្ជូនមកដល់ភ្នំពេញ។

**៣.២.៣ ធនធានមនុស្សនៅមានកម្រិត**

បច្ចុប្បន្ន បុគ្គលិកចាស់ៗមួយចំនួនបានចូលនិវត្តន៍ មួយចំនួនទៀតត្រូវបានផ្ទេរឲ្យទៅធ្វើការនៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ផ្សេងទៀត ហើយបុគ្គលិកចូលថ្មីមានខ្លះក៏គ្មានសញ្ញាប័ត្រ បរិញ្ញាបត្រ ខ្លះខ្វះជំនាញ ឯខ្លះទៀតខ្វះបទពិសោធន៍ ទើបបង្ករឲ្យមានបញ្ហាមួយចំនួនដូចជាការវេចខ្ចប់មិនបានល្អ ដែលធ្វើឲ្យកញ្ចប់បញ្ញើធ្លាយ ឬត្រូវទឹករលួយ ប្រលាក់ សើម ខូចខាត និងបាក់បែកជាដើម។ ពេលខ្លះកញ្ចប់បញ្ញើត្រូវបានទទួល និងរក្សាទុកនៅឃ្លាំងប្រៃសណីយ៍រងចាំផ្ញើចេញ ស្រាប់តែជ្រាបទឹករលួយប្រអប់វេចខ្ចប់ និងត្រូវឲ្យម្ចាស់បញ្ញើត្រឡប់មកវេចខ្ចប់សារឡើងវិញ ឬពេលខ្លះត្រូវសងលុយទៅម្ចាស់ដោយសារតែការខូចគុណភាព ឬក៏កម្ចាស់មិនពេញចិត្តនឹងផ្ញើតទៅទៀត។ ម្យ៉ាងវិញទៀត បុគ្គលិកមួយចំនួនមានចំណេះដឹងតិចតួច ឬមិនបានយល់ច្បាស់ពីច្បាប់ និងការអនុញ្ញាតការនាំចេញបញ្ញើទៅកាន់បណ្តាប្រទេសទទួល ធ្វើឲ្យទំនិញដែលអតិថិជនផ្ញើត្រូវបានឃាត់ទុកឬកម្ទេចចោល ធ្វើឲ្យខាតបង់ថវិកា ។

**៣.២.៤ ការផ្ញើទំនិញដែលហាមឃាត់ និងទំនិញមានវេទយិតភាព**

បញ្ហាកើតមានឡើងលើទំនិញដែលហាមឃាត់ និងទំនិញមានវេទយិតភាពរួមមាន៖

-ការលួចលាក់បង្កប់នូវសារធាតុញៀននៅក្នុងកំប៉ុងត្រីខ ស្បែកជើង ប៊ិច ប៉ុងអារទ្រនាប់ ។ល។ ដែលកន្លងមក ទប់ស្កាត់បានខ្លះនៅប្រទេសកម្ពុជា ឯខ្លះទៀតរកឃើញនៅប្រទេស

ទទួល ។ ជាក់ស្តែងនៅឆ្នាំ២០១៦ មានមួយករណីដែលអ្នកផ្ញើរលាក់សារធាតុញៀនក្នុងប្រអប់ប៊ិច និងផ្ញើបាននាំចេញបានជោគជ័យទៅដល់ប្រទេសទទួល ។

-ការបង្កប់នូវគ្រឿងអលង្ការ មាស ពេជ្រ កែវកងក្នុងសំលៀកបំពាក់ដែលផ្ញើអោយមានការបាត់បង់ និងទង្វើលាក់លុយនៅក្នុងសឺមី ឬស្រោមសំបុត្រដែលផ្ញើអោយជនខិលខូចលួចដកយក ។ ម្តងម្កាលម្ចាស់បញ្ញើគិតថាលាក់ក្រវិល ខ្សែក ក្នុងសំលៀកបំពាក់មិនឲ្យភ្នាក់ងារប្រៃសណីយ៍បានដឹង ប៉ុន្តែមួយអាទិត្យក្រោយមកគាត់បានទំនាក់ទំនងទៅអ្នកទទួលសួររកមិនឃើញមានគ្រឿងអលង្ការទាំងនោះឡើយ គាត់ក៏បានប្តឹងតវ៉ាទៅខាងប្រៃសណីយ៍កម្ពុជាឲ្យចេញសងគាត់ ប៉ុន្តែមិនមានប្រសិទ្ធិភាពនោះទេ ព្រោះបញ្ញើរបស់គាត់ជាវត្ថុហាមឃាត់ ។

-ការផ្ញើនូវសារធាតុរាវ ឡេ ម្សៅលាយលាបមុខ និងភេសជ្ជៈមួយចំនួនដែលមិនត្រូវបានអនុញ្ញាតអោយផ្ញើចេញដោយសារមានប្រតិកម្មជាមួយម៉ាស៊ីនស្កេន ។ ករណីនេះច្រើនប្រទះឃើញនៅឃ្លាំងទំនិញអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដែលម្ចាស់បញ្ញើទទូចចង់ផ្ញើចេញ បើទោះជាមានការពន្យល់ពីភ្នាក់ងារប្រៃសណីយ៍ក៏ដោយ ប៉ុន្តែចុងក្រោយកញ្ចប់បញ្ញើនោះត្រូវបញ្ជូនមកកាន់ទីស្នាក់ការប្រៃសណីយ៍កណ្តាលវិញ ដើម្បីឲ្យម្ចាស់មកដោះស្រាយ ។

-ការផ្ញើរនូវវត្ថុដែលងាយឆាបឆេះ ឬងាយផ្ទុះអាចបណ្តាលអោយផ្ទុះ ឬធ្លាក់យន្តហោះ។ ករណីនេះមិនដែលជួបប្រទះនោះទេ ដោយសារតែមានការទប់ស្កាត់នៅមុនពេលទទួលបញ្ញើ ព្រោះទំនិញដែលម្ចាស់យកមកផ្ញើរមានជាប់ប្រឡាក់ប្រេងកាត ប្រេងម៉ាស៊ីនជាដើម។

-ការនាំចេញគ្រប់បណ្តាសត្វមានជីវិតទាំងអស់ ដែលត្រូវហាមឃាត់ និងមិនអនុញ្ញាតអោយធ្វើការនាំចេញ ។

### ៣.២.៥ បញ្ហាពាក់ព័ន្ធនឹងការដឹកជញ្ជូនបញ្ញើ

#### ក. ប្រព័ន្ធIPS មិនដំណើរការ

ទោះបីជាយើងមានរថយន្តដឹកជញ្ជូនទំនិញ ដែលអាចបញ្ជូនបញ្ញើទៅកាន់ឃ្លាំងទំនិញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញបានលឿន និងឆាប់រហ័សក៏ពិតមែន ប៉ុន្តែប្រសិនបើប្រព័ន្ធIPS មិនដំណើរការ ទិន្នន័យមិនអាចប្រតិបត្តិការបញ្ចូលទៅក្នុងប្រព័ន្ធតាមដានបានទេ មានន័យថារាល់ដំណើរការដឹកជញ្ជូនកញ្ចប់បញ្ញើទាំងអស់ត្រូវបានផ្អាកជាបណ្តោះអាសន្ន និងត្រូវរង់ចាំរហូតដល់ប្រព័ន្ធដំណើរការឡើងវិញ ជាហេតុនាំឲ្យការដឹកជញ្ជូនមិនអាចធ្វើទៅបាន ។

**ខ. អាកាសធាតុ**

បញ្ញើប្រៃសណីយ៍នៅតាមមន្ទីរប្រៃសណីយ៍ខេត្តត្រូវបញ្ជូនមកកាន់ភ្នំពេញ ដើម្បីផ្ញើចេញទៅក្រៅប្រទេសឲ្យបានទាន់ពេលវេលា ។ ជួនកាលនៅខេត្តឬតំបន់មួយចំនួនទទួលរងនូវខ្យល់ព្យុះ ទឹកជំនន់ និងគ្រោះធម្មជាតិផ្សេងៗ ធ្វើឲ្យការដឹកជញ្ជូនមានការយឺតយ៉ាវ និងចំណាយពេលវេលាយូរដើម្បីទៅដល់ប្រទេសគម្យដ្ឋាន ។

**គ. បញ្ហាចរាចរណ៍**

ការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ កំពុងផ្លាស់ប្តូរស្ថានភាពចរាចរណ៍នៅរាជធានីភ្នំពេញឲ្យកាន់តែយ៉ាប់យឺនទៅៗ ដូចជាការកសាងស្ពាន ស្ថាបនាផ្លូវ ធ្វើឲ្យស្ទះខ្លាំង ដែលបណ្តាលឲ្យការដឹកជញ្ជូនមិនអាចប្រព្រឹត្តទៅដោយរលូនបានទេ ដែលតម្រូវឲ្យភ្នាក់ងារដឹកជញ្ជូនបញ្ញើធ្វើការបន្ថែមរហូតដល់ពេលយប់ ។

**ឃ. បញ្ញើសំណល់**

បញ្ញើគ្រប់ប្រភេទដែលចែកឲ្យអ្នកទទួលពុំបាន ហើយពុំអាចផ្ញើត្រឡប់ទៅអ្នកផ្ញើវិញបានដោយប្រការណាមួយនោះត្រូវចាត់ទុកជាបញ្ញើសំណល់ ។ លក្ខណៈមិនគ្រប់គ្រាន់នេះមានដូចខាងក្រោម៖

1. គ្មានអាស័យដ្ឋានអ្នកផ្ញើ
2. ពុំអាចរកអាស័យដ្ឋានអ្នកផ្ញើឃើញ
3. គ្មានអាស័យដ្ឋានអ្នកផ្ញើ និងគ្មានសញ្ញាសំគាល់ ឬត្រាថ្ងៃ ខែរបស់ប្រទេសផ្ញើ (បញ្ញើអន្តរជាតិ)
4. ភណ្ឌិកាដែលគ្មានសំណូមពរឲ្យបញ្ជូនត្រឡប់ ឬឲ្យបោះបង់ចោលក្នុងករណីចែកមិនបាន
5. អន្តរវត្ថុលាយលំដែលពុំអាចរកអាស័យដ្ឋានរបស់អ្នកផ្ញើ ឬអ្នកទទួលឃើញ
6. ចំពោះអាណត្តិដែលពុំអាចបើកឲ្យអ្នកទទួលបាន និងពុំអាចសងប្រាក់ទៅអ្នកផ្ញើវិញក្នុងរយៈពេលមួយឆ្នាំ ។ នៅការិយាល័យដែលមានបញ្ញើសំណល់ត្រូវប្រមូលផ្តុំបញ្ជូនមកផ្នែកគ្រប់គ្រងបញ្ញើសំណល់ នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

## ៣.៣ ដំណោះស្រាយ

### ៣.៣.១ ការបញ្ជូនបន្ត បញ្ជូនត្រឡប់ និងពាក្យសុំកែប្រែអាស័យដ្ឋាន

#### ៣.៣.១.១ ការបញ្ជូនបន្ត

រាល់បញ្ញើដែលអាចបញ្ជូនបន្តបានត្រូវស្ថិតនៅក្នុងករណីដូចខាងក្រោមៈ

១. អ្នកទទួលផ្លាស់អាស័យដ្ឋានតែង បានប្រកាសប្រាប់ឲ្យការិយាល័យប្រៃសណីយ៍ដឹង ឬក៏គ្មានឲ្យដំណឹងប៉ុន្តែកត្តាបានដឹងអាស័យដ្ឋានថ្មី ។

២. ផ្ញើខុសទិសដៅ។

៣. អាស័យដ្ឋានខុស។

៤. អ្នកផ្ញើ ឬអ្នកទទួលសំណូមពរ ។

៥. រាល់លិខិតនិងប្រៃសណីយ៍ប័ត្រ ដែលអ្នកទទួលបានផ្លាស់អាស័យដ្ឋានទៅនៅក្រៅប្រទេស ត្រូវបញ្ជូនបន្តដោយគិតអាករបន្ថែម រួចហើយបោះត្រា (ក្នុងករណីដែលអ្នកទទួលសំណូមពរ)។

៦. ក្នុងករណីដែលលិខិតត្រូវផ្ញើឲ្យអ្នកទទួល (អ្នកផ្ញើនិងអ្នកទទួលនៅក្នុងប្រទេសតែមួយ) តែអ្នកទទួលចេញទៅក្រៅប្រទេស លិខិតនេះមិនអាចបញ្ជូនបន្តបានទេ ។

៧. ដោយឡែកចំពោះប្រៃសណីយ៍ភ័ណ្ឌ ទាំងការបញ្ជូនបន្តនៅក្នុងប្រទេស និងក្រៅប្រទេស អ្នកផ្ញើ ឬអ្នកទទួលដែលមានសំណូមពរឲ្យបញ្ជូនបន្ត រាល់ពន្ធអាករដែលជាប់ពាក់ព័ន្ធ អ្នកផ្ញើសំណូមពរត្រូវបង់ជាដាច់ខាត។

៨. បញ្ញើឆាប់រហ័ស៖ ការបញ្ជូនបន្តចំពោះលិខិត គឺមិនត្រូវបានគិតពន្ធអាករឡើយ ដោយឡែកចំពោះកញ្ចប់ត្រូវគិតអាករដឹកជញ្ជូន។

៩. អាណត្តិ៖ បញ្ជូនបន្តត្រូវបានអនុវត្តដូចមានចែងក្នុងបញ្ញើប្រៃសណីយ៍ដែរ ដោយឡែកចំពោះការបញ្ជូនបន្តមិនត្រូវបង់ពន្ធអាករទេ ហើយអាចបញ្ជូនបានតែចំពោះការិយាល័យប្រៃសណីយ៍ណាដែលមានបើកអាណត្តិ។

១០. រាល់ការបញ្ជូនបន្តជាលិខិតប្រៃសណីយ៍ប័ត្រ៖ ត្រូវច្រកចូលក្នុងស្រោម CN14 ដោយចំហរ។

**៣.៣.១.២ ការបញ្ជូនត្រឡប់**

រាល់បញ្ញើទាំងឡាយដែលបានបែងចែកពុំបាន ដូចមានរៀបរាប់ក្នុងមាត្រា ១២៩-១៣០ ត្រូវបានបញ្ជូនត្រឡប់ទៅឲ្យការិយាល័យដើមវិញ។ របៀបបញ្ជូនត្រូវបានអនុវត្តដូចខាងក្រោមនេះ៖

១-ប្រភេទបញ្ញើប្រៃសណីយ៍ត្រូវបានបញ្ជូនត្រឡប់ (ទោះគ្មានសំណូមពរពីអ្នកផ្ញើក៏ដោយ) តាមផ្លៃរាប។ ដោយឡែកចំពោះកលិកប័ត្រ ក្នុងករណីយល់ឃើញថាគ្មានសារៈសំខាន់អាចមិនបញ្ជូនទៅការិយាល័យដើមវិញ។

២-ចំពោះបញ្ញើអនុសិដ្ឋ៖ ទោះជាគ្មានអាស័យដ្ឋានអ្នកផ្ញើក៏ដោយ ចាំបាច់ត្រូវបញ្ជូនត្រឡប់ទៅការិយាល័យដើមវិញ។

៣-ចំពោះប្រៃសណីយ៍ភ័ណ្ឌ៖ អាស្រ័យទៅលើសំណូមពររបស់អ្នកផ្ញើ ឬអ្នកទទួលអាចបញ្ជូនត្រឡប់តាមផ្ទៃរាប ឬតាមអាកាសយាន។ ក្នុងករណីនៅជាប់ពន្ធណាមួយនៅលើភណ្ឌិកាត្រូវបិទស្លាក CP77 និងជ្រើសរើសមូលហេតុនៃការបញ្ជូនត្រឡប់។

៤-បញ្ញើឆាប់រហ័ស EMS និងអាណត្តិ៖ ត្រូវបានអនុវត្តដូចបញ្ញើអនុសិដ្ឋដែរ ប៉ុន្តែត្រូវបានបញ្ជូនទៅតាមផ្លូវបញ្ញើឆាប់រហ័ស។

៥-នៅលើបញ្ញើត្រូវឆូតអាស័យដ្ឋានអ្នកទទួល រួចបោះត្រាឬសរសេរ (បញ្ជូនទៅអ្នកផ្ញើវិញ) (Retour à l'envoyeur) និងបិទស្លាក CN15។

### ៣.៣.១.៣ ពាក្យសុំកែប្រែអាស័យដ្ឋាន

ពាក្យសុំកែប្រែអាស័យដ្ឋានដែលបានបំពេញលើគំរូ CN17 ឬ MP4 ត្រូវបានច្រកក្នុងស្រោមបញ្ជូនតាមផ្លូវបញ្ញើយ៉ាងឆាប់បំផុតទៅកាន់ការិយាល័យទទួល។ ការិយាល័យទទួលត្រូវកែប្រែទៅតាមសំណូមពរនៅពេលបញ្ញើពុំទាន់បានចែក ឬពុំទាន់បើកប្រាក់។ ក្នុងករណីពាក្យសុំបញ្ជូនតាមទូរគមនាគមន៍ ចាំបាច់ CN17 និង MP4 ត្រូវបញ្ជូនតាមក្រោយ ។ (មើលឧបសម្ព័ន្ធទី៥)

### ៣.៣.១.៤ បណ្ដឹងតវ៉ា

អ្នកផ្ញើ ឬអ្នកទទួលបញ្ញើគ្រប់ប្រភេទ មានសិទ្ធិសុំធ្វើពាក្យបណ្ដឹងតវ៉ា ក្នុងករណីដែលបញ្ញើអ្នកទទួលអាចបង្ហាញ G32-2 នៅប្រៃសណីយ៍ណាមួយ ហើយបំពេញលើគំរូ CN08។ ចំពោះតម្លៃត្រូវបានកំណត់ក្នុងតារាងពន្ធអាករ អនុលោមទៅតាមអ្នកសុំ ដោយតាមរយៈប្រៃសណីយ៍ ឬផ្លូវទូរគមនាគមន៍ ចំពោះបញ្ញើអនុសិដ្ឋ ឬមាន AR ត្រូវអនុវត្តទៅតាមមាត្រា ១៧។ ចំពោះបញ្ញើឆ្លងកាត់ដោយចំហរ ប្រៃសណីយ៍ឆ្លងកាត់ ត្រូវបំពេញលើគំរូ CN21 ផ្ញើទៅអោយប្រៃសណីយ៍ដើម រួចបញ្ជូនគំរូ CN08 ទៅប្រៃសណីយ៍ទទួល។ នៅពេលទទួលបាន CN08 ការិយាល័យទទួលត្រូវបំពេញចូល CN18 យកអោយអ្នកទទួលចុះហត្ថលេខារួចផ្ញើត្រឡប់ទៅការិយាល័យដើមវិញ។

### ៣.៣.២ ការត្រួតពិនិត្យលម្អិតនៅភ្នំពេញ

ដោយសារតែពិនិត្យឃើញចំណុចខ្សោយរបស់ខ្លួន និងការគំរាមកំហែងដែលតែងកើតមាននៅតាមមន្ទីរប្រៃសណីយ៍ខេត្ត ដែលមិនទាន់មានសកម្មភាពលំហូរកញ្ចប់បញ្ញើទៀងទាត់ និងមិនទាន់មានពង្រាយភ្នាក់ងារគយនៅឡើយ សហគ្រាសប្រៃសណីយ៍កម្ពុជាមានគោលនយោបាយមួយ

ដែលទាមទារឲ្យកញ្ចប់បញ្ញើទាំងឡាយ ត្រូវវាយតម្លៃនិងដំណើរការនៅសាខាប្រៃសណីយ៍កណ្តាលភ្នំពេញ ។

នៅពេលកញ្ចប់បញ្ញើដែលបានផ្ញើរពីខេត្តចូលមកដល់ប្រៃសណីយ៍នៅភ្នំពេញ មន្រ្តីគយត្រូវប្រមូលឯកសារឲ្យបានគ្រប់គ្រាន់ និងបញ្ជីមួយហៅថា Mail Report ដែលរៀបរាប់អំពីលេខកញ្ចប់បញ្ញើ បញ្ញើឆ្លងកាត់ ចំនួនប្រអប់ និងទម្ងន់ដែលនឹងត្រូវធ្វើការផ្ទៀងផ្ទាត់រៀងរាល់ថ្ងៃ ដែលមានសកម្មភាពបញ្ញើឆ្លងកាត់តាមខេត្ត។ ភ្នាក់ងារប្រៃសណីយ៍ត្រូវទម្លាក់កញ្ចប់បញ្ញើចេញ ពីមធ្យោបាយដឹកជញ្ជូន នៅចំពោះមុខមន្រ្តីគយដើម្បីធ្វើការត្រួតពិនិត្យមុននឹងបញ្ជូន ទៅកាន់ការិយាល័យបញ្ជូនបញ្ញើ ។ ក្រោយពីត្រួតពិនិត្យរួបរ័ន្តរួច កញ្ចប់បញ្ញើទាំងអស់នឹងត្រូវប្រតិបត្តិការ ទៅតាមនីតិវិធីរបស់ប្រៃសណីយ៍ដូចគ្នាទៅបញ្ញើនៅតាមបញ្ជរសាខាប្រៃសណីយ៍នានានៅភ្នំពេញដែរ ។

**៣.៣.៣ ការរៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស**

សកម្មភាពដែលត្រូវបន្តក្នុងការកែទម្រង់ គឺការតម្លើងប្រាក់បៀវត្សន៍ជូននិយោជិកអោយបានសមរម្យ ពង្រឹងវិន័យ និងសាមគ្គីផ្ទៃក្នុង ជាពិសេសគឺការងារបណ្តុះបណ្តាលជំនាញបច្ចេកទេសជូននិយោជិករបស់ប្រៃសណីយ៍កម្ពុជា ។ ជាក់ស្តែងនៅក្នុងឆ្នាំ ២០១៦ ប្រៃសណីយ៍កម្ពុជាសម្រេចបានសមិទ្ធិផលដូចខាងក្រោម៖

ក. ការបណ្តុះបណ្តាលក្នុងប្រទេស៖ បើកវគ្គបណ្តុះបណ្តាលបញ្ជូនថ្នាក់ដឹកនាំ និងនិយោជិក ប.កចូលរួមវគ្គបណ្តុះបណ្តាលចំនួន០៧វគ្គគឺ :

១. វគ្គស្តីពីប្រព័ន្ធ IPS សរុបចំនួន៤៣នាក់ ក្នុងនោះមានស្រីចំនួន០៩នាក់ និងប្រុសចំនួន៣១នាក់ ។

២. វគ្គបណ្តុះបណ្តាលផ្នែកកត្តា សរុបចំនួន៣៩នាក់ មានប្រុសចំនួន៣៩នាក់

៣. វគ្គស្តីពីប្រព័ន្ធ IPS លើ Mobile Scanner សរុបចំនួន៣៥នាក់សុទ្ធតែប្រុសទ

៤. វគ្គស្តីពីសហភាពប្រៃសណីយ៍សកល (UPU) សរុបចំនួន០១នាក់ មានស្រីចំនួន០១នាក់

៥. វគ្គណែនាំពីផលិតផលសេវាកម្មប្រៃសណីយ៍សាធារណៈ: សរុបចំនួន០១នាក់ មានស្រីចំនួន០១នាក់

៦. វគ្គស្តីពីច្បាប់ប្រៃសណីយ៍ និងច្បាប់ទូរគមនាគមន៍ សរុបចំនួន០២នាក់ មានប្រុសចំនួន០២នាក់ ។

៧. ច្បាប់ស្តីពីមូលដ្ឋានគ្រឹះរដ្ឋបាល សរុបចំនួន០១នាក់ មានស្រី០១នាក់ ។

ខ. ការបណ្តុះបណ្តាលក្រៅប្រទេស: បានបញ្ជូនថ្នាក់ដឹកនាំនិយោជិក ប.ក ចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន០៥វគ្គ៖

១. វគ្គ Postal Business Development នៅប្រទេសថៃចំនួន០១នាក់

២. វគ្គ Corporate Management Course នៅប្រទេសប៉ាគីស្ថានចំនួន០១នាក់

៣. វគ្គ Human Resource Management Course នៅប្រទេសថៃចំនួន០១នាក់

៤. វគ្គ E-Business and Technology Management Course នៅប្រទេសថៃចំនួន០១នាក់

៥. វគ្គ Postal Management Course នៅប្រទេសថៃចំនួន០១ ។

### ៣.៣.៤ ការសហការជាមួយស្ថាប័នមានសមត្ថកិច្ច

ការចូលរួមចំណែកយ៉ាងសកម្មក្នុងការស្រាវជ្រាវ បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀន គ្រឿងផ្ទុះ អាវុធយុទ្ធភ័ណ្ឌ សារធាតុវិទ្យុសកម្ម បញ្ហាភេរវកម្ម អន្តរវត្ថុខុសច្បាប់ និងបញ្ញើហាមឃាត់តាមរយៈបញ្ញើប្រៃសណីយ៍ គឺជាកិច្ចការងារដែលត្រូវអនុវត្តន៍ជាប្រចាំពីសំណាក់ភាគីពាក់ព័ន្ធដូចជា បុគ្គលិកប្រៃសណីយ៍ មន្ត្រីគយ មន្ត្រីនគរបាលប៉ូលីសគ្រឿងញៀន ប៉ូលីសសេដ្ឋកិច្ច អាជ្ញាធរមូលដ្ឋាន និងប្រទេសជាដៃគូរ ។ ការបង្ក្រាប និងចាប់បានភ្លាមៗ ភាគច្រើនគឺដោយសារការត្រួតពិនិត្យដោយឈ្លាសវៃ និងការយកចិត្តទុកដាក់ពីមន្ត្រីមានសមត្ថកិច្ច និងការរកឃើញដោយប្រើប្រាស់ម៉ាស៊ីនស្កេនដែលជំនួយរបស់រដ្ឋាភិបាលប្រទេសអូស្ត្រាលី ។ ជាលទ្ធផលយើងសង្កេតឃើញថា ការប៉ុនប៉ងប្រព្រឹត្តបទល្មើស រត់ពន្ធគ្រឿងញៀនរបស់ជនខិលខូចបានធ្លាក់ចុះជាលំដាប់ ដោយក្នុងឆ្នាំ២០១៥ មាន៤ករណី ឆ្នាំ២០១៦ មាន២ករណី និងឆ្នាំ២០១៧ នេះមានតែ១ករណីប៉ុណ្ណោះ និងបញ្ជូនសំណុំរឿងទៅតុលាការ ហើយជនល្មើសត្រូវបានគេស្គាល់អត្តសញ្ញាណដែលខ្លះចាប់បាន ខ្លះទៀតស្ថិតក្នុងការតាមដាន ។

### ៣.៣.៥ ការបំពេញឯកសារដឹកជញ្ជូនដោយដៃ

ទោះបីជាប្រព័ន្ធប្រៃសណីយ៍អន្តរជាតិ ឬប្រព័ន្ធតាមដានបញ្ញើ (IPS) មានភាពល្អឥតខ្ចោះ និងប្រព្រឹត្តទៅបានប្រសើរប៉ុនណាក៏ដោយ ក្នុងលក្ខខណ្ឌណាមួយបញ្ហានឹងកើតឡើង ។ នៅពេលដែលប្រព័ន្ធបញ្ញើអន្តរជាតិ IPS មិនអាចប្រតិបត្តិការទៅបានដោយសារបញ្ហាបច្ចេកទេស ដែលមិនបានគ្រោងទុក ភ្នាក់ងារដឹកជញ្ជូននៃប្រៃសណីយ៍កម្ពុជាបានត្រៀមខ្លួនរួចជាស្រេច ក្នុងការរៀបចំឯកសារដែលធ្វើដោយដៃ ដូចជា Manifest; Mail Report; ដឹការអមដឹកជញ្ជូន និងឯកសារផ្ទៀងផ្ទាត់ពាក់ព័ន្ធផ្សេងៗទៀត ដោយដំណើរការទៅតាមនីតិវិធីដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ដូចធម្មតាដែរ ដើម្បីសម្រួលយ៉ាងណាឲ្យការដឹកជញ្ជូនបញ្ញើចេញអាចប្រព្រឹត្តទៅបានទាន់ពេលវេលា និង ជៀសវាងការ

បង្អាកឬពន្យាកាលវិភាគជើងហោះហើរ និងការពារកុំឲ្យបញ្ញើដែលឆាប់ខូចគុណភាពទៅដល់ប្រទេសគោលដៅមានការយឺតយ៉ាវ ។ ដោយឡែកចំពោះព័ត៌មាន និងទិន្នន័យបញ្ញើនឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធបញ្ញើអន្តរជាតិដដែល ក្រោយពេលដែលប្រព័ន្ធដំណើរការប្រក្រតីឡើងវិញ ដើម្បីធានានូវនិរន្តភាព និងប្រសិទ្ធិភាពនៃការគ្រប់គ្រងបញ្ញើប្រៃសណីយ៍ជាអន្តរជាតិ ។

### ៣.៣.៦ របៀបបទអនុវត្តក្នុងករណីបញ្ញើពុំអាចចែកបាន

ជាទូទៅក្នុងករណីអ្នកទទួលអវត្តមាន បញ្ញើប្រៃសណីយ៍គ្រប់ប្រភេទយកទៅចែកបានចំនួនបីដង ។ នៅរាល់ពេលដែលយកទៅចែកត្រូវកត់ត្រានូវមូលហេតុដែលចែកមិនបានហើយចុះថ្ងៃ ខែ និងឆ្នាំលើបញ្ញើ ។ លើកទីបីដែលនៅតែចែកពុំបាន កត្តាត្រូវទុកលិខិតអញ្ជើញនៅអាស័យដ្ឋានអ្នកទទួលដើម្បីឲ្យមកបើកផ្ទាល់នៅបញ្ជរប្រៃសណីយ៍កម្ពុជា ។ ដោយឡែកក្នុងករណីដឹងច្បាស់ថាអ្នកទទួលផ្លាស់ប្តូរអាស័យដ្ឋានដោយគ្មានជូនដំណឹង ឬអ្នកទទួលស្លាប់គ្មានអ្នកស្នង ឬក៏អ្នកទទួលបដិសេធ ការចែកអនុវត្តតែមួយលើកប៉ុណ្ណោះ ហើយកត់ត្រាពីមូលហេតុ រួចបញ្ជូនមកការិយាល័យប្រៃសណីយ៍វិញ ។ ករណីចែកមិនបានមានដូចខាងក្រោមនេះ៖

1. អាស័យដ្ឋានមិនគ្រប់គ្រាន់ គ្មានលេខផ្ទះ គ្មានឈ្មោះផ្លូវ។
2. ឈ្មោះជាន់គ្នា។
3. គ្មានអ្នកស្គាល់។
4. ចាកចេញដោយគ្មានទុកអាស័យដ្ឋានថ្មី។
5. អ្នកទទួលអនិច្ចកម្មគ្មានអ្នកស្នង។
6. អ្នកទទួលបដិសេធ ។ល។

នៅលើបញ្ញើត្រូវវាយត្រា ឬបិទស្លាក CN15 និងខ្វែងពីចំនុចដែលចែកពុំបាន ។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ផ្អែកទៅតាមលទ្ធផលដែលសម្រេចបានក្នុងឆ្នាំ២០១៦នេះ អាចវាយតម្លៃបានថាសេវាកម្មអាជីវកម្មប្រៃសណីយ៍ មានការរីកចម្រើនមួយកម្រិតគួរអោយកត់សំគាល់ ។ យើងសង្កេតឃើញថា ទោះបីមានផ្នែកខ្លះមានការរីកចម្រើនសមស្របតាមកម្រិតអភិវឌ្ឍន៍ក៏ដោយ ក៏នៅមានផ្នែកខ្លះទៀតពុំទាន់អាចបំពេញបានគ្រប់សំណូមពរ និងចាំបាច់ត្រូវបន្តខិតខំបន្ថែមទៀតតួយ៉ាងដូចជា ត្រូវបង្កើនជើងបញ្ញើអោយបានច្រើនទៀតទៅកាន់បណ្តាខេត្តសំខាន់ៗ ។ ម៉្យាងវិញទៀតត្រូវបង្កើននូវការគ្រប់គ្រងចំណូលអោយបានល្អ ដោយកាត់បន្ថយចំណាយដែលពុំចាំបាច់អោយស្ថិតក្នុងកម្រិតទាបបំផុត ។ លើសពីនេះទៅទៀត បង្កើនការបន្តកិច្ចសហការជាមួយស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីធានាអោយបានភាពដ៏ប្រសើរបំផុតក្នុងការស្តារ និងការវិភិវឌ្ឍន៍វិស័យប្រៃសណីយ៍ជ្រាបចូលជ្រៅដល់ទីជនបទ ។ បន្ថែមលើនេះក្រុមហ៊ុនប្រៃសណីយ៍កម្ពុជា បានខិតខំពង្រឹងគុណភាពសេវាប្រៃសណីយ៍ដោយបន្តពង្រឹងសាមគ្គីធានាឯកភាព និងប្រកាន់ខ្ជាប់វិន័យការងារជំនាញអោយរឹតតែរឹងមាំថែមទៀត ដើម្បីសម្រេចបានការងារសម្រាប់ជាគុណប្រយោជន៍ដល់កិច្ចអភិវឌ្ឍ។ ជាពិសេសក្រុមហ៊ុនប្រៃសណីយ៍ បានព្យាយាមប្រឹងប្រែងដោយផ្តោតទៅលើការយកចិត្តទុកដាក់បន្តការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រច្បាស់លាស់សម្រាប់វិស័យប្រៃសណីយ៍ ដោយមានយន្តការត្រួតពិនិត្យ និងពង្រឹងគុណភាពការងារទាំងថ្នាក់កណ្តាល និងតាមបណ្តាខេត្តដើម្បីបង្កើនប្រសិទ្ធិភាពសេវាអោយកាន់តែប្រសើរថែមទៀត សំដៅទៅលើការជួយលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រក្នុងសង្គម ។

ដើម្បីបម្រើសេវាកម្មអោយកាន់តែមានភាពឆ្លើយតប ជំនឿទុកចិត្ត ប្រសិទ្ធិភាព និងប្រសិទ្ធិផល ប្រៃសណីយ៍កម្ពុជាមានទិសដៅសម្រាប់ឆ្នាំ២០១៧ គឺបន្តការអភិវឌ្ឍន៍លើបណ្តាញដឹកជញ្ជូន (បង្កើតសេវាដឹកជញ្ជូនភ្ញៀវក្នុងស្រុក) ។ ប្រៃសណីយ៍កម្ពុជា មានការបង្កើតនូវសេវាថ្មីៗទៅតាមតម្រូវការទីផ្សារនាពេលបច្ចុប្បន្ន និងតាមបច្ចេកវិទ្យាICT (E-Post Services) ក៏ដូចជាការបង្កើតនូវសេវាទទួល និងបែងចែកវិក័យប័ត្រតាមបណ្តាស្ថាប័នរដ្ឋ សហគ្រាស ធនាគារឯកជន និងអង្គការនានា។ លើសពីនេះទៀត ប្រៃសណីយ៍កម្ពុជានឹងបង្កើតបរិមាណប្រអប់សំបុត្រជួលជាវ និងរៀបចំលក្ខណៈបច្ចេកទេសប្រអប់អោយស្របតាមកម្រិតស្តង់ដារអន្តរជាតិ ។ មិនតែប៉ុណ្ណោះថែមទាំងមានការបន្តពង្រីកបន្ថែមប្រព័ន្ធត្រួតពិនិត្យតាមបញ្ជរប្រៃសណីយ៍ (Counter Automation ) ប្រព័ន្ធតាមដានបញ្ញើប្រៃសណីយ៍ (International Postal Scanner ) , ប្រព័ន្ធIFS (International Financial

System ) អោយបានគ្រប់ខេត្តក្រុងទូទាំងប្រទេស ។ ជាពិសេសជាងនេះទៀត ប្រៃសណីយ៍កម្ពុជា បានបន្តបំពាក់Mobile Scanner អោយបានគ្រប់កត្តាចែកសេវាEMS និងបន្តការសាងសង់ ការជួល ជុលកែលំអរសាខា ប.ក គ្រប់ខេត្តក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេសអោយបានសមរម្យ ដែលជាទីតាំងបម្រើអាជីវកម្ម ។

## ២. ការផ្តល់អនុសាសន៍

ក្រោយពីសិក្សាលើផ្នែកទ្រឹស្តី និងសកម្មភាពអនុវត្តជាក់ស្តែងរបស់ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជា (Cambodia Post) រួចមក យើងចាប់អារម្មណ៍ឃើញថា ទោះបីជាក្រុមហ៊ុនប្រៃសណីយ៍កម្ពុជា មានចំណុចវិជ្ជមានជាច្រើន និងមានការរីកចម្រើនទៅមុខជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំយ៉ាងណាក៏ដោយ បើក្រឡេកមើលនិងវិភាគឲ្យបានល្អិតល្អន់ យើងរកឃើញពីបញ្ហាខ្លះៗដែលទាមទារឲ្យក្រុមហ៊ុនមួយនេះមានការយកចិត្តទុកដាក់ ហើយក្នុងនាមយើងខ្ញុំជានិស្សិតសូមផ្តល់ជាអនុសាសន៍ក្នុងការចូលរួម និងកែតម្រូវ ដើម្បីឲ្យវិស័យប្រៃសណីយ៍កម្ពុជាកាន់តែមានការវិវត្តន៍ទៅមុខដូចតទៅ៖

✓ ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជាត្រូវបង្កើតគោលនយោបាយថ្មីមួយ គឺការទទួលខុសត្រូវលើការបាក់បែក ខូចខាត និងចេញសងចំពោះរាល់ទំនិញទាំងអស់ ។ ក្នុងករណីដឹងថាការវេចខ្ចប់មិនបានល្អ ហើយម្ចាស់នៅតែទទូចផ្ញើ បុគ្គលិកប្រៃសណីយ៍មិនត្រូវទទួលឲ្យផ្ញើដាច់ខាត ។ ហេតុនេះពេលដែលទំនិញផ្ញើរទៅដល់ប្រទេសគម្យដ្ឋាន អ្នកទទួលអាចទៅទទួលបាននូវកញ្ចប់បញ្ញើប្រៃសណីយ៍ប្រើការបាន មានសុវត្ថិភាព និងមានគុណភាពដូចដើមហើយក៏កាត់បន្ថយបណ្តឹងតវ៉ាដដែលៗមិនចាំបាច់ ។ ចំណែកឯក្រុមហ៊ុនអាចការពារកេរ្តិ៍ឈ្មោះ និងរក្សាតម្លៃរបស់ខ្លួនបានល្អប្រសើរជាជាងការគិតតែពីផលប្រយោជន៍ និងប្រាក់ចំណេញតែមួយមុខ ។

✓ ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជា ត្រូវធ្វើយ៉ាងណាស្នើសុំម៉ាស៊ីនស្កេនបន្ថែមទៀត ដើម្បីអោយត្រួតពិនិត្យទំនិញដែលផ្ញើនៅតាមខេត្តមុននឹងបញ្ជូនមកកាន់ទីស្នាក់ការប្រៃសណីយ៍ភ្នំពេញ ដោយហេតុថាការដឹកជញ្ជូនដោយរថយន្តតាមខេត្តមកភ្នំពេញ អាចនឹងខាតបង់ពេលវេលាច្រើន ករណីប្រធានសក្តិ និងកត្តាផ្សេងៗទៀតដែលមិនអាចព្យាករណ៍ទុកមុនបាន ។ ការស្កេនទៀតសោធ គឺកាន់តែលឿន និងមានប្រសិទ្ធិភាពជាងមុន ។ ក្នុងករណីដែលទំនិញមានការសង្ស័យ ហើយនៅតែស្កេនមិនឃើញ សាខាប្រៃសណីយ៍ខេត្ត-ក្រុង ចាំបាច់ត្រូវសុំសហការជាមួយកម្លាំងជំនាញ និងមន្ត្រីមានសមត្ថកិច្ច ។

✓ នៅថ្ងៃអនាគតខាងមុខ សហគ្រាសប្រៃសណីយ៍កម្ពុជាត្រូវតែគិតគូរពីការប្រើប្រាស់យន្តហោះដឹកជញ្ជូនបញ្ញើផ្ទាល់ខ្លួនមួយ ដែលអាចចរាចរបាននៅគ្រប់ប្រៃសណីយ៍ ទូទាំងប្រទេសកម្ពុជា

ដើម្បីពន្លឿនការដឹកជញ្ជូនបញ្ញើពីតាមខេត្តមកភ្នំពេញ និងពីក្នុងស្រុកទៅកាន់អន្តរជាតិបានដោយរលូននិងមានប្រសិទ្ធិភាពជាងនេះ សម្រាប់បំពេញតម្រូវការចាំបាច់របស់អតិថិជននៅទូទាំងពិភពលោក ។

✓ ក្នុងនាមជាក្រុមហ៊ុនបញ្ញើ និងដឹកជញ្ជូន ប្រៃសណីយ៍កម្ពុជាត្រូវបង្កើតសេវាកម្មថ្មីមួយទៀតគឺសេវាកម្មលក់ទំនិញ តាមរយៈមធ្យោបាយអេឡិចត្រូនិក(e-commerce) ដែលដាក់លក់ទំនិញដូចជាតែមប្រ៍ សៀវភៅប្រវត្តិសាស្ត្រ ភូមិសាស្ត្រ វប្បធម៌ អរិយធម៌ អក្សរសាស្ត្រខ្មែរ គ្រឿងអេឡិចត្រូនិក និងសម្ភារៈប្រើប្រាស់ដទៃទៀត ដែលផ្តល់លទ្ធភាពឲ្យភ្ញៀវជាតិ និងអន្តរជាតិបានទំនាក់ទំនងទិញ និងដឹកជញ្ជូនដល់ទីកន្លែង ។ ក្នុងន័យនេះ ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជាអាចពង្រីកខ្លួនយ៉ាងខ្លាំងទៅក្នុងទីផ្សារអន្តរជាតិ និងអាចបង្កើនប្រាក់ចំណូលទ្វេរដង ។

✓ ក្រុមហ៊ុនប្រៃសណីយ៍កម្ពុជាជាពិសេសបណ្តាមន្ទីរប្រៃសណីយ៍តាមខេត្តនានា ត្រូវសហការជាមួយមន្ត្រីគយមានសមត្ថកិច្ច ផ្សព្វផ្សាយ និងផ្តល់ព័ត៌មានដល់អតិថិជនឲ្យបានទូលំទូលាយ និងអាចដាក់បញ្ចូលពីច្បាប់ បទបញ្ញត្តិ និងនីតិវិធីគយស្តីពីការបង់ពន្ធ អាករ និងកម្រៃផ្សេងៗដែលទាក់ទងនឹងការនាំចេញនាំចូលតាមច្រកប្រៃសណីយ៍ ដើម្បីចៀសវាងការភ័ន្តច្រឡំថាទំនិញនាំចូលតាមប្រៃសណីយ៍មិនមានបង់ពន្ធ ឬថាសេវាកម្មថ្លៃដឹកជញ្ជូនប្រៃសណីយ៍ជាថ្លៃពន្ធនាំចូល ។

# ឯកសារយោង

- **ឯកសារយោងជាភាសាខ្មែរ**


១. ឯកសារៈ វគ្គបណ្ដុះបណ្ដាលនៅសមាគមន៍ភ្នាក់ងារបញ្ជូនទំនិញកម្ពុជាឆ្នាំ២០១១ក្នុងមេរៀនៈ Trade and transport linkage ។
២. ឯកសារៈ វគ្គបណ្ដុះបណ្ដាលនៅសមាគមន៍ភ្នាក់ងារបញ្ជូនទំនិញកម្ពុជាឆ្នាំ២០១៥ក្នុងមេរៀនៈ Liability of Multimodal Transport Operation (MTO) ។
៣. របាយការណ៍ស្ដីពីលទ្ធផលការងារអាជីវកម្មឆ្នាំ២០១៦ និងទិសដៅឆ្នាំ២០១៧ប្រៃសណីយ៍កម្ពុជា ។
៤. តារាងតម្លៃសេវាប្រៃសណីយ៍ អនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧
៥. ឯកសារៈស្ដីពីពានរង្វាន់អន្តរជាតិភាពជាអ្នកដឹកនាំឆ្នើម២០១៦ ក្នុងសៀវភៅ វិញ្ញាបនប័ត្របញ្ជាក់ពីកម្រិតសមត្ថភាពនៃការគ្រប់គ្រង ឆ្នាំ២០១៤ ដោយUPU ។
៦. ឯកសារៈ ច្បាប់ស្ដីពីវិស័យប្រៃសណីយ៍ដោយមានចែងក្នុងមាត្រា៣៣
៧. ព័ត៌មានលំអិតសូមចុចចូលក្នុងគេហទំព័ររបស់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ
៨. ច្បាប់ស្ដីពីវិស័យប្រៃសណីយ៍


- **ឯកសារយោងជាភាសាអង់គ្លេស**


៩. គេហទំព័រFresh New: http://m.freshnewasia.com/index.ph/en/17765-2016-02-11-07-13-21.html
១០. គេហទំព័រ: http://www.tradingeconomics.com/cambodia/balance-of-trade
១១. គេហទំព័រ: http://en.m.wikipedia.org/wiki/Management
១២. គេហទំព័រ: thebizmangmentguide.com
១៣. គេហទំព័រ: Universal Postal Union
១៤. គេហទំព័រ: customs.gov.ph/wp-content/uploads/2016/10/KYOTO-Convention.pdf
១៥. គេហទំព័រ:(http://www.advancedontrade.com/2015/02/what-are-differences-between-air-waybill-and-bill-of-lading.html)
១៦. គេហទំព័រ: (http://www.customs.gov.kh/km/)
១៧. គេហទំព័រ: http://www.upu.int/uploads/tx_sbdownloader/ips20YearsEn.pdf
១៨. តាមរយៈគេហទំព័រ: http://m.postkhmer.com/សេដ្ឋកិច្ច/ប្រៃសណីយ៍កម្ពុជា-នឹងបង្កើតក្រុមហ៊ុនសេវាអនឡាញ

# សេចក្ដីណែនាំក្នុងការបំពេញបែបបទផ្ញើបញ្ញើឆាប់រហ័ស ( EMS )

## Guide To Completing EMS Forms

**មុននឹងបំពេញទម្រង់នេះ លោកអ្នកគួរតែអានសេចក្ដីណែនាំនៅផ្នែកខាងក្រោមឲ្យបានគ្រប់ជ្រុងជ្រោយជាមុនសិន។**



**1**

បំពេញអាសយដ្ឋានអ្នកផ្ញើ ជាភាសាខ្មែរ ឬអង់គ្លេស ឲ្យបានច្បាស់លាស់ ពេញលេញ ដោយមានលេខទូរស័ព្ទ ឬបញ្ជាក់លេខកូដ ប្រៃសណីយ៍ផងដែរ។ ឧទាហរណ៍៖

ឡាយ ប៊ុសេង
ផ្ទះលេខ 97 ក្រុម ៣ ភូមិ ១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
ភ្នំពេញ 12203 ប្រទេសកម្ពុជា
ទូរស័ព្ទលេខ: 012 823 827



**2**

បំពេញអាសយដ្ឋានអ្នកទទួល ជាភាសាខ្មែរ ឬអង់គ្លេស ឲ្យបានច្បាស់លាស់ ពេញលេញ ដោយមានលេខទូរស័ព្ទ និងបញ្ជាក់លេខកូដប្រៃសណីយ៍ផងដែរ។ ឧទាហរណ៍៖

Mr. Koang Hocun
284 Steven St Lowell MA 01851, USA
Tel: 9788884250

**3**

គូសខ្វែងក្នុងប្រអប់សមស្របទៅនឹងប្រភេទបញ្ញើរបស់លោកអ្នក នៅក្នុង ប្រតិវេទន៍គយ ត្រូវគូសខាងជាចាំបាច់។ ប្រសិនជាបញ្ញើរបស់លោកអ្នកជា ឯកសារ លោកអ្នក ត្រូវតែគូសខ្វែងក្នុងប្រអប់ឯកសារ (Document) ជាការស្រេច។ ករណីដែលបញ្ញើមិនមែនជាឯកសារ នោះបន្ទាប់ពីគូសខ្វែងក្នុងប្រអប់សមស្របហើយ លោកអ្នក ត្រូវសរសេរបន្ថែមនូវឈ្មោះអង្គវត្ថុខាងក្រោម។ ក្នុងករណីអង្គវត្ថុមានតម្លៃលើសពី ៣០០$ លោកអ្នកត្រូវបំពេញសារលិខិត CN 23 បន្ថែមទៀត។

លោកអ្នក ត្រូវសហការជាមួយបញ្ជរប្រៃសណីយ៍ (Counter Clerk) ប្រៃសណីយ៍ក្នុងការបំពេញសារលិខិត CN 23 ឲ្យបានត្រឹមត្រូវ។ សារលិខិតនេះត្រូវបំពេញដោយមានក្រដាសកាបោន និងធ្វើជា ០៤សន្លឹក ហើយត្រូវភ្ជាប់ជាមួយនឹងបញ្ញើចំនួន ០២សន្លឹក។ ចំណែកឯ ០២សន្លឹកទៀតសម្រាប់ប្រៃសណីយ៍និងលោកអ្នក ម្នាក់មួយសន្លឹក ដើម្បីរក្សាទុក។



# <u>សេចក្តីណែនាំក្នុងការបំពេញបែបបទផ្ញើបញ្ញើប្រៃសណីយ៍កញ្ចប់ ( CP )</u>

## <u>Guide To Completing Parcel Post Forms</u>

**មុននឹងបំពេញទម្រង់នេះ លោកអ្នកគួរតែអានសេចក្តីណែនាំនៅផ្នែកខាងក្រោមឲ្យបានគ្រប់ជ្រុងជ្រោយជាមុនសិន។**



**1**

បំពេញអាសយដ្ឋានអ្នកផ្ញើ ជាភាសាខ្មែរ ឬអង់គ្លេស ឲ្យបានច្បាស់លាស់ ពេញលេញ ដោយមានលេខទូរស័ព្ទ ឬបញ្ជាក់លេខកូដ ប្រៃសណីយ៍ផងដែរ។ ឧទាហរណ៍៖

ឡាយ ប៊ុនសោ
ផ្ទះលេខ 97 ក្រុម ៣ ភូមិ ១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
ភ្នំពេញ 12203 ប្រទេសកម្ពុជា
ទូរស័ព្ទលេខ: 012 823 827



**2**

បំពេញអាសយដ្ឋានអ្នកទទួល ជាភាសាខ្មែរ ឬអង់គ្លេស ឲ្យបាន ច្បាស់លាស់ ពេញលេញ ដោយមានលេខទូរស័ព្ទ និងបញ្ជាក់លេខកូដ ប្រៃសណីយ៍ផងដែរ។ ឧទាហរណ៍៖

Mr. Keang Hoeun
284 Steven St Lowell MA 01851, USA
Tel: 9788884250

**3**

គូសធីកក្នុងប្រអប់សមស្របទៅនឹងប្រភេទបញ្ញើរបស់លោកអ្នក នៅក្នុង <u>ប្រភេទទំនិញ</u> ក្រោមនេះជាចាំបាច់។ ប្រសិនបើបញ្ញើរបស់លោកអ្នកជា ឯកសារ លោកអ្នក ត្រូវតែគូសធីកក្នុងប្រអប់ឯកសារ (Document) ជាការស្រេច។ ករណីដែលបញ្ញើមិនមែនជាឯកសារ នោះបន្ទាប់ពីគូសធីកក្នុងប្រអប់សមស្របហើយ លោកអ្នក ត្រូវសរសេរ បរិយាយឈ្មោះអង្គធាតុខាងក្នុង។ ក្នុងករណីអង្គធាតុមានតម្លៃលើសពី ៣០០$ លោកអ្នកត្រូវបំពេញសាលាប័ត្រ CN 23 បិទភ្ជាប់បន្ថែមទៀត។

លោកអ្នក ត្រូវសហការជាមួយបញ្ជរបេឡា (Counter Clerk) ប្រៃសណីយ៍ក្នុងការបំពេញសាលាប័ត្រ CN 23 ឲ្យបានត្រឹមត្រូវ។ សាលាប័ត្រនេះត្រូវបំពេញដោយមានក្រដាសកាបោន និងធ្វើជា ០៤សន្លឹក ហើយត្រូវបិទភ្ជាប់នឹងបញ្ញើចំនួន ០២សន្លឹក។ ចំណែកឯ ០២សន្លឹកទៀតសម្រាប់ប្រៃសណីយ៍និងលោកអ្នក ម្នាក់មួយសន្លឹក ដើម្បីរក្សាទុក។



| [illegible] | [illegible] | Zone | [illegible] | [illegible] | Zone | [illegible] | [illegible] | Zone |
|---|---|---|---|---|---|---|---|---|
| 1 | Thailand | A | 36 | Bahamas | E | 71 | Cyprus | F |
| 2 | Bangladesh | B | 37 | Barhrain | E | 72 | Denmark | F |
| 3 | Brunei Darussalam | B | 38 | Belgium | E | 73 | France | F |
| 4 | Hong Kong | B | 39 | Bulgaria | E | 74 | Germany | F |
| 5 | Indonesia | B | 40 | Estonia | E | 75 | Great Britain | F |
| 6 | Lao | B | 41 | Fiji | E | 76 | Ireland | F |
| 7 | Macau | B | 42 | Finland | E | 77 | Israel | F |
| 8 | Malaysia | B | 43 | Greece | E | 78 | Jamaica | F |
| 9 | Philippines | B | 44 | Hungary | E | 79 | Malta | F |
| 10 | Singapore | B | 45 | Iceland | E | 80 | Netherlands | F |
| 11 | Vietnam | B | 46 | Iran | E | 81 | South Africa | F |
| 12 | Bhutan | C | 47 | Italy | E | 82 | Spain | F |
| 13 | China | C | 48 | Kenya | E | 83 | Switzerland | F |
| 14 | India | C | 49 | Kyrghyzstan | E | 84 | United Kingdom | F |
| 15 | Japan | C | 50 | Macedonia | E | 85 | Argentina | F |
| 16 | Korea, Rep. of | C | 51 | Mongolia | E | 86 | Barbados | G |
| 17 | Nepal | C | 52 | Nauru | E | 87 | Brazil | G |
| 18 | Pakistan | C | 53 | New Caledonia | E | 88 | Ghana | G |
| 19 | Sri Lanka | C | 54 | Norway | E | 89 | Mexico | G |
| 20 | Taiwan | C | 55 | Oman | E | 90 | Canada | I |
| 21 | Australia | D | 56 | Poland | E | 91 | USA | I |
| 22 | Egypt | D | 57 | Portugal | E | | | |
| 23 | Jordan | D | 58 | Qatar | E | | | |
| 24 | Kuwait | D | 59 | Russia | E | | | |
| 25 | Luxembourg | D | 60 | Saudi Arabia | E | | | |
| 26 | Maldives | D | 61 | Slovenia | E | | | |
| 27 | Mauritius | D | 62 | Solomon Island | E | | | |
| 28 | Myanmar | D | 63 | Sweden | E | | | |
| 29 | New Zealand | D | 64 | Tanzania | E | | | |
| 30 | Papua New Guinea | D | 65 | Ukraine | E | | | |
| 31 | Romania | D | 66 | United Arab Emirates | E | | | |
| 32 | Seychelles | D | 67 | Vanuatu | E | | | |
| 33 | Turkey | D | 68 | Western Samoa | E | | | |
| 34 | Yemen | D | 69 | Zimbabwe | E | | | |
| 35 | Austria | E | 70 | Belarus | F | | | |

| ល.រ | ឈ្មោះប្រទេស | តំបន់ |
|---|---|---|
| 1 | Argentina | K |
| 2 | Australia | F |
| 3 | Austria | H |
| 4 | Belgium | H |
| 5 | Brazil | K |
| 6 | Brunei | B |
| 7 | Bulgaria | I |
| 8 | Canada | J |
| 9 | China | C |
| 10 | Cyprus | I |
| 11 | Czech | G |
| 12 | Denmark | F |
| 13 | Egypt | F |
| 14 | Estonia | I |
| 15 | Fiji | G |
| 16 | Finland | H |
| 17 | France | G |
| 18 | Germany | G |
| 19 | Ghana | I |
| 20 | Great Britian | H |
| 21 | Greece | G |
| 22 | Hong Kong | D |
| 23 | Hungary | H |
| 24 | Iceland | H |
| 25 | India | D |
| 26 | Indonesia | C |
| 27 | Ireland | H |
| 28 | Israel | E |
| 29 | Italy | F |
| 30 | Japan | E |
| 31 | Kenya | E |
| 32 | Korea South | D |
| 33 | Korea North | F |

| ល.រ | ឈ្មោះប្រទេស | តំបន់ |
|---|---|---|
| 34 | Lao | B |
| 35 | Luxembourg | G |
| 36 | Malaysia | B |
| 37 | Mexico | K |
| 38 | Mongolia | D |
| 39 | Myanmar | B |
| 40 | Netherlands | H |
| 41 | New Caledonia | G |
| 42 | New Zealand | H |
| 43 | Nigeria | I |
| 44 | Norway | H |
| 45 | Pakistan | D |
| 46 | Panama | K |
| 47 | Philippines | B |
| 48 | Poland | F |
| 49 | Portugal | H |
| 50 | Romania | H |
| 51 | Russia | I |
| 52 | Saudi Arabia | E |
| 53 | Singapore | B |
| 54 | South Africa | G |
| 55 | Spain | G |
| 56 | Sweden | G |
| 57 | Switzerland | F |
| 58 | Taiwan | C |
| 59 | Thailand | A |
| 60 | Turkey | I |
| 61 | United Arab Emirate | E |
| 62 | USA | J |
| 63 | Venezuela | K |
| 64 | Viet Nam | B |
| 65 | Scotland | H |
| 66 | Colombia | K |

| ល.រ | ឈ្មោះប្រទេស | តំបន់ |
|---|---|---|
| 1 | Argentina | H |
| 2 | Australia | C |
| 3 | Austria | C |
| 4 | Belgium | D |
| 5 | Brazil | H |
| 6 | Brunei | B |
| 7 | Bulgaria | F |
| 8 | Canada | F |
| 9 | China | C |
| 10 | Cyprus | H |
| 11 | Czech | F |
| 12 | Denmark | C |
| 13 | Egypt | H |
| 14 | Estonia | H |
| 15 | Fiji | E |
| 16 | Finland | G |
| 17 | France | D |
| 18 | Germany | D |
| 19 | Ghana | F |
| 20 | Great Britian | G |
